01382259

E1/474.1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 27-Jan-2017, 08:30

CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៤៥៥**

ចៅក្រមសាលាដំបូង៖

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

ក្រឡាបញ្ជីសាលាដំបូង៖

កញ្ញា ជា ស៊ីវហ៊ាង

លោក ហាសាន អាធុរេលិយ៉ា

*(Mr.HARSHAN Athureliya)*

ការិយាល័យសហព្រះរាជអាជ្ញា៖

លោក សេង លាង

លោក ឌេល លីសាក់ *(Mr.Dale Lysak)*

លោក ស្រ៊ា រតនៈ

ជនជាប់ចោទ៖

លោក នួន ជា

លោក ខៀវ សំផន

មេធាវីការពារជនជាប់ចោទ នួន ជា៖

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរលក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោក ឡេា ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម យូរ ឧត្តរា | ខ្មែរ |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី សួ សុទ្ធាវី | ខ្មែរ |
| លោក នឹម អ៊ឹម (2-TCE-854) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក នឹម អ៊ុំម** (2-TCW-854)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៤
សួរដោយលោក វិចទ័រ កូប៉េ ផ្តើមពី........................................ ទំព័រ ១០
សួរដោយលោក ឌេល លីសាក់ ផ្តើមពី ........................................ ទំព័រ ៥៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៣៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគី និង សាធារណជនឲ្យបានជ្រាបថា ឥឡូវនេះ ស្ថានភាពសុខភាពរបស់ប្រធាន និល ណុន មានសុខភាពល្អ ប្រសើរឡើងវិញហើយ ហើយអង្គជំនុំជម្រះរំពឹងថា លោកប្រធាននឹងអាចចូលរួមនៅក្នុងកិច្ចដំណើរនីតិវីធីសវនាការក្នុងពេលឆាប់ៗខាងមុខនេះ បន្ទាប់ពីគាត់បានទទួលដំណឹងពេញលេញអំពីការវិវត្តន៍នៃរឿងក្តីនេះនៅក្នុងអំឡុងពេលដែលគាត់អវត្តមាន។

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)* -- ខ្ញុំស្តាប់ទៅឮសំឡេងខ្យល់ឈូឆរ មិនដឹងថាយ៉ាងម៉េចដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គភាពបកប្រែ ភាសាខ្មែរក៏អត់ឮដែរ។ សូមរៀបចំឡើងមន្ត្រីរដ្ឋបាលតុលាការ!

[០៩:០២:៣៤]

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគី និង សាធារណជនឲ្យបានជ្រាបថា ឥឡូវនេះ ស្ថានភាពសុខភាពរបស់ប្រធាន និល ណុន មានសុខភាពល្អប្រសើរឡើងវិញហើយ ហើយអង្គជំនុំជម្រះរំពឹងថា លោកប្រធាននឹងអាចចូលរួមនៅក្នុងកិច្ចដំណើរនីតិវិធីសវនាការក្នុងពេលឆាប់ៗខាងមុខនេះ បន្ទាប់ពីគាត់បានទទួលដំណឹងពេញលេញអំពីការវិវត្តន៍នៃរឿងក្តីនេះ នៅក្នុងអំឡុងពេលដែលគាត់អវត្តមាន។

សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សី 2-TCW-854 ពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខស-២១។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន និង បុគ្គលដែលអង្គជំនុំជម្រះ--

សូមអញ្ជើញលោកស្រី!

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមកាត់ផ្តាច់លោកប្រធាន គឺថាខ្ញុំមានបញ្ហានៅ*កាណាល់* ជាភាសាបារាំងហ្នឹង គឺឮសូរខ្យល់ឈូរៗ ស្ដាប់ឮសំឡេងអ្នកបកប្រែសឹងតែមិនបាន លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីខាងសោតទស្សន៍ពិនិត្យមើលឧបករណ៍ខាងភាសាបារាំងអត់ឮសូរសំឡេងទេ ឮសូរខ្យល់។

[០៩:០៥:00]

*(មានបញ្ហាបច្ចេកទេស)*

[០៩:០៨:០៥]

**ប្រធានអង្គជំនុំ៖**

គ្រប់ភាគី តើឮសំឡេងទេ?

**កញ្ញា អង់តា ហ្គីសសេះ**

ឥឡូវធម្មតាវិញហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

អង្គជំនុំជម្រះប្រកាសបន្តទៀត។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរកិច្ចនីតិវិធីសវនាការ។

អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគី និងសាធារណជនឲ្យជ្រាបថា ឥឡូវនេះស្ថានភាពសុខភាពរបស់លោកប្រធាន និល ណុន មានភាពល្អប្រសើរវិញហើយ។ ហើយអង្គជំនុំជម្រះរំពឹងថា លោកប្រធាននឹងអាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងពេលឆាប់ៗខាងមុខនេះ បន្ទាប់ពីគាត់បានទទួលដំណឹងពេញលេញអំពីការវិវត្តន៍នៃរឿងក្ដីនេះ នៅក្នុងអំឡុងពេលដែលគាត់អវត្តមាន។

សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មសាក្សី 2-TCW-854 ពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខស-២១។

ក្រឡាបញ្ជីសវនាការ លោកស្រី ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញចូលរួមក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។ សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ លើកលែងតែលោកមេធាវី លីវ សុវណ្ណា មេធាវីជាតិការពារក្ដីឲ្យលោក នួន ជា បានជូនដំណឹងមកថា នឹងអវត្តនៅសវនាការព្រឹកនេះ ដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-854។ ហើយសាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខអ្នកតាមដំបងដែកកាលពីម្សិលមិញនេះ។ សាក្សីមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ នៅថ្ងៃនេះដែរ មានដើមបណ្ដឹងរដ្ឋប្បវេណីបម្រុងមួយរូបដែលមានរហស្សនាម 2-TCCP-283។

សូមអរគុណលោកប្រធាន។

[០៩:១០:១៣]

**ប្រធានអង្គជំនុំ៖**

អរគុណកញ្ញា ស៊ីវហ័ង។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាពខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦។ មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលស្នើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ បានកត់

សម្គាល់ថា ស្ថានភាពសុខភាពលោក នួន ជា នៅថ្ងៃនេះ មានអាការៈឈឺចង្កេះជាប្រចាំ ហើយនិងកាន់តែឈឺខ្លាំងនៅពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួន មួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ឲ្យចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សី 2-TCW-854 មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:១៣:៥៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តី លោកសាក្សី តើលោកឈ្មោះអីដែរ? លោកសាក្សី នៅពេលដែលលោកឆ្លើយចាំមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហម ចាំលោកឆ្លើយ។

**លោក នឹម អ៊ឹម៖**

**ឆ៖** ខ្ញុំបាទ ឈ្មោះ នឹម អ៊ឹម ហៅ នឹម គឹមស្រ៊ាង។

**ស៖** លោកមានឈ្មោះហៅផ្សេងពីហ្នឹងទៀតទេ? សូមអញ្ជើញលោកមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអភ័យទោស ប៉ុន្តែ -- ឮសូរឆៗទៀតហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ពិនិត្យមើលឧបករណ៍ខាងភាសាបារាំង!

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*(មានបញ្ហាបច្ចេកទេស)*

*(សម្រាករយៈពេលខ្លី)*

[០៩:១៨:៤៥]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកសាក្សី តើលោកកើតនៅថ្ងៃណា ខែណា ឆ្នាំណាដែរ?

លោកសាក្សីមើលមីក្រូហ្វូន! មន្ត្រីរដ្ឋបាលតុលាការលើកមីក្រូហ្វូនឡើងបន្តិច ដើម្បីអង្គជំនុំជម្រះបានមើលឃើញភ្លើងក្រហមហ្នឹងផង ហើយនិងបានសម្រួលឲ្យគាត់ បានមើលឃើញខ្លួនឯងដែរ។

លោកសាក្សី លោកកើតនៅថ្ងៃណា ខែណា ឆ្នាំណាដែរ លោកចាំទេ?

**លោក នឹម អ៊ឹម៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** លោកសាក្សីកុំអាលទាន់ឆ្លើយ មីក្រូហ្វូនលោកអត់ទាន់ប្រតិបត្តិការទេ។ ភ្លើងក្រហមមិនទាន់ឆេះទេ។ ចាំដល់ភ្លើងក្រហមឆេះ នៅក្បាលមីក្រូហ្វូន អាហ្នឹងចាំលោកឆ្លើយ។

**ឆ៖** កើតនៅឆ្នាំ១៩៥៣។ ថ្ងៃខែ ខ្ញុំមិនបាននេះ អត់បានចាំ។

**ស៖** លោករស់នៅទីកន្លែងណាដែរ សព្វថ្ងៃ ហើយមានមុខរបរធ្វើអី?

**ឆ៖** រស់នៅភូមិព្រៃទទឹង ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្ដាល។ មុខរបរធ្វើស្រែចម្ការ និងនៅខាងសង្គមកិច្ច ខាងលក់ថ្នាំ ព្យាបាលរោគ។

**ចៅក្រម យូរ ឧត្តារ៖**

បារាំងឮសូរក្រឹកៗ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ពិនិត្យមើលឧបករណ៍ភាសាបារាំងទៀតហើយ អត់ដំណើរការ។

*(មានបញ្ហាបច្ចេកទេស)*

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២២:៣៧]

**ប្រធានអង្គជំនុំ៖**

ដោយសារផ្នែកបច្ចេកទេសត្រូវការរយៈពេល ២០នាទី ដូច្នេះនៅពេលនេះ អង្គជំនុំជម្រះប្រកាស

សម្រាក ២០នាទី ហើយចូលមកបន្តសវនាការវិញដោយមិនមានប្រកាសពេលសម្រាកទៀតទេ។

សូមអញ្ជើញៗ លោកមេធាវី នួន ជា!

[០៩:២២:៥៥]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណ ហើយសូមជម្រាបសួរលោកប្រធាន។ ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីធ្វើសំណើ។ ខ្ញុំដឹងថាគាត់ស្ដាប់ឮ ប៉ុន្តែគ្រាន់តែមិនច្បាស់ ឥឡូវមុននឹងយើងសម្រាក។ មុននឹងពេលដែលខ្ញុំសួរសាក្សីនេះ ខ្ញុំសូមធ្វើការកត់សម្គាល់ជាបឋមសិន ទាក់ទងទៅនឹងពេលវេលាដែលបែងចែកទៅឲ្យភាគី។ យើងគិតថា នេះជាសាក្សីដ៏សំខាន់មួយ ដែលនិយាយទាក់ទងទៅនឹងស-២១។ សាក្សីកន្លងមកដូចជា ហ៊ឹម ហ៊ុយ ឬក៏ សួស ធី គឺយើងទទួលបានពេលពីរថ្ងៃ ប៉ុន្តែសាក្សីរូបនេះគឺសំខាន់ដូចគ្នានឹងសាក្សីពីររូបកន្លងមកហ្នឹង។ ដូច្នេះខ្ញុំគិតថារយៈពេលមួយថ្ងៃ គឺខ្លីបន្តិចសម្រាប់ការសួរសាក្សីនេះ ហើយខ្ញុំគិតថា ព្រះរាជអាជ្ញាក៏ប្រហែលយល់ស្របជាមួយខ្ញុំដែរ។ ដូច្នេះ បន្ថែមទៅលើបញ្ហាបច្ចេកទេសដែលយើងកំពុងតែប្រឈមនេះទៀត ដូច្នេះខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះបន្ថែមពេលវេលាសាកសួរសាក្សីនេះតទៅទៀត។ ខ្ញុំគិតថា ហោចណាស់ក៏មួយថ្ងៃកន្លះ ឬក៏ប្រសិនបើបាន ពីរថ្ងៃរឹតតែល្អ វាអាស្រ័យទៅលើថាតើដំណើរការវាបន្តទៅយ៉ាងដូចម្តេច។ ដូច្នេះ ខ្ញុំសូមអនុញ្ញាត ថាហោចណាស់ក៏សូមបន្តទៅដល់ព្រឹកថ្ងៃស្អែកសម្រាប់មួយភាគីៗផងដែរ។

[០៩:២៤:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគ្រាន់តែចង់គូសបញ្ជាក់ថា កាណាល់បារាំងហ្នឹងឮសំឡេងល្អវិញហើយ លែងមានសំឡេងឆៗទៀតហើយ។ ខ្ញុំមិនដឹងថាភាគីផ្សេងទៀតហ្នឹងដែលស្ដាប់ជាភាសាខ្មែរហ្នឹងមានបញ្ហាដែរឬអត់ទេ ស្ដាប់ជាភាសាផ្សេងទៀតមានបញ្ហាអត់ទេ?

អ៊ីចឹងឥឡូវខ្ញុំឃើញថាដូចជាមិនចាំបាច់សម្រាក២០នាទីអីទៀតទេ ពីព្រោះថាបញ្ហាបច្ចេកទេសនេះត្រូវបានដោះស្រាយរួចរាល់ហើយ។

**ប្រធានអង្គជំនុំ៖**

ឧបករណ៍ដំណើរការល្អឡើងវិញហើយ ដូច្នេះ អង្គជំនុំជម្រះបន្តសវនាការបន្តទៀត។ ចំពោះសំណូមពររបស់សំណើរបស់មេធាវីលោក នួន ជា អង្គជំនុំជម្រះនឹងសម្រេចបញ្ជាក់តាមភាពជាក់ស្ដែង។

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ខ្ញុំសូមលើកមតិបន្ថិច ខ្ញុំមិនយល់ស្របជាមួយមេធាវីការពារក្ដី នួន ជា ដែលថាសាក្សីនេះសំខាន់ដូច ហ៊ឹម ហ៊ុយ ឬក៏ សួស ធី នោះទេ ដែលតម្រូវឲ្យមានពេលពីរថ្ងៃនោះឡើយ។ ខ្ញុំគិតថាវាច្បាស់ណាស់ថាតាមរយៈការអានកំណត់ហេតុស្ដាប់ចម្លើយ គឺគាត់មានការចាំតិចតួច ហើយមានបញ្ហាខ្លះផងក្នុងការចាំ។ ដូច្នេះ ដោយសារមេធាវីការពារក្ដីគិតថាសំខាន់ ដូច្នេះខ្ញុំមិនជំទាស់ទេប្រសិនបើអង្គជំនុំជម្រះសម្រេចផ្ដល់ពេលបន្ថែមមួយវគ្គ ប៉ុន្តែខ្ញុំគិតថាមិនគួរដល់ពេលពីរថ្ងៃនោះទេ។ ប៉ុន្តែប្រសិនបើអង្គជំនុំជម្រះសម្រេចយ៉ាងដូចម្ដេច ក៏ខាងព្រះរាជអាជ្ញាមិនមានអ្វីជំទាស់បន្ថែមដែរ។

[០៩:២៦:៥០]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកសាក្សីតើឪពុកម្ដាយបង្កើតរបស់លោកឈ្មោះអីដែរ?

**លោក នឹម អ៊ុំ៖**

**ឆ៖** ឪពុកខ្ញុំបាទឈ្មោះ ឌឹក អ៊ីនឹម ម្ដាយឈ្មោះ រស់ ឌៀប។ នៅភូមិ--

**ស៖** អរគុណលោកសាក្សី។ ចុះប្រពន្ធលោកឈ្មោះអី ឈ្មោះអ្វីដែរ ហើយមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ ភុំ វ៉ាន មានកូនបួននាក់ ប្រុសពីរ ស្រីពីរ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ពេលដែលយើងផ្ដល់វេទិកាទៅសាក្សីហើយហ្នឹង ក៏សំឡេងហ្នឹងមកឆៗវិញហើយ។ អ៊ីចឹងវាមានបញ្ហាបច្ចេកទេសមែនទែនហើយ។ អ៊ីចឹងត្រូវដោះស្រាយបញ្ហានេះសិន។

*(មានបញ្ហាបច្ចេកទេស)*

[០៩:៣៣:១៦]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកសាក្សី តាមរបាយការណ៍របស់ក្រឡាបញ្ជីបានបញ្ជាក់ថា តាមសមត្ថភាព និងលទ្ធ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបលោក នួន ជា និង លោក ខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០២ នេះទេ។ តើពិតមែនដែរទេ?

**លោក នឹម អ៊ុម៖**

**ឆ៖** ខ្ញុំបាទពិតប្រាកដមែន ហើយគ្មានជាប់ញាតិ -- សាច់ញាតិជាមួយលោក ខៀវ សំផន លោក នួន ជា ហ្នឹងទេ គឺជាប្រជាជនសាមញ្ញសុទ្ធសាធ។ ក៏ខ្ញុំគ្មានដែលជួប ដែលស្គាល់ទេ អ្នកទាំងពីរនោះ។

**ស៖** អរគុណលោកសាក្សី។ ហើយថា លោកបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែក មុននឹងចូលមកនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ។ តើពិតជាអ៊ីចឹងមែនទេ?

**ឆ៖** មុននឹងបង្ហាញ -- ធ្វើជាសាក្សី ខ្ញុំទៅស្បថមុខលោកដំបងដែក ពិតប្រាកដមែន។

**ស៖** អរគុណលោកសាក្សី។ ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោកក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការដែលឲ្យលោកធ្វើអត្ថាធិប្បាយមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យលោកចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរបស់លោករួចអម្បាញ់មិញនេះ។ ក្នុងឋានៈជាសាក្សី លោកត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយ ដែលពាក់ព័ន្ធនឹងសំណួរដែលភាគីសួរចំពោះលោក។

លោកសាក្សី តើលោកបានផ្តល់សក្ខីកម្ម ឬបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេកន្លងមក? ហើយប្រសិនបានធ្វើ ធ្វើប៉ុន្មានដង ហើយធ្វើនៅទីកន្លែងណា?

**ឆ៖** បាទ ខ្ញុំបាទធ្លាប់បានធ្វើការសម្ភាសជាមួយអ្នកស៊ើបអង្កេតការងារកាត់ទោសខ្មែរក្រហម

ហ្នឹង គឺខ្ញុំមកកន្លែងហ្នឹងបានម្តងដែរ។

[០៩:៣៦:២៣]

**ស៖** បាទ អរគុណ។ ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្តល់ចម្លើយកាលពីពេលមុន ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សុំអភ័យទោសលោកប្រធាន។ អ្នកស្តាប់ជាភាសាបារាំងហ្នឹង ចម្លើយចុងក្រោយអម្បាញ់មិញហ្នឹងគឺស្តាប់អត់បានទេ គឺបញ្ហាបច្ចេកទេសហ្នឹងកើតឡើងមានទៀតហើយ។ ខ្ញុំមិនដឹងថា កើតមានរហូតឬក៏ម្តងម្កាលទេ ឬក៏មក បញ្ហាមកពីមីក្រូហ្វូនរបស់អ្នកបកប្រែ ឬក៏យ៉ាងណាទេ។ ក៏ប៉ុន្តែចម្លើយចុងក្រោយរបស់គាត់ហ្នឹង ខ្ញុំស្តាប់អត់បានទេ លោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៧:៥១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសាកល្បងបន្តបន្តិច។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរគុណលោកសាក្សី។ ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្តល់ចម្លើយកាលពីពេលមុន ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំរបស់ដែរឬទេ?

**លោក នឹម អ៊ឹម៖**

**ឆ៖** ខ្ញុំបានអានរំឭកនេះ ការឆ្លងកាត់របស់យើងខ្ញុំគឺមិនអាចភ្លេចបានដាច់ខាត។

**ស៖** អរគុណលោកសាក្សី។ ហើយតាមសមត្ថភាពដែលអាចដឹង តើលោកអាចបញ្ជាក់បានទេថា កំណត់ហេតុដែលស្តាប់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំហ្នឹង គឺវាពិតត្រឹមត្រូវ វាស៊ីចង្វាក់គ្នាស្របនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុនដែរឬទេ?

[០៩:៣៩:០៨]

**ឆ៖** ព្រោះខ្ញុំបានអាន ហើយនិងបានឆ្លើយកាលពីមុន ការឆ្លងកាត់ និងដំណើរការទាំងនៅក្នុងជាងថតស-២១នោះ គឺខ្ញុំដឹងបានច្បាស់។ អត់មានថា អូ ! ឆ្លើយនូវរវាងវង្វេង បំភាន់ការពិត គ្មាន។

**ស៖** អរគុណលោកសាក្សី។ ក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិ៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា សួរដេញដោលសាក្សី នឹម អ៊ីម នេះ មុនភាគីដទៃទៀតនៃរឿងក្តី ហើយមេធាវីការពារក្តីលោក នួន ជា រួមជាមួយមេធាវីការពារក្តីលោក ខៀវ សំផន មានរយៈពេលពីរវគ្គ។

សូមអញ្ជើញលោកមេធាវីការពាក្តីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណាសួស្តីលោកសាក្សី ខ្ញុំឈ្មោះ វ៉ិចទ័រ កូប៉េ ជាមេធាវីអន្តរជាតិ ការពារលោក នួន ជា។ ខ្ញុំមានសំណួរមួយចំនួន សួរទៅកាន់លោកនៅថ្ងៃនេះ អំពីតួនាទីរបស់លោកក្នុងឋានៈជាប្រធានអង្គភាពថតរូបនៅស-២១។ ប៉ុន្តែមុននឹងចូលដល់ចំណុចនេះ ខ្ញុំសូមសួរសំណួរបឋមមួយចំនួនជាមុនសិន។ ចំណុចមួយដែលខ្ញុំទើបតែបានកត់សម្គាល់នោះគឺថា មិនមានមេធាវីប្រឹក្សាអង្គុយក្បែរលោកទេ។ គឺមានន័យថា មេធាវីដែលប្រាប់ទៅលោក អំពីសិទ្ធិដែលលោកត្រូវរក្សាភាពស្ងៀមស្ងាត់មិនឆ្លើយតបទៅនឹងសំណួរណាមួយ។ តើលោកមានទទួលបានឱកាសប្រាប់ថា លោកមានសិទ្ធិទទួលបានមេធាវីប្រឹក្សានេះដែរឬទេ?

[០៩:៤១:០៧]

**លោក នឹម អ៊ីម៖**

**ឆ៖** ខ្ញុំអត់បានទទួលផង។ ខ្ញុំអត់ដឹង។

**ស៖** លោកប្រធាន ខ្ញុំបានចូលទៅពិនិត្យមើលប្រតិចារឹកស្តីពីស-២១ ពីបុគ្គលិកស-២១ នោះ គឺសក្ខីកម្មរបស់គាត់ ខ្ញុំបានកត់សម្គាល់ឃើញថា ទាំង ហ៊ឹម ហ៊ុយ, ទាំង សួស ធី, ទាំង តយ តេង ពួកគាត់ទាំងបីនេះបានទទួលមេធាវីប្រឹក្សា ហើយសាក្សីរូបនេះគឺជាប្រធានអង្គភាពថតរូប។ អ៊ីចឹងខ្ញុំមិនដឹង

01382273



ថាមានអ្វីកើតឡើងដែលគាត់មិនមានមេធាវីប្រឹក្សា។ លោកសាក្សី ខ្ញុំបានឃើញកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺថាលោកត្រូវបានគេដាក់ពន្ធនាគារ ១០ឆ្នាំចន្លោះពីឆ្នាំ១៩៩៦ ដល់ ២០០៦។ តើត្រឹមត្រូវទេ ដែលថាលោកត្រូវបានជាប់ពន្ធនាគារ១០ឆ្នាំ?

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** តើការឃុំឃាំងខ្លួននៅពន្ធនាគារ ដោយសារតែលោកមានតួនាទីនៅឯស-២១ ឬក៏ដោយ-សារតែបទល្មើសផ្សេង?

**ឆ៖** មិនមែនតួនាទីខាងស-២១។ ពេលនោះគេដេញវ៉ៃខ្ញុំបាទ ដល់ពេល *(ឮមិនច្បាស់)* បានបីសា ហើយក៏នៅតែតាម ទាល់ច្រកដាក់បណ្តោយទៅ។

[០៩:៤២:៥៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានបានទទួលចម្លើយពីសាក្សីទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន បានទទួលចម្លើយហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ចុះខាងអ្នកស្តាប់ កាណាល់បារាំង ឮសួរដែរទេ?

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ឮ។ តើការជាប់គុក ១០ឆ្នាំនេះ មូលហេតុអីបានជាលោកជាប់ពន្ធនាគារដល់ទៅ ១០ឆ្នាំនេះ?

**លោក នឹម អ៊ុំ៖**

**ឆ៖** កាលខ្ញុំជាប់គុក កាលជំនាន់ហ្នឹង គឺពេលកាលនោះ ខ្ញុំជួយយកអាសារគេ ដល់ហើយគេបែរមកខឹងខ្ញុំ ដេញវ៉ៃខ្ញុំ ដល់ហើយខ្ញុំក៏ចាប់ដំបងបានបីសា។ នឹកឃើញថា ខ្ញុំអត់តទេ ព្រោះនឹកឃើញថាយើងជួយគេ។ ដល់ពេលអាអ្នកដែល គ្រួសារខ្ញុំជួយហ្នឹង គឺស្ទុះមកវ៉ៃខ្ញុំ។ ខ្ញុំចាប់បានបីសា ហើយបោះចោលបីសា វាតាមមកទៀត។ ចុងក្រោយខ្ញុំថាទ័លច្រកហើយ វាអស់មានកន្លែងរត់ហើយ ក៏ខ្ញុំវ៉ៃបំបាក់ដៃ មិនបាក់ដៃ លេងចំកញ្ចឹងកបណ្តោយ។ អស់ហើយ។

**ស៖** តើក្រោយឆ្នាំ១៩៧៩ គេមានដាក់ពន្ធនាគារលោក ដោយសារតែលោកជាប់តួនាទីជា

ប្រធានថតរូបនៅ ស-២១ ទេ?

[០៩:៤៥:០០]

**ឆ៖** អត់មានដាក់ទេ ព្រោះខ្ញុំចុះមក គឺមកដល់ គឺអត់មានអ្នកណាដឹងថាខ្ញុំជាជាងថតស-២១ ទេ។ ព្រោះខ្ញុំប្រែឈ្មោះខ្ញុំពី នឹម អ៊ុម -- ពី នឹម គឹមស្រ៊ាង មក នឹម អ៊ុម វិញ ពេលចូលដល់ស្រុក។

**ស៖** សូមអរគុណ។ លោកសាក្សី ខ្ញុំសូមសួរសំណួរមួយចំនួន ថាតើលោកធ្វើអ្វីដែរ មុនរំដោះទីក្រុងភ្នំពេញ នៅថ្ងៃ១៧ មេសា ១៩៧៥។ <ខ្ញុំចង់សង្ខេបជូនលោក ដើម្បីឲ្យ>វាបានលឿនបន្តិច។ តើត្រឹមត្រូវដែរឬទេ ដែលថានៅមុនឆ្នាំ១៩៧៥ លោកគឺជាសមាជិកកងពល៧០៣ ហើយជាកងទ័ព៧០៣ ដែលបញ្ជាដោយ តាណាត។ គឺលោកនៅក្នុងកងវរសេនាតូច១១៦ ហើយលោកហ្នឹងគឺជាអនុប្រធានក្រុម ហើយនៅពេលមួយនោះ លោកត្រូវរបួស។ នៅពេលនោះ កងពលនោះ គឺហៅជាកងពល១២នៅឡើយទេ។ ហើយគឺ តាណាត នេះឯង ដែលបញ្ជូនលោកឲ្យទៅរៀនស្ទូត្រ ដើម្បីក្លាយទៅជាអ្នកថតរូប អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដមែនហើយ ព្រោះតាណាត គាត់ជាអ្នកបញ្ជូនតាមរយ: តាមលោកតា ស្រីមឿន ហៅ វិត។

**ស៖** ចុះហេតុអ្វីជា តាណាត ស្នើសុំឲ្យលោកទៅរៀនស្ទូត្រ ដើម្បីឲ្យក្លាយទៅជាអ្នកថតរូប? <>មូលហេតុអី<បានជាលោកត្រូវរៀនថតរូប>?

**ឆ៖** មូលហេតុកាលហ្នឹង គឺខ្ញុំត្រូវរបួស សើរើរបួសបាន ឆ្នាំ ថ្ងៃចំអាថ្ងៃបែកភ្នំពេញហ្នឹង ខ្ញុំចេញពីមន្ទីរពេទ្យមក បានជួប ស្រីមឿន។ ស្រីមឿន ក៏យកខ្ញុំមកបញ្ជូនមកឲ្យនៅជាមួយ តាណាត ឲ្យមកធ្វើជាងថតហ្នឹងតែម្តង។

[០៩:៤៧:៥១]

**ស៖** តើត្រឹមត្រូវដែរឬទេ ដែលថាមិនមែនតែលោកម្នាក់ឯងទេ គឺមានអ្នកដទៃទៀត មកពីកងពល៧០៣ ក៏ត្រូវបានគេស្នើសុំឲ្យទៅធ្វើជាអ្នកថតរូបដែរ។ អ៊ីចឹង សរុបទៅគឺថាក្រុមថតរូបរបស់លោកហ្នឹង វាមានគ្នាដល់ទៅប្រាំមួយនាក់?

**ឆ៖** ប្រាំមួយនាក់ពិតមែន គ្រាន់តែថា៧០៣ហ្នឹង គឺបីនាក់គេទៅរៀននៅចិន។ បីនាក់ទុកនៅកន្លែង។ ចំពោះខ្ញុំអ្នកចេះអក្សរ គេឲ្យទុកមួយកន្លែង។ អ្នកអត់ចេះអក្សរ គេឲ្យទៅរៀននៅចិន។ ដល់ពេលត្រឡប់មកវិញ បានពួកនៅក្រុមថតហ្នឹងរត់ទៅថៃ។ អស់គ្នា -- នៅនឹងថៃអស់ម្នាក់ យកពួកជាង

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឡានទៅពីរ -- បីនាក់ -- ពីរនាក់ទៀត។ ពេលនោះ ខ្ញុំភ័យអាសន្នមែនទែននោះ រកយកខោ ខោអាវខ្ញុំ កាំភ្លើងខ្ញុំ មួកខ្ញុំ លិខិតខ្ញុំអស់រលីង យកទៅ រត់ទៅថៃ។ ដល់ហើយ គេបង្កើត គេបញ្ជូនខ្ញុំ ម៉ាថ្ងៃផ្លាស់បីដង។ ហើយចូលកៀកគុកមែនទែន ភ័យមែនទែន ខ្ញុំអង្កាល់នោះ។ ខ្ញុំអស់យោបល់ហើយ។

**ស៖** តើត្រឹមត្រូវដែរឬទេ បីនាក់ដែលឲ្យនៅនឹងកន្លែងដើម្បីរៀនថតរូបហ្នឹង គឺមានរូបលោកម្នាក់ ស្រ៊ុន សុង និង កង និត គឺបីនាក់ហ្នឹង ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពិតត្រឹមត្រូវមែន។

**ស៖** ហើយតើត្រឹមត្រូវដែរឬទេ ក្នុងចំណោមបីនាក់ដែលគេទុកឲ្យនៅកន្លែង រៀនថតរូបនៅកន្លែងហ្នឹង គឺលោក គឺជាប្រធានក្រុម។ លោកជាអ្នកក្តោបក្តាប់ ស្រ៊ុន សុង ហើយនិង កង និត។ ត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំជាមេពួក គេមិនឲ្យហៅក្រុម ហៅមេពួកវិញ បីនាក់ហ្នឹង។

[០៩:៥០:០៦]

**ស៖** តើលោកនៅនឹកឃើញទេ<នៅពេលណា> តាណាត បានបញ្ជូនលោក ស្រ៊ុន សុង និង កង និត ទៅ ស-២១?

**ឆ៖** ព្រោះអង្កាល់ហ្នឹង តាណាត គាត់បើកអាឡង់គ្រីស័រ អាស្ទីររបស់អាមេរិក ឡាននេះ ឡានអ្នកធំគេជិះ ឌុបខ្ញុំ បីនាក់យកមកចូលកន្លែង ស-២១។

**ស៖** នៅពេលដែលលោកនិយាយពីស-២១ តើលោកនិយាយអំពីបរិវេណដែលសព្វថ្ងៃនេះគេហៅថា "សារមន្ទីរទួលស្លែង" ហ្នឹងឬ?

**ឆ៖** បាទ សារមន្ទីរទួលស្លែងសព្វថ្ងៃហ្នឹង។

**ស៖** តើលោក ស្រ៊ុន សុង និង កង និត ស្នាក់នៅស-២១ ដើម្បីធ្វើការជាអ្នកថតរូបចាប់តាំងពីដើមដំបូងមក គឺចាប់តាំងពីខែមេសា ឧសភា ១៩៧៦ មកឬ?

**ឆ៖** បាទ ចាប់តាំងពី១៩៧៦ មក។

**ស៖** តើពួកលោកទាំងបីនាក់ហ្នឹងធ្វើការនៅស-២១ រហូតដល់ចុងបញ្ចប់គឺដល់ខែមករា ១៩៧៩ មែនទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺឯកសារលេខ គឺE3/7639, ERN ជា

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ភាសាអង់គ្លេស 00162733, ខ្មែរ 00162709, បារាំង 00338076 និងទំព័របន្ទាប់ផងដែរ លោកបាននិយាយថា “មានតែពួកលោកបីនាក់ទេដែលធ្វើការជាអ្នកថតរូប ហើយមិនមានអ្នកថតរូបណាផ្សេងទៀតទេនៅស-២១ នោះនៅពេលដែលពួកលោកទាំងបីនាក់ទៅដល់<ជាលើកដំបូង> គឺគ្មានអ្នកថតរូបផ្សេងក្រៅពីពួកលោកទេ។ ត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[០៩:៥៣:១២]

**ស៖** ឥឡូវ ខ្ញុំសូមសួរអំពីមនុស្សម្នាក់ដែលលោកបានលើកឈ្មោះ លោកនិយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺលោកហៅថា “អេនតូច” – ញ៉ែម អេន។ លោកមាននៅចាំទេ កុមារាម្នាក់ឈ្មោះ ញ៉ែម អេន ឬក៏ហៅថា អាអេនតូច លោកនៅចាំទេ?

**ឆ៖** បាទ ពេលនោះចាំ ព្រោះ ញ៉ែម អេន ហ្នឹងតូចណាស់ ព្រោះគ្រាន់តែចាប់បញ្ជូនក្មេងឲ្យចូលមកកន្លែងខ្ញុំហ្នឹង ខ្ញុំដឹងខ្លួនហើយស្រេចហើយ ព្រោះខ្ញុំចោលភ្នែកឃើញ គាណាត អ្នកនាំចូលមកហ្នឹងជាប់គុក ប្អូនខ្ញុំក៏នៅហ្នឹង អ្នកជិតខាងខ្ញុំនៅហ្នឹង ក្រឡេកឃើញដឹងខ្លួនហើយស្រេច។ ដឹងខ្លួន បើបង្រៀនវាឲ្យចេះ គឺងាប់បណ្តោយ។ ព្រោះជំនាន់នេះអត់ប៉ានចេះ អ្នកចាស់បណ្តុះអ្នកថ្មីបាន គឺងាប់ហើយ ងាប់អ្នកចាស់ហើយ។ បាទ ខ្ញុំអត់ប៉ានបង្រៀនឲ្យចេះ គ្រាន់តែឲ្យចេះតែថតទេ រឿងលាយថ្នាំ បិទផ្តិតរូបអីមិនទាន់ចេះទេ ញ៉ែម អេន ហ្នឹង។ អ៊ីចឹងបានថា ក្នុងរយៈកាលហ្នឹងគ្រាន់តែចូល ញ៉ែម អេន ហើយពីរនាក់ខ្ញុំអត់ ភ្លេចឈ្មោះហើយ គ្រាន់តែចូលទៅ ខ្ញុំប្រាប់គ្នាខ្ញុំថាកុំ ហាមផ្តាច់កុំឲ្យរៀនចេះសោះ ចេះតែថតបានហើយ។ ដល់ហើយបានដំណាក់កាលនោះ បែកទៅ បានខ្ញុំរួចខ្លួនបណ្តោយនេះ។

[០៩:៥៤:៤៣]

**ស៖** មុនពេលខ្ញុំសួរសំណួរមួយចំនួនអំពី ញ៉ែម អេន លោកប្រធានសូមការអនុញ្ញាតបង្ហាញសាក្សីនូវឯកសារពីរ ឯកសារទី១ គឺឯកសារ E3/10600 គឺ10600 ជារូបថតរបស់ ញ៉ែម អេន និងសៀវភៅមួយក្បាលរបស់ ញ៉ែម អេន ដែលមាននៅក្នុង -- ដែលត្រូវបានទទួលដាក់នៅក្នុងសំណុំរឿង។ ដូច្នេះ បើអង្គជំនុំជម្រះអនុញ្ញាត សូមប្រគល់ឯកសារទាំងពីរនេះទៅឲ្យសាក្សីពិនិត្យមើល។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

មន្ត្រីរដ្ឋបាលតុលាការយកឯកសារទាំងពីរនេះយកទៅជូនសាក្សីពិនិត្យមើល!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី ដើម្បីប្រតិចារឹកសូមបញ្ជាក់ផង ប្រាប់លេខ ERN ផង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ លោកស្រីចៅក្រមខ្ញុំនឹងផ្តល់ជូន។ ដំបូងខ្ញុំឲ្យឯកសារនេះទៅឲ្យសាក្សីមើលសិន។ ឥឡូវនេះខ្ញុំមាន ERN ហើយអង់គ្លេស 00162874 ជាឧបសម្ព័ន្ធ(ក)។ គឺឯកសារមួយនេះឯងជាឧបសម្ព័ន្ធ(ក)។ ERN សម្រាប់សៀវភៅរបស់គាត់នៅទំព័រដំបូងខ្ញុំនឹងផ្តល់ពេលក្រោយ។ លោកសាក្សី តើរូបថតពេលនេះគឺជារូបថត ញ៉ែម អេន ដែលយើងកំពុងនិយាយគ្នានេះមែនទេ?

**លោក នឹម អ៊ីម៖**

**ឆ៖** ញ៉ែម អេន កាលហ្នឹងនៅក្មេងណាស់។ ពិត ញ៉ែម អេន ហើយ ប៉ុន្តែចាក់ខ្សែខាងក្រៅ អត់ដែលជួបគ្នាសោះ ឮសួរតាមដែលសំឡេង ទៅតាមអាស៊ីសេរីទេ អាមេរិកាំងទេ។ ព្រោះខ្ញុំដាក់មកមិនដែលជួបគ្នាសុទ្ធ។

[០៩:៥៦:៥៣]

**ស៖** តើលោកនៅនឹកឃើញទេថានៅពេល<ណាដែល> ញ៉ែម អេន បានមកជួយធ្វើការលោក ឬក៏រៀនថតរូបជាមួយនឹងពួកលោក ដែលពួកលោកជាអ្នកគ្រប់គ្រងហ្នឹង <នៅពេលណាខណៈដែល> លោក<នៅស-២១នោះ?> តើនៅពេលណាដែលលោកចាប់ ផ្តើមបង្រៀន ញ៉ែម អេន ឲ្យរៀនថតរូបនេះ?

**ឆ៖** ចាប់ពីពេលដែលប្អូនខ្ញុំគេដកពីៗអង្គរក្សការពារទៅធ្វើបន្លែៗ ខ្ញុំដឹងខ្លួនហើយស្រេច ព្រោះចំពេលហ្នឹង ញ៉ែម អេន ចូលបញ្ជូនមកឲ្យខ្ញុំ គ្នាខ្ញុំរៀបបង្រៀនហ្នឹងណា ញ៉ែម អេន កាលហ្នឹងមកបីនាក់ ប៉ុន្តែតូចៗទេ។ ដល់ហើយបាន -- ប៉ុន្តែរៀនតែថ្ងៃ យប់ទៅដេកកន្លែងគេវិញ។ មានខ្ញុំបីនាក់នៅកន្លែងផ្តិតរូបថតហ្នឹង។

**ស៖** ប៉ុន្តែលោកដឹងទេនៅកន្លែងណាដែរ ដែល ញ៉ែម អេន និងពីរនាក់ផ្សេងទៀតនោះបានចូលមករួមក្រុមជាមួយលោកដើម្បីរៀនថតរូបនោះ?

**ឆ៖** ព្រោះពេលហ្នឹងខ្ញុំអត់ដឹង អត់ដឹង ព្រោះថាការងារកន្លែងណា គឺឈរជើងកន្លែងហ្នឹង អត់មានឆ្វេងឆ្វាចកាលជំនាន់ហ្នឹង។ តែមិនដឹងពីណាមកណាទេពេលហ្នឹង ព្រោះដឹងថា តាឌុច បញ្ជូនមកហើយ។

**ស៖** បាទ ខ្ញុំព្យាយាមសាកល្បងជួយរំឭកដល់ការចងចាំរបស់លោកបន្តិចមើល។ ព្រោះវាយូរយារណាស់ហើយ។ លោកបានឆ្លើយជាច្រើនដងរួចមកហើយ បើខ្ញុំចាំចម្លើយលោកមិនច្រឡំទេនោះ លោកថា ញ៉ែម អេន បានចូលមកស-២១ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ឬក៏ថាចុង១៩៧៨ក៏ថាបាន។ គឺប្រាំមួយខែមុននឹងការដួលរលំទីក្រុងភ្នំពេញ គឺម៉ុពេលវេលាដែលគេចាប់ខ្លួន ណាត តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពិតត្រឹមត្រូវ។

**ស៖** ដូច្នេះ នៅពេល ញ៉ែម អេន មកជួបលោកដើម្បីរៀនថតរូប តើ ញ៉ែម អេន នេះមានចំណេះដឹងពីរបៀបផ្តិតរូបថត ឬក៏ថតរូប<ហើយនៅ? តើគាត់ដឹងពីរបៀបប្រើម៉ាស៊ីនថតរូបទេ? តើគាត់ចេះរបៀបផ្តិតរូបទេ? តើគាត់ដឹងពីរបៀបធ្វើរូបថតទេ> ឬថាគាត់ត្រូវមកហ្នឹង គឺថាមករៀនចាប់ពី១ដំបូងឡើយ គឺមករៀនថតរូបថ្មីថ្មោងសុទ្ធ?

[០៩:៥៩:៥៨]

**ឆ៖** កាលហ្នឹង ញ៉ែម អេន មកដល់ភ្លាម អត់ទាន់ចេះអីទាំងអស់។ ប៉ុន្តែខ្ញុំបានបង្រៀនចេះថតទេ តែរឿងលាយថ្នាំ លាយ លាងហ្វីល លាង ផ្តិតរូបថតអី ខ្ញុំអត់ទាន់ប៉ានបង្រៀនឲ្យចេះទេ ព្រោះខ្ញុំពន្យារពេលបន្តិច ព្រោះថាមើលទៅបើឲ្យរៀនមួយមុខម្តង ទាំងអស់ហ្នុងសរុប នាំក្មេងវាចាប់អត់បានរៀនឲ្យតែចេះថតមួយមុខសិន។

**ស៖** តើត្រឹមត្រូវដែរឬទេ បើខ្ញុំនិយាយថា នៅពេលដែលលោកជួប ញ៉ែម អេន ជាលើកដំបូងនៅឯមន្ទីរសន្តិសុខស-២១ គឺថា ញ៉ែម អេន នេះគឺគាត់គ្មានដឹងអីសោះអំពីរបៀបថតរូបនេះ គឺអត់ចេះសោះតែម្តង។ ខ្ញុំថាអ៊ីចឹងត្រឹមត្រូវទេ?

**ប្រធានអង្គជំនុំ៖**

សុំអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

យើងខ្ញុំយល់ថា នេះជាសំណួរនាំមុខហើយ។ សាក្សីបានឆ្លើយរួចមកហើយតាមការចងចាំរបស់គាត់ គឺថា<យ៉ាងហោចណាស់មិនស៊ីសង្វាក់គ្នានឹងភ័ស្តុតាងជាច្រើន>។ ទោះជាយ៉ាងនេះក៏ដោយមេធាវីការពារក្តីមិនគួរណាសួរសំណួរនាំមុខដោយបញ្ចូលពាក្យសម្តីមកចូលនៅ មកឲ្យសាក្សីអ៊ីចឹងទេ។

[១០:០១:២៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** មិនបញ្ហាអីទេ ខ្ញុំសួរតាមរបៀបផ្សេងវិញ។ នៅពេលដែលលោកជួប ញ៉ៃម អេន ជាលើកដំបូង តើគាត់មានបង្ហាញថាគាត់មានការចេះដឹងអ្វីខ្លះពីរបៀបថតរូបដែរឬទេ? តើគាត់មានបានប្រាប់លោកថាគាត់រៀនថតរូបហ្នឹងនៅឯណាដែរឬទេ? តើគាត់មានប្រាប់ថាគាត់ធ្លាប់បានទៅរៀននៅឯប្រទេសចិន ឬក៏ធ្លាប់រៀនថតរូបនៅពេលដែលមេធាវីប្រតិភូ -- នៅពេលប្រតិភូចិនមកធ្វើទស្សនកិច្ចនៅតាមបណ្ដា មកទំនប់ផ្សេងៗនោះណ៎ា។ គាត់មានប្រាប់អីចឹងទេ?

**លោក នឹម អ៊ឹម៖**

**ឆ៖** បើនិយាយពីរឿងថា ញ៉ៃម អេន នេះបើគាត់ថាគាត់បានរៀនចិន បើតាមខ្ញុំមើលសម្គាល់គាត់ចូលមកភ្លាម គឺថា សូម្បីដាក់ហ្វីលថត ក៏ដាក់អត់ត្រូវដែរ។ ហើយគាត់អួតខ្លួនគាត់ ខ្ញុំស្ដាប់ប៉ុស្តិ៍អាស៊ីសេរីផ្សាយថាគាត់ថា ញ៉ៃម អេន គាត់រៀនពីចិន! ទៅរៀនពីចិនឯណា បើពួកគ្នាខ្ញុំបីនាក់ទៅ គេថាគ្មានក្មេងៗផងហ្នឹង។ យកគ្រប់កងពលទាំងអស់ទៅរៀន មួយកងពលបីនាក់ៗ រៀនពីចិន។ ហើយដល់ញ៉ៃម អេន ចូលមកថារៀនដែរ អីចឹងមិនបាច់មករៀនពីខ្ញុំធ្វើអី! មិនមកដល់ថតផ្ដិតយកហ្នងទៅ ដកខ្ញុំចេញដាក់គុកទៅចប់ហើយកាលហ្នឹង។ ព្រោះថាខ្ញុំដឹងខ្លួនរិះនឹងងាប់ហើយ ព្រោះឃើញសញ្ញាផ្សំជុំវិញខ្លួនខ្ញុំ គេចាប់គុកចង់អស់ហើយហ្នឹង។ នៅតែ កាលហ្នឹងណាធ្វើនីរសារចំពួកខ្សែខ្មែរ ខ្សែរបស់អាមេរិកាំងសុទ្ធតែងាប់ហើយ បើរបស់យួន អត់ងាប់ទេ។ សួរខ្ញុំទៅ។ ខ្ញុំតាមដានច្បាស់ណាស់ជំនាន់នោះ។ មកដល់ទៀត ស្រីមឿន កុំបានទៅស្គាល់ខ្សែយួន កុំអីខ្ញុំងាប់ដែរហ្នឹង។

[១០:០៣:៣៥]

**ស៖** បាទ សូមបញ្ចប់ជាមួយនឹង ញ៉ៃម អេន ទៅចុះលោកសាក្សី។ ឥឡូវខ្ញុំសុំអាននូវអ្វីដែលគាត់បានឆ្លើយជាមួយនឹងជនជាតិអាមេរិកាំងម្នាក់ឈ្មោះ ដាក ណេវិន, ភីតធ័រ ម៉ាខ្វៃអ៊័រ គឺឯកសារ E3/7495, ERN ជាភាសាអង់គ្លេស 00078256, ខ្មែរ 00826558, បារាំង 00795351។ នេះគឺជាសសម្ដីរបស់ ញ៉ៃម អេន។ គាត់និយាយថា សំណួរសួរថា៖ “អ្នកណាជាជំនួយការរបស់លោក? គាត់ឆ្លើយថា៖ ជំនួយការរបស់ខ្ញុំ រី, សំ, និត, សុង និង ស្រ៊ាង។” គឺលោកនេះជាជំនួយការ។ អីចឹងគាត់ឆ្លើយថាគាត់នេះគឺជាមេក្រុមថតរូប ហើយលោកហ្នឹងគឺជាជំនួយការរបស់គាត់ទេ។ ត្រឹមត្រូវដែរឬទេ?

[១០:០៤:៥១]

**ឆ៖** ចំពោះរឿង អេន និយាយអីចឹងវាបោក មិនបោកត្រឹមបុគ្គលម្នាក់ទេ ទូទាំងប្រទេសសកលលោកទៀតណោះ។ អាហ្នឹងវាអាការមិនពិត ធ្វើជាការពិត។ ខ្ញុំស្ដាយណាស់ដែលកូនចៅខ្ញុំវាបាត់ខ្លួននៅ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លើកំពូលភ្នំនេះ។ ទៅសួរ តាឌុច លោកដឹងហើយ។ ទៅសួរ តាឌុច អ្នកណាគ្រប់គ្រងហ្នឹង គាត់ដឹងច្បាស់ណាស់។

**សៈ** ត្រឹមត្រូវហើយលោក ឌុច បានបញ្ជាក់ថា ញ៉ែម អេន គ្មានតួនាទីអីទេនៅស-២១។ សួស ធី ថាមិនស្គាល់ ញ៉ែម អេន ទេ។ ឌុច បានឆ្លើយថា លោកជាមនុស្សទី១ ក្នុងក្រុមថតរូប ហើយ សុង គឺជាមនុស្សទី២។ តើត្រឹមត្រូវដែរទេថា ក្នុងក្រុមថតរូបនោះ លោកជាមនុស្សទី១, សុង ជាមនុស្សទី២?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹង មេធាវី អត់មានលើកសំអាងឯកសារណាយកមកបង្ហាញសិនទេ គឺយកពាក្យពេចន៍ហ្នឹងមកសួរ បញ្ចុកមាត់សាក្សីតែម្ដង។ ឌុច <មិន>បាន<បដិសេធថា> ញ៉ែម អេន <មានតួនាទីណាមួយនៅស-២១ទេ។ គាត់បានបញ្ជាក់ថា គាត់បានធ្វើ។ ហើយ ញ៉ែម អេន>មិនដែលបានឆ្លើយនៅក្នុងបន្ទប់សវនាការនេះថា គាត់ជាប្រធានទេ។ <នោះជាអ្វីដែលមាននៅក្នុងបទសម្ភាសន៍មួយ។> គាត់មិនដែលថាគាត់ជាប្រធានក្រុមថតរូបទេ<នៅក្នុងបន្ទប់សវនាការនេះ>។

[១០:០៦:២៩]

**លោក វ៉ិចទ័រ កូប៉េះ៖**

មិនជាអ្វីទេ។ ឥឡូវខ្ញុំយកសក្ខីកម្មរបស់ ឌុច ទាក់ទងទៅនឹង ស្រ៊ាង គឺសាក្សីចំពោះមុខយើង និង សុង។ នៅក្នុងឯកសារ <E3/7457> ចុះឆ្នាំ២០០៩ ខែកក្កដា <ថ្ងៃទី០៩> គឺសក្ខីកម្មនៅក្នុងសំណុំរឿង ០០១ គាត់បានឆ្លើយថា "ស្រ៊ាង គឺជាប្រធានក្រុមថតរូប ជាអ្នកត្រួតត្រាក្រុមថតរូប។" គាត់បានឆ្លើយនូវសក្ខីកម្មរបស់ថ្ងៃទី០៤ សីហា ឆ្នាំ២០០៩ E3/7468 "ប្រធានក្រុមថតរូបគឺ ឈ្មោះ នឹម គឹមស្រ៊ាង ហើយនិងសមមិត្តសុង ជាអ្នកថតរូបនៅឯព្រៃស"។ ហើយនៅក្នុងសក្ខីកម្មរបស់គាត់នៅថ្ងៃទី២៧ មេសា ២០០៩ នៅក្នុងឯកសារ E3/5793 ឌុច បានឆ្លើយថា "ប្រធានគឺ ស្រ៊ាង។ ខ្ញុំឲ្យ ស្រ៊ាង ថតរូបអ្នកទោសដែលទើបតែមកដល់។ សមមិត្តស្រ៊ាង ជា<អ្នកធ្វើផែនទីថតរូប> គឺគាត់ជាប្រធានក្រុម ហើយអនុប្រធានរបស់គាត់លេខ២ គឺ ឈ្មោះ សុង"។ ហើយខ្ញុំក៏កំពុងព្យាយាមរកចម្លើយ សួស ធី ដែលថាមិនស្គាល់ ញ៉ែម អេន នោះទេ។ ដូច្នេះ សំណួររបស់ខ្ញុំ លោកសាក្សី តើត្រឹមត្រូវដែរឬទេ ដែលថា ញ៉ែម អេន មិនមានតួនាទីអ្វីសំខាន់នៅក្នុងអង្គភាពថតរូបនោះទេ ត្រឹមត្រូវដែរឬទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:០៨:៣០]

**ឆ៖** ព្រោះពិតប្រាកដហើយ ញ៉ែម អេន ហ្នឹងគឺវាអត់មានតួនាទី វាគ្រាន់តែមករៀន។ ហើយដូច ធី ដែលអ្នកកត់ត្រាហ្នឹង គាត់ថាគាត់អត់ស្គាល់ ក៏ពិតប្រាកដមែន ព្រោះ ញ៉ែម អេន គ្មានសិទ្ធិចូលទៅកន្លែងហ្នឹងបាន កន្លែងដែលកត់ត្រាហ្នឹង។ ខ្ញុំមានសិទ្ធិតែចេញចូលកន្លែងថតផ្តិតហើយទៅវិញ។ អត់មានបានសិទ្ធិអីដើរឯណាផ្តេសផ្តាសទេ ជំនាន់នោះ គឺកន្លែងណា គឺនៅកន្លែងហ្នឹង។ ហើយដូច ធី ប្រាប់ហ្នឹងថា អត់ស្គាល់ ញ៉ែម អេន ខ្ញុំជឿជាក់ពិតប្រាកដ ព្រោះ ញ៉ែម អេន អត់មានបាននេះទេ អត់បាននៅនៅតែក្រៅហ្នឹង។

**ស៖** សូមអរគុណច្រើនលោកសាក្សី។ ឥឡូវខ្ញុំចូលទៅនិយាយអំពីភារកិច្ចរបស់លោកនៅស-២១។ តើលោកមានភារកិច្ចធ្វើអ្វីនៅពេលដែលលោកនៅឯស-២១ គឺថា នៅទីនោះជិតបីឆ្នាំ តើលោកមានភារកិច្ចធ្វើអ្វីដែរ?

**ឆ៖** គឺតួនាទីគោលធំ ដូចថាតួនាទីផ្តិតនិងថត ថតនិងផ្តិតរូបហ្នឹង គឺជួនកាលគេហៅចូលទៅផ្តិត អំ! ទៅថត គឺទៅថត ថតហើយចូលមកលាងហ្វីលផ្តិត។ តែប៉ុណ្ណឹងឯង។

**ស៖** ចុះលោកនៅនឹកឃើញទេ <កន្លែង>ដែលលោក សុង និង និត <រស់នៅ>នៅស-២១ លោកនឹកឃើញទេ?

**ឆ៖** ចេញទៅណា? ព្រោះ ចេញៗទាំងអស់ ពេលយួនវ៉ៃចូលហ្នឹង។ អត់មានអ្នកណាចេញណាទេ ជំនាន់ហ្នឹង។ បើចេញពេលខ្ញុំនៅ៧០៣ អាហ្នឹងបានៗមានគេរត់ចេញទៅថៃ។ កាលនៅជាងថត ៧០៣។

[១០:១១:០០]

**ស៖** សូមទោស ប្រហែលជាសំណួរខ្ញុំវាមិនច្បាស់លាស់។ ខ្ញុំសួរថា តើលោកនិងសមមិត្តលោកពីរនាក់ទៀត<រស់នៅកន្លែងណា ពេលដែលលោកធ្វើការនៅស-២១នោះ?> តើត្រឹមត្រូវដែរទេ ដែលថាក្នុងចំណោមលោកទាំងបីនាក់នេះ គឺរស់ ស្នាក់នៅក្នុងផ្ទះមួយ ជិតផ្ទះ ឌុច។ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពិតត្រឹមត្រូវហើយ ព្រោះគ្នាខ្ញុំដេកតែបីនាក់ទេ។ ធ្វើការតែបីនាក់ទេ។

**ស៖** ហើយនៅក្នុងផ្ទះមួយនេះ (ដោយរៀបឡើងវិញ) តើផ្ទះមួយនេះ ជាផ្ទះដែលលោក ហើយនិងសមមិត្តលោកពីរនាក់ទៀត ប្រើប្រាស់សម្រាប់ផ្តិតរូបថត ដែលបានថតនៅក្នុងបរិវេណស-២១នោះមែនទេ?

**ឆ៖** បាទ ផ្ទះដែលខ្ញុំរស់នៅនោះ គឺថត ផ្តិត -- ថតហើយ មកផ្តិតកន្លែងហ្នឹង លាងហ្វីលកន្លែងហ្នឹង គឺប្រចាំការរាល់ថ្ងៃ រាល់ខែហ្នុង។

**ស៖** លោកសាក្សី លោកបានបញ្ជាក់ថា ផ្ទះរបស់លោកហ្នឹងគឺស្ថិតនៅទិសពាយ័ព្យ ពីខាងផ្ទះ ឌុច ប្រហែលជា៥០ ទៅ៧០ម៉ែត្រ ចម្ងាយពីផ្ទះ ឌុច។

លោកប្រធាន សូមការអនុញ្ញាតបង្ហាញសាក្សីនូវឯកសារ E3/10603, ERN អង់គ្លេស 00210940។ នេះគឺជាផែនទី ទីក្រុងភ្នំពេញ នៅជុំវិញបរិវេណស-២១ <ហើយវាក៏មានផ្ទះនៅតាមខាងៗនោះដែរ>។ ដូច្នេះ យើងខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារនេះទៅឲ្យសាក្សីពិនិត្យមើល ហើយតើគាត់អាចបញ្ជាក់ ហើយស្គាល់ផ្ទះមួយ នៅលើផែនទីនេះដែរ ឬក៏អត់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី មានចង់ស្នើសុំដាក់បញ្ចាំងលើអេក្រង់ផងដែរទេ?

[១០:១៣:២៤]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមបញ្ចាំងនៅលើអេក្រង់ផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមមន្ត្រីសោតទស្សន៍បញ្ចាំងឯកសារនេះលើអេក្រង់ទូរទស្សន៍។ ហើយមន្ត្រីរដ្ឋបាលតុលាការ យកឯកសារនេះជូនទៅសាក្សី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី យើងមានគូសរង្វង់នៅផ្នែកខាងស្តាំនោះ នៅខាងស្តាំនៃអេក្រង់ មានផ្ទះបី។ វាអាចជាទីតាំងផ្ទះដែលលោកស្នាក់នៅដើម្បីផ្តិតរូបថត។ តើលោកមាននៅចាំផ្ទះណាមួយ ក្នុងចំណោមផ្ទះទាំងបី គឺលោកមើលទៅខាងស្តាំ ជ្រុងក្រដាសខាងស្តាំទៅ មានផ្ទះទុកឯកសារ ហើយផ្ទះដែល ឌុច ធ្លាប់ស្នាក់នៅ។ លោកមើលៗ លោកពិនិត្យមើលឃើញទេ លោកនៅចាំទេ?

[១០:១៥:០៤]

**លោក នឹម អ៊ឹម៖**

**ឆ៖** បាទ ខ្ញុំចាំ។ ផ្ទះដែលខ្ញុំនៅគូសរង្វង់ខៀវ។ ផ្ទះ តាឌុច នៅបន្ទាប់ពីខ្ញុំប្រហែលជា ៥០-៦០ ម៉ែត្រប៉ុណ្ណឹងទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដោយសារការគូសរង្វង់ហ្នឹង គឺថាមិនមានច្បាស់លាស់ អ៊ីចឹងធ្វើច្បាស់លាស់សម្រាប់ប្រតិចារឹក ខ្ញុំមិនមានបញ្ហាទេ ប៉ុន្តែដើម្បីប្រតិចារឹក យើង--

**លោក វ៉ិចទ័រ កូប៉េ៖**

<ដោយសារតែយើងមិនអាច -->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ខ្ញុំមិនជំទាស់នឹងការដែលលោកប្រើឯកសារនេះទេ ប៉ុន្តែដើម្បីជាប្រតិចារឹក យើងចង់កំណត់នូវអ្វីដែលគាត់បញ្ជាក់នេះ។>

**លោក វ៉ិចទ័រ កូប៉េ៖**

ដោយសារតែពេលវេលា ខ្ញុំយល់ឃើញថា ខ្ញុំសូមយកផែនទីនេះមកវិញ ហើយទី១ យើងខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះឲ្យបានច្បាស់លាស់ថា តើគាត់រៀបរាប់ ផ្ទះមួយណាជាអ្វីៗ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកឯកសារនេះ យកទៅឲ្យលោកមេធាវី នួន ជា វិញ។

[១០:១៦:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំក៏ឆ្ងល់ដែរ <ហេតុអីបានគាត់និយាយថាពណ៌ខៀវ ព្រោះអត់មានការគូសរង្វង់ពណ៌ខៀវទេ។ មានរង្វង់>ពណ៌លឿង<មួយ ហើយនិងរង្វង់>ពណ៌ទឹកក្រូច<ពីរ>។ <>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងឯង បានន័យថាដោយសារវាមិនច្បាស់ យើងប្រហែលជាអាចសួរគាត់ជាថ្មី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី <ខ្ញុំបានឮខ្លះហើយ -- នៅពេលមួយនោះ មានម៉ាស៊ីនថតរូបផងដែរ ដែលអាចផ្ដង់ទៅលើសាក្សី។ ប្រហែលជាយើងអាចប្រើវាតែម្ដង។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<>ប្រហែលជាមន្ត្រីតុលាការអាចអង្គុយក្បែរគាត់ទៅ ហើយអានឲ្យគាត់ស្ដាប់ <-- ឲ្យគាត់ចង្អុលទៅ ហើយអានឲ្យគាត់ស្ដាប់>។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <ខ្ញុំសួរលោកម្តងទៀត ឲ្យលោកបង្ហាញ>ផ្ទះដែលលោក សុង ហើយនិង និត ហ្នឹងស្នាក់នៅ។ សូមលោកបញ្ជាក់អំពីផ្ទះមួយនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ខ្ញុំគ្រាន់តែចង់សួរដើម្បីឲ្យច្បាស់ ថាតើការគូសរង្វង់ហ្នឹង គឺជាការគូសរង្វង់ដែលខាងសហចៅក្រមស៊ើបអង្កេតគូស ឬមួយក៏លោកអ្នកគូស?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺខាងសហចៅក្រមស៊ើបអង្កេតអ្នកគូសទេ។

[១០:១៧:៤៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកអាចចង្អុលបានទេថា ផ្ទះដែលលោក ហើយនិង សុង ហើយនិង និត រស់នៅហ្នឹង តើលោកអាចប្រាប់ទៅមន្ត្រីតុលាការដែលអង្គុយជាប់លោកហ្នឹង ឲ្យដឹងបានទេ?

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកផែនទី យកទៅបង្ហាញឲ្យសាក្សីពិនិត្យមើល។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១០:១៨:៥៣]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សាក្សីតើលោកអាចបញ្ជាក់បានទេថា អាចបញ្ជាក់អំពីផ្ទះដែលមេធាវីការពារសួរលោកហ្នឹងទេ?

**លោក នឹម អ៊ឹម៖**

បាទ ដឹង ព្រោះផ្ទះខ្ញុំៗឲ្យប្រាប់អ្នកនៅក្បែរខ្ញុំនេះ កន្លែងនេះណេះ។

**លោកស្រី សួ សុទ្ធាវី៖**

*(ឮមិនច្បាស់)*

**លោក នឹម អ៊ឹម៖**

បាទៗ អាហ្នឹងពណ៌លឿងនេះ អាហ្នឹងគឺផ្ទះខ្ញុំនៅ ហើយនេះផ្ទះ តាឌុច។ តែមួយនេះ ខ្ញុំអត់បានដែលទៅទេណា។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើផ្ទះ ឌុច ហ្នឹងគេគូសរង្វង់ពណ៌អី?

**លោក នឹម អ៊ឹម៖**

**ឆ៖** ពណ៌ទឹកក្រូច។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវីការពារក្តីនឹងប្រាប់យើងដើម្បីជាកំណត់ត្រាប្រតិចារឹក ថាតើគាត់គូសពណ៌អី?

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ គឺយើងមានគូស<ពណ៌ទឹកក្រូច>ពីរ អាមួយខាងលើ អាមួយខាងក្រោម ហើយប្រហែលជាខាងមន្ត្រីតុលាការអាចជួយបាន។

**លោក នឹម អ៊ឹម៖**

**ឆ៖** ផ្ទះៗ តាឌុច ខាងក្រោមនេះបាទ។ ពណ៌ទឹកក្រូចខាងក្រោម។

**ស៖** ហើយៗចុះអាផ្ទះពណ៌លឿងវិញ <ជាផ្ទះដែលលោករស់នៅឬ?>

**ឆ៖** ផ្ទះខាងលើខ្ញុំអត់ដែលៗ -- អត់ដឹង។

**ស៖** <>ដើម្បីជាកំណត់ត្រាប្រតិចារឹក ផ្ទះពណ៌លឿងគឺជា "កន្លែងរក្សាទុកឯកសារ <និង> សួរចម្លើយ ផ្ទះលេខ១២ ផ្លូវ៣៤៨" <យោងទៅលើឯកសារ D49/8> នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ <សៀង ដានី>។

[១០:២០:៥២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណ។ ហើយខ្ញុំគិតថាប្រសិនបើលោកអាចឲ្យកំណត់ត្រាហ្នឹងមក ដើម្បីជាកំណត់ត្រាប្រតិចារឹកយើងមិនដាក់បញ្ចូលធ្វើជាភស្តុតាងទេ ប៉ុន្តែយើងអាចភ្ជាប់ជាមួយកំណត់ត្រាប្រតិចារឹកបាន។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំនឹងអនុវត្តន៍តាម។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ដោយសារតែខ្ញុំអត់មានឯកសារដែលមានគូសពណ៌ គូសលឿងអីហ្នឹង។ ដូច្នេះ ខ្ញុំមិនច្បាស់ថាតើសាក្សីគាត់រស់នៅក្នុងផ្ទះសួរចម្លើយ ឬមួយក៏យ៉ាងម៉េច តើអ៊ីចឹងមែនទេ?

[១០:២១:៣៥]

**លោក វ៉ិចទ័រ កូប៉េ៖**

<អត់ទេ។ នោះ>គឺអ្វីដែលរៀបរាប់ពីផ្ទះនោះ។ ទោះបីថាការរៀបរាប់ហ្នឹងត្រូវឬមិនត្រូវក៏ដោយ ប៉ុន្តែខ្ញុំមិនដឹងទេ។ ប៉ុន្តែ<នោះជា>អ្វីបាននិយាយនៅក្នុងឯកសារ E3/10603។ <>ប្រហែលជាឧបសម្ព័ន្ធមិនត្រឹមត្រូវ <ហើយវាពិតជាផ្ទះ --> ប៉ុន្តែខ្ញុំនឹងសួរបន្តទៅទៀតទាក់ទងទៅនឹងរូបថតនេះ។ ដូច្នេះ ខ្ញុំនឹងអាចបន្តទៅទៀតបានបើសិនអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីបន្តសំណួរ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំដឹងអំពីពេលវេលា ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំរីករាយនឹងបន្តទៅមុខទៀតលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកអាចរំឭកបន្តិចបានទេថា នៅត្រង់កន្លែងណានៅក្នុងផ្ទះហ្នឹង ដែលជា ដែលគេទុកនៅម៉ាស៊ីនផ្តិតហ្វីល ម៉ាស៊ីនលាងៗហ្វីល? <តើ>បន្ទប់ងងឹតមួយដែលគេរក្សាទុកថ្នាំលាងហ្វីលលាងអីជាដើម <រួមទាំងឧបករណ៍វាស់វែង>ហ្នឹង<នៅកន្លែងណា?> តើលោកអាចចាំបានទេ?

[១០:២៣:០៥]

**លោក នឹម អ៊ឹម៖**

**ឆ៖** បាទ ខ្ញុំចាំបាន។ ព្រោះក្នុងហ្វីលក្តី ក្រដាសក្តី ថ្នាំក្តី ខ្ញុំដាក់នៅក្នុងបន្ទប់ផ្តិតហ្នឹងហ្នុង។ ព្រោះបន្ទប់ហ្នឹងធំ មានម៉ាស៊ីនត្រជាក់ការពារសម្ភារៈហ្នឹងបានទាំងអស់ អត់មានដាក់នៅក្រៅណាក្រៅពីបន្ទប់ផ្តិតខ្ញុំហ្នឹងទេ។

01382287



**សះ** អ៊ីចឹងឧបករណ៍និងថ្នាំសំខាន់ៗ ដើម្បីលាងផ្តិតហ្វីលទាំងអស់ គឺគេទុកនៅក្នុងផ្ទះហ្នឹងមែនទេ គឺថាតាំងពីចាប់ផ្តើមដំបូងនៅពេលដែលលោកហើយនិង សុង ហើយនិង និត ចូលធ្វើការរហូតដល់ថ្ងៃ០៧ មករា ៧៩ ហ្នឹងគេទុកតែមួយកន្លែងហ្នឹងទេ តើមែនទេ?

**ឆះ** ៧៩ ជួនណាខ្ញុំប្រមូលតាមផ្ទះមកវិញទេ យកមកទុកថែរក្សាការពារដែលខ្ញុំត្រូវការធ្វើហ្នឹងណា គឺប្រមូលពីណាពីណី មកទុកកន្លែងខ្ញុំ រក្សាទុកកុំខូចហ្វីល ខូចថ្នាំ ខូចក្រដាសហ្នឹង។

**សះ** ខ្ញុំយល់ ប៉ុន្តែខ្ញុំចង់សួរលោកថា អ៊ីចឹងបានន័យថាទាំងឧបករណ៍ទាំងអស់ គឺនៅក្នុងមួយកន្លែងហ្នឹងទេ។ គឺបានន័យថាចាប់ពីខែឧសភា ៧៦ រហូតមកដល់ខែមករា ៧៩ ហ្នឹង គឺឧបករណ៍ទាំងអស់ទឹកថ្នាំហ្វីលក្រដាសអីហ្នឹង គឺទុកតែមួយកន្លែងហ្នឹងទេមែនទេ?

**ឆះ** ទុកតែមួយកន្លែងហ្នឹងទេ។

[១០:២៥:០៧]

**សះ** ឥឡូវនេះជាសំណួរចុងក្រោយសម្រាប់ផ្នែកនេះ គឺថាលោកសាក្សី តើមានតែលោក និត ហើយនិង សុង ហ្នឹងទេដែលរស់នៅទីនោះ ឬមួយក៏មានមនុស្សផ្សេងទៀតមកនៅជាមួយលោកដែរ នៅផ្ទះនោះ?

**ឆះ** គឺអត់មានក្រៅពីក្រុមខ្ញុំបីនាក់ៗហ្នឹងទេ បើតែ ញ៉ែម អេន មិនដែលបានទៅដេក តែថ្ងៃមិនបានដេកផង។ តែចូលផ្តិត ខ្ញុំក៏អត់ឲ្យទាន់ចូលដែរ ព្រោះ ញ៉ែម អេន ពេលមករៀនមួយភ្លែតៗគេទៅធ្វើកន្លែងគេវិញបាត់ទៅ។ តែចំពោះខ្ញុំបីនាក់ គឺប្រចាំការហ្នឹងហ្មង។

**សះ** ឥឡូវនេះខ្ញុំសួរលោកអំពីការលាង និង ផ្តិតហ្វីល។ តើលោកអាចប្រាប់បានទេថា លោកលាង ហើយផ្តិតហ្វីលហ្នឹងដោយរបៀបណា? តើវាជាការងារលំបាក ឬមួយក៏ថាអាចពេលខ្លះវាផ្តិតលាងទៅវាខូចជាដើម? តើលោកអាចរៀបរាប់ឲ្យបានលម្អិតបន្តិចបានទេអំពីការងារនេះរបស់លោក?

**ឆះ** សារៈសំខាន់គឺមុនដំបូង។ ងាប់រស់មុនដំបូង គឺពេលលាងហ្វីលតែម្តង។ ពេលដែលយើងលាយថ្នាំទៅខុស គឺខូចទាំងអស់។ តែបើយើងបញ្ចូលហ្វីលហ្នឹងវាប៉ះគ្នា ខូចមួយ ឬពីរតែប៉ុណ្ណឹងទេណា។ តែបើលាយថ្នាំខុស គឺខូចទាំងអស់ហើយ។ អាហ្នឹងផ្នែកខាងលាងហ្វីល។ តែបើចំណែកខាងផ្តិតវិញ បើយើងផ្តិតទៅខូចមួយសន្លឹក វាអត់បញ្ហាអីទេ។ ព្រោះសំខាន់តែលាយថ្នាំ តែលាយថ្នាំខូច គឺខូចទាំងអស់ហ្មង។ តែលាងទៅខូច លាងខូចៗហើយ។ សំខាន់ផ្តិត អ៊ីចឹងដូចគ្នា លាងហ្វីលដូចគ្នា។

[១០:២៧:១១]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ខ្ញុំសួរលោកបែបនេះ ព្រោះថានៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក E3/7639 អង់គ្លេសមានលេខ <00162736>, បារាំងមានលេខ 00338079 និងខ្មែរមានលេខ 00162713។ លោកបានពន្យល់ថា មានម្តងម្កាលគឺរូបថតហ្នឹងវាខូច។ ហើយលោកត្រូវផ្តិតរូបថតឡើងវិញ។ តើលោកចាំទេថា លោកបានឆ្លើយបែបនេះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលថា មានម្តងម្កាលទៅរូបថតវាអាចខូច?

**ឆ៖** មែន។ បើយើងផ្តិចខូច យើងអាចផ្តិចវិញបាន។ តែបើយើងលាង បើលាងហ្វីលខូច គឺត្រូវថតសាថ្មីហើយ អាហ្នឹងបើលាងហ្វីលខូចណ៎ា។ តែបើផ្តិតខូច យើងអាចផ្តិតសាថ្មីវិញបាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ដោយសារពេលនេះ ឪរឺឪ អស់ហើយក៏ដល់ពេលសម្រាកដែរ អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី ចាប់ពេលនេះតទៅ។

*(សវនាការសម្រាកពីម៉ោង ១០:២៨ នាទី ដល់ម៉ោង ១០:៥០ នាទី)*

[១០:៥០:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្ត អង្គជំនុំជម្រះសម្រេចបដិសេធការស្នើសុំពេលវេលាបន្ថែមរបស់មេធាវី នួន ជា ដោយសារការធ្វើសំណើសុំពេលវេលានេះយឺតពេលពេក នឹងធ្វើឱ្យប៉ះពាល់ដល់កាលវិភាគសវនាការយ៉ាងខ្លាំង។ ដោយសារអង្គជំនុំជម្រះត្រូវធ្វើសវនាការតាមប្រព័ន្ធសោតទស្សន៍នៅថ្ងៃច័ន្ទផង។ម្យ៉ាងទៀត មេធាវីការពារក្តីលោក នួន ជា សុំធ្វើសារណាផ្ទាល់មាត់លើការកោះហៅសាក្សីថ្មីម្នាក់នៅថ្ងៃនេះជំនួសឱ្យការធ្វើសារណានៅថ្ងៃសុក្រ។

សូមអញ្ជើញលោកមេធាវីការពារក្តី លោក នួន ជា បន្តសំណួរលើសាក្សីរូបនេះ!

**លោក វ៉ិចទ័រ កូប៉េ៖**

ការសម្រេចនេះមិនច្បាស់ទាល់តែសោះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមបញ្ជាក់ គឺលោកបានធ្វើសារណានៅព្រឹកនេះ មុនពេលដែលយើងចាប់ផ្តើម។ យើងមានកាលវិភាគកំណត់កាលបរិច្ឆេទរួចទៅហើយ។ ហើយឥឡូវនេះ ប្រសិនបើយើងពន្យារពេលបន្ថែមតទៅ

ទៀត គឺបានន័យថា យើងនឹងខកពេលសវនាការតាមវីដេអូលីង។ ដូច្នេះ អង្គជំនុំជម្រះផ្តល់យោបល់ថា ប្រសិនមានយោបល់ទាក់ទងទៅនឹងការបែងចែកពេលវេលា គឺសូមឲ្យលើកបញ្ហាហ្នឹងឲ្យបានឆាប់រហ័សមែនទែន មិនមែនលើកមកពេលភ្លាមៗនេះទេ ដើម្បីឲ្យអង្គជំនុំជម្រះអាចសម្របសម្រួលបាន។

**លោក វ៉ិចទ័រ កូប៉េះ**

<នេះគឺមិនសមហេតុផលសោះ>លោកស្រីចៅក្រម ហ្វេនស៍ គឺថាលោកស្រី<>ដឹង<ហើយមិនមានបញ្ហាលើការកំណត់ពេលវេលាទាល់តែសោះ។ យើងអាចបន្តទៅទៀតបាន>--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<មេធាវីការពារក្តី ប្រយ័ត្នសម្តី។>

**លោក វ៉ិចទ័រ កូប៉េះ**

<ខ្ញុំនឹងមិនប្រយ័ត្នទេ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកបានទទួល -->

**លោក វ៉ិចទ័រ កូប៉េះ**

<ខ្ញុំនឹងមិនប្រយ័ត្នសម្តីទេ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<-- សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។>

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំនឹងមិនខ្វល់អំពីពាក្យសម្តីរបស់ខ្ញុំនោះទេ។ គាត់ជាប្រធានអង្គភាពផ្តិតរូបថត។ <យើងបានស្តាប់សក្ខីកម្មលោក ញ៉ែម អេន ជាមនុស្សបោកប្រាស់> ហើយគាត់ជាមនុស្សសំខាន់ <នៅពេលយើងនិយាយពី ស-២១> ហើយលោកស្រីចៅក្រម គ្រាន់តែនិយាយថា មិនទេ?

[១០:៥២:៣៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកគួរតែធ្វើសំណើជាលាយលក្ខណ៍អក្សរដោយមានសំអាងហេតុ យើងនឹងពិចារណាក្នុងការកោះហៅមកវិញ។

**លោក វិុចទ័រ កូប៉េ៖**

មិនអីទេ។

**សួរដោយលោក វិុចទ័រ កូប៉េ៖**

**ស៖** ឥឡូវនេះ លោកសាក្សីយើងបន្តទៅមុខទៀត។ ខ្ញុំសូមបន្តទៅលើការសួរសំណួររបស់ខ្ញុំទាក់ទងទៅនឹង ញ៉ែម អេន បន្តទៀត មុននឹងខ្ញុំសួរទៅលើដំណើរការថតរូបបន្ត។ មេធាវី ខៀវ សំផន បានប្រាប់ខ្ញុំអំពីចម្លើយរបស់ ញ៉ែម អេន ទាក់ទងទៅនឹងចម្លើយដែលថា គាត់ជាប្រធានអង្គភាពថតរូប ហើយខ្ញុំសូមអានឲ្យលោកស្ដាប់។ ហើយបន្ទាប់មកទៀត ខ្ញុំនឹងឲ្យលោកបង្ហាញនូវប្រតិកម្មរបស់លោកចំពោះចម្លើយ។ នៅថ្ងៃ២១ មេសា <មុនម៉ោង០៩:៤៥ នាទី> គឺ ញ៉ែម អេន បាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ខ្ញុំត្រឡប់មកពីចិនបន្ទាប់ពីចូលរួមវគ្គបណ្តុះបណ្តាល។ ខ្ញុំមិនមានតួនាទីខ្ពស់ទេ ប៉ុន្តែខ្ញុំចាត់ទុកខ្លួនខ្ញុំថាជាប្រធាន។ ប៉ុន្តែនៅទីនោះគឺមានពីរផ្នែក។ ដូចដែលខ្ញុំបានបញ្ជាក់រួចទៅហើយ គឺថាខ្ញុំគឺជាប្រធានកង ហើយ <ស្រ៊ាង> គឺជាប្រធានកងផងដែរ។ ខ្ញុំរៀននូវបច្ចេកទេសទាំងអស់ពីចិន ដូចជាថតរូប ផ្ដិតរូប <និងគូរផែនទី>ជាដើម។ ទោះបីជាខ្ញុំមិនជំនាញក៏ដោយ ប៉ុន្តែខ្ញុំមានចំណេះដឹងច្រើនជាងគេនៅក្នុងផ្នែកទាំងអស់នេះ។ ហេតុដូច្នេះហើយ ខ្ញុំគិតថាខ្លួនខ្ញុំគឺជាប្រធាន។” តើលោកអាចបង្ហាញនូវប្រតិកម្មរបស់លោកចំពោះអ្វីដែល ញ៉ែម អេន និយាយហ្នឹង តើលោកយល់យ៉ាងម៉េចដែរ?

[១០:៥៤:២២]

**លោក នឹម អ៊ឹម៖**

**ឆ៖** ព្រោះ ញ៉ែម អេន គឺខ្ញុំពិបាកថា វាអស់សំណើចរឿងត្រង់ថា គាត់ក្មេងមិនទាន់ជ្រុះពន្លៃផង ហើយថា វាទៅរៀនពីចិន ព្រោះចិន ពួកខាង៧០៣ ចាត់តាំងតែបីនាក់ទៅរៀនទេ។ ខ្ញុំអត់បានទៅផងកាលហ្នឹង។ គេឲ្យតែអ្នកអត់ចេះអក្សរទៅរៀន។ ហើយចំណែក ញ៉ែម អេន ក្មេងតូចមួយថាចេះ ខ្ញុំអត់ជឿ។ បើអត់ចេះ បើចេះដដែល ម៉េចមកសុំរៀនពីខ្ញុំធ្វើអី។ អ៊ីចឹងសូមអស់យោបល់ហើយ។

**ស៖** មុននេះ លោកនិយាយថា ញ៉ែម អេន មិនទាំងចេះដាក់ហ្វីលចូលកាមេរ៉ាផង។ តើលោកពិតជាបាននិយាយអ៊ីចឹងមែនទេ ហើយតើ ញ៉ែម អេន ពិតជាកុហកអំពីតួនាទីរបស់គាត់នៅផ្នែកថតរូបនៅស-២១ មែនទេ?

**ឆ៖** បាទ ពិតមែនហើយ។ ព្រោះកាលហ្នឹងមកដល់មិនទាន់ចេះអីទាំងអស់។ ខ្ញុំឲ្យបញ្ចូលហ្វីល ហើយចង់ដឹងមើល បញ្ចូលអត់ត្រូវផងហ្នឹង។ ហើយដល់ពេលហើយ តាំងខ្លួនថាចេញមកពីរៀនចិន ធ្វើ

មេងណា។ ព្រោះកន្លែងខ្ញុំមានបីនាក់។ ញ៉ែម អេន អត់មាន បានត្រឹមរៀនភ្លែតៗ ហើយទៅកន្លែងវាវិញទេ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំបន្តទៅនិយាយអំពីការថតរូបនៅក្នុងបរិវេណស-២១។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បីបង្ហាញឯកសារ គឺបង្ហាញនូវរូបភាព<ដែលមានដាក់នៅក្នុងបញ្ជី>មួយ។ នៅក្នុងឯកសារ E3/9214 គឺជារូបថតជាច្រើនដែលថតនៅក្នុងមន្ទីរស-២១ ហើយអ្វីដែលខ្ញុំចង់លើកឡើង គឺថាខ្ញុំសូមប្រគល់ឯកសារមួយ*ក្រណូ* ដែលមានរូបថតទាំងអស់នេះជូនទៅសាក្សី ហើយក្នុងពេលជាមួយគ្នាហ្នឹង គឺក្រុមការងាររបស់ខ្ញុំនឹងដាក់បង្ហាញរូបភាពទាំងអស់នេះនៅលើអេក្រង់ គឺនៅក្នុងឯកសារ E3 នេះ ហើយខ្ញុំនឹងឲ្យសាក្សី គាត់មើលរូបថតទាំងអស់នេះ។ ហើយយើងទាំងអស់គ្នា ក៏យើងពិនិត្យមើលទៅលើរូបថតទាំងអស់នេះ<នៅលើអេក្រង់>។

[១០:៥៦:៥១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដើម្បីជាកំណត់ត្រាប្រតិចារឹក និងដើម្បីឲ្យយើង<ប្រយ័ត្នចំពោះបទពិសោធន៍កន្លងមក> ថាតើលោកមានបានគូសកំណត់សម្គាល់អីនៅលើរូបថតនេះទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

អត់ទេ។ ខ្ញុំអត់មានធ្វើអីទេ ព្រោះខ្ញុំមិនដឹងថាតើគាត់ស្គាល់អ្វី ឬមិនស្គាល់អ្វីទេ។ ដូច្នេះ ខ្ញុំអត់មានគូសសម្គាល់ ធ្វើកំណត់សម្គាល់អីនោះទេ នៅលើរូបថតនោះ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកឯកសារនេះ ពីលោកមេធាវី នួន ជា យកទៅបង្ហាញ -- យកទៅប្រគល់ឲ្យសាក្សីពិនិត្យ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតថា អង្គភាពសោតទស្សន៍ដាក់បង្ហាញនូវរូបថតទាំងអស់នេះ ទៅលើអេក្រង់ ដើម្បីឲ្យសាធារណជន គាត់អាចតាមដានមើលជាមួយយើងទាំងអស់គ្នាបាន។ សូមលោកប្រធាន អនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ អង្គភាពសោតទស្សន៍សូមបង្ហាញរូបថតនេះ តាមអេក្រង់ទូរទស្សន៍។ សូមអញ្ជើញលោកចៅក្រម លោកចៅក្រម ហ្សង់ម៉ាក!

[១០:៥៨:១៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកមេធាវី លោកបានផ្ដល់លេខឯកសារ E3/9214។ ឯកសារហ្នឹងគឺជាបញ្ជីរូបថត ហើយនិងបញ្ជីឈ្មោះ។ អ៊ីចឹង លោកអាចផ្ដល់លេខយោងនៃរូបថតហ្នឹងបានទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺ E3/9214a។ គឺអក្សរ “a” ដែលយើងឃើញរូបថតទាំងអស់ហ្នឹង ដែលជារូបថតប្រើប្រាស់ដោយខាងព្រះរាជអាជ្ញាផងដែរ នៅពេលដែលគាត់សួរ ញ៉ែម អេន។ នេះគឺជារូបថតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រគល់មកយើង ហើយវាមានអក្សរសរសេរដៃនៅលើ<ខ្នង>រូបថតនោះផងដែរ។ ដូច្នេះ ដើម្បីជួយសម្រួលដល់ការងារ ខ្ញុំសូមអនុញ្ញាតពីលោកប្រធានថា ឲ្យមន្ត្រីតុលាការអង្គុយជាប់សាក្សី ដើម្បីជួយដល់សាក្សី។ ហើយខ្ញុំឃើញថា លោកសាក្សីគាត់កំពុងតែបើកមើលរូបថតរួចទៅហើយ។ ដូច្នេះ ខ្ញុំគិតថាយើងនឹងធ្វើដូចគ្នា នៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានឯកសារ E3/9214a នោះទេ ប៉ុន្តែខ្ញុំមានរូបថតនេះ។ <គ្រាន់តែដើម្បីជាការយោងរបស់តុលាការទេ ក្នុងករណីដែលអ្នកផ្សេងទៀតមានបញ្ហាក្នុងការរកមើលឯកសារនេះ> គឺឯកសារ <E3/9837> <>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺប្រសិនម៉្យាងទៀត គឺឯកសារ E3/94.1 ក៏មានដែរ។ ខ្ញុំសង្ឃឹមថា ឥឡូវនេះយើងអាចឃើញនៅលើអេក្រង់។ លោកសាក្សី ខ្ញុំសូមបង្ហាញជូនលោកនូវរូបថតដែលយើងគិតថា ប្រហែលជារូបថត ថតនៅ ស-២១។ តើលោកចាំទេ តើលោកចាំរូបថតទាំងអស់នេះទេ?

**លោក នឹម អ៊ីម៖**

**ឆ៖** រូបថតនេះគឺ វាមិនបានចាំទាំងអស់ទេ ព្រោះថាគ្នាខ្ញុំបីនាក់ថត មានតែបីនាក់ទេចូលថត

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បើខ្ញុំមិនបានទៅថត អាសុង អានិត ទៅថត។ តែនេះសុទ្ធតែពួកខាងខ្ញុំថតហើយ មិនមែនពួកណាចូលមកថតបានទេ កាលពីជំនាន់ហ្នឹង គឺមានតែបីនាក់នៅប្រចាំការហ្នឹង។

[១១:០១:១០]

**ស៖** សូមទោសដែលខ្ញុំសួរមិនច្បាស់ ខ្ញុំមិនមែនសួរលោកឲ្យកំណត់ថា អ្នកណាជាអ្នក -- ថា តើលោកស្គាល់អ្នករូបថតអស់នោះអត់ទេ។ ខ្ញុំគ្រាន់តែចង់ឲ្យលោកពិនិត្យមើលទៅលើរូបថតម្តងមួយៗទាំងអស់ហ្នឹងបើកមើលត្រួសៗទៅ ហើយតើលោកមើលទៅឃើញថារូបថតហ្នឹង គឺជារូបថតដែលគេថតនៅស-២១ មែនទេ? ឧទាហរណ៍ថាលោកចាំអំពីទំហំរូបថត ឬក៏ថារបៀបដែលគេថត របៀបដែលគេដាក់មនុស្សឲ្យឈរថតអីជាដើមហ្នឹង តើវាជារបៀបដែលគេធ្វើនៅស-២១ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតហើយ សុទ្ធតែថតស-២១។ កន្លងមក ជួនណា កាលពីមុនខ្ញុំថតផ្ទាល់ជញ្ជាំងជាប់ជញ្ជាំងក៏មាន ជួនណាថតតាមបង្អួចក៏មាន។

**ស៖** លោកប្រធាន ក្នុងពេលដែលសាក្សីគាត់ឆ្លើយ គឺថាអេក្រង់អត់មានបង្ហាញរូបថតអីទេ ដូច្នេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានបង្គាប់ទៅដល់អង្គភាពសោតទស្សន៍ ឲ្យរក្សារូបថតនៅលើអេក្រង់ដើម្បីឲ្យសាធារណជនគាត់អាចមើលឃើញ។ លោកសាក្សីរូបថតទាំងអស់នេះត្រូវបានថតនៅ ស-២១ ប្រសិនបើយើងមើលចុះទៅក្រោមបន្តិចនោះ យើងនឹងឃើញថានៅគ្រប់ទំព័រទាំងអស់គឺនៅខាងក្រោយខ្នងរូបថតហ្នឹងគឺវាមានអក្សរ។ ហើយរូបថតទាំងអស់មានអត្ថបទនៅខាងក្រោយខ្នងរូបថត សូមលោកមើលទៅលើរូបភាពខ្នងរូបថតហ្នឹងទៅមើលបន្តិចមើល។

**ឆ៖** ត្រូវហើយកាលហ្នឹង គឺថតហើយយកឲ្យ ធី គេទៅនេះ បញ្ជូនរូបថតទៅ ធី តែពួកខ្ញុំអត់បានសរសេរអាក្រោយហ្នឹងទេណ៎ា។ ធី ទៅដល់ គឺបញ្ជូន -- ផ្តិតហើយបញ្ជូនរូបថតទៅ ធី ខ្មោកៗ។

[១១:០៣:៤២]

**ស៖** លោកមើលទៅក្រោមបន្តទៀតថា តើលោកចាំទេថាតើជាអក្សររបស់ សួស ធី ឬក៏មិនមែន? ខ្ញុំមិនដឹង ខ្ញុំមើលទៅដូចជា មើលទៅអក្សរហ្នឹងដូចជាមិនមែនជាអក្សរមនុស្សតែមួយទេ លោកអាចបញ្ជាក់បានទេទៅលើចំណុចនេះ?

**ឆ៖** កាលហ្នឹង ខ្ញុំអត់ដឹងថាពីណាអ្នកសរសេរទេណ៎ា រូបថតហ្នឹង ព្រោះខ្ញុំថតហើយកាត់តម្រូវហើយអីហើយ បញ្ជូនទៅឲ្យខាង ធី រៀបចំឯកសារនៅជាមួយឈ្មោះមនុស្សហ្នឹងណ៎ា។ រួចគេចូលថ្ងៃប៉ុន្មាន ខែប៉ុន្មាន ហ្នឹង ធី លើគេអ្នកគេរៀបចំទេអាហ្នឹង។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** ខ្ញុំយល់បានលោកសាក្សី។ ញ៉ែម អេន នៅក្នុងសាលសវនាការនេះបានន័យថាវាជាអក្សរដៃ អក្សរសរសេរដៃរបស់លោក តើលោកយល់យ៉ាងម៉េចដែរ? តើលោកមានប្រតិកម្មយ៉ាងម៉េចដែរចំពោះអ្វីដែល ញ៉ែម អេន បាននិយាយនេះ?

**ឆៈ** ព្រោះ តាញ៉ែម អេន និយាយនេះ ខ្ញុំអត់ទទួលស្គាល់ទាំងអស់។ ព្រោះធម្មតា ខ្ញុំមានសិទ្ធិតែផ្តិត -- អ៎! ថតនិងផ្តិត។ រឿងការកត់ថ្ងៃឈ្មោះថ្ងៃខែគេ អាហ្នឹងលើ ធី គេអ្នកៗគេសម្រេចណា ព្រោះគេអ្នកគ្រប់គ្រងការចេញចូលក្នុងមន្ទីរហ្នឹង។

[១១:០៥:៣៤]

**សៈ** អរគុណលោកសាក្សី។ ឥឡូវនេះប្រសិនបើលោកបើកទំព័រថ្មី ហើយខ្ញុំក៏សូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ផងដែរ គឺថាលោកឃើញរូបមនុស្សទាំងអស់នេះនៅក្នុងផ្នែកដំបូងនៃក្រុណ្ឌគឺគេមាន នៅលើរូបថតមួយៗមានលេខ គឺមានលេខនៅលើដើមទ្រូងរបស់ពួកគេតែម្តង។ លោកឃើញលេខដែលគេដាក់នៅលើទ្រូងរូបថតទាំងអស់នេះទេ គឺនៅរូបថតមួយៗសុទ្ធតែមានលេខជាប់នឹងទ្រូងរបស់ពួកគេ?

**ឆៈ** គឺលេខរូបនេះគឺ ខ្ញុំ, និត, សុង។ គឺខ្ញុំថតបានប៉ុន្មាន ខ្ញុំការពាររបស់ខ្ញុំ ខ្លាចខូច ខ្ញុំយកតែ បើថាខូចលេខ១ លេខ២អីចឹង ខ្ញុំយកលេខហ្នឹងទៅដកស្រង់ចេញពី ធី សូមឈ្មោះហ្នឹងមកថតវិញ។ លេខនេះអត់មានកំណត់ គឺគ្នាខ្ញុំបីនាក់ ពីណាថតបានប៉ុន្មាន គឺដឹងទទួលត្រូវប៉ុណ្ណឹង។ ព្រោះលេខហ្នឹងអត់មានកំណត់ថា អ្ហូ ! ចូលមួយថ្ងៃប៉ុន្មានៗ អត់កំណត់ចំពោះអ្នកថតទេ។ ខ្ញុំថតបានមួយថ្ងៃប៉ុន្មាន អ្នកចូលមក ១០០នាក់ ឧទាហរណ៍ ខ្ញុំបាន៣០ ឬបាន២០។ ថតបានប៉ុន្មានអាហ្នឹងគេលើក អាហ្នឹងគេកាន់លេខរៀងៗខ្លួនអ្នកថតហ្នឹង។

[១១:០៧:១៧]

**សៈ** នៅពេលដែលលោកមើលរូបថតហ្នឹងក៏គិតថា វាមានថ្ងៃខ្លះអត់មានអ្នកទោសចូលទេ ហើយលោករង់ចាំដល់មានអ្នកទោសគ្រប់គ្រាន់ចូលមកដល់បានលោកថត ហើយដាក់លេខហ្នឹង ឬមួយក៏យ៉ាងម៉េចដែរ?

**ឆៈ** អាហ្នឹងលេខសម្គាល់ មិនស្គាល់ខែឆ្នាំទេ ស្គាល់តែខ្ញុំអ្នកថតទេ ឧទាហរណ៍ បើខ្ញុំថ្ងៃនេះថត បើថាក្នុងមួយដុំហ្នឹង ខ្ញុំថតបានប៉ុន្មាននាក់ ថាបាន៣៦ -- ៣២នាក់ ឧទាហរណ៍ ខ្ញុំដាក់លេខរៀងរបស់ខ្ញុំ។ ហ៎! និត ថតបានប៉ុន្មានដាក់លេខរៀងប៉ុណ្ណឹង។ ប៊ុនគេចាំលេខរបស់គេ បើខូចលេខប៉ុន្មាន គេ

ទៅសាស្រង់ឡើងវិញ ទៅថតវិញលេខហ្នឹង។ ព្រោះលេខហ្នឹងគេអត់កំណត់ អត់មានកំណត់ថា អ៊ូ! ក្នុងចុះចូលមួយថ្ងៃប៉ុន្មានៗ អត់ទៀងទេ។ គឺគេកំណត់តែគេ ដូចថាខ្ញុំកាន់អាកាណុងទៅថត វាសាមសិបប៉ុន្មានប៉ុស្តិ៍ បានប៉ុន្មាន ដល់គេបង្ខំកាត់យកហ្នុង កាត់យកទៅបញ្ចូលលាងហ្វីលផ្តិត វាពិបាក។ អ៊ីចឹងបានដាក់លេខនេះ ដាក់គេកំណត់របស់កាន់ទេ អ្នកថតទេ។

[១១:០៨:៤៨]

**ស៖** ឥឡូវនេះខ្ញុំអានជូនលោកនូវអ្វីដែលលោកបានឆ្លើយជាមួយអ្នកស៊ើបអង្កេត <E3/7639> អង់គ្លេសមាន 00162737, ខ្មែរមានលេខ 00162714 និងបារាំងមានលេខ 00338080។ នេះគឺជាអ្វីដែលលោកបានឆ្លើយ៖ “ខ្ញុំចង់ពន្យល់ថាក្នុងចំណោមពួកយើងទាំងបីនាក់ ពេលខ្លះខ្ញុំអត់ទៅទេ ពួកគេអ្នកទៅ។ ហើយពេលខ្លះមានអ្នកទោសតិចតួចចូលមក ដូចដែលខ្ញុំនិយាយ គឺថាមានតែបួនប្រាំនាក់អ៊ីចឹងគឺគេរក្សាទុកពួកហ្នឹងប្រហែលជាប្រាំ -- បួន ប្រាំថ្ងៃ គឺរង់ចាំឲ្យមានមនុស្សច្រើនមុននឹងគេថតរូបរួម។ ធ្វើអ៊ីចឹងដើម្បីឲ្យយើងអាចប្រើអស់ហ្វីលមួយដុំក្នុងមួយពេល។” សូមបញ្ចប់ការដកស្រង់។ តើវាត្រឹមត្រូវទេ ដែលថាដោយសារតែលោកមិនចង់ឲ្យខាតហ្វីល គឺលោកត្រូវរង់ចាំឲ្យមានអ្នកទោសច្រើនបន្តិចមកដល់ មុននឹងលោកថតរូបរួមគ្នានោះ?

**ឆ៖** បាទ ពិតប្រាកដហើយ ព្រោះហ្វីល ព្រោះគេកាត់ក្នុងកាត់ ថតៗម្នាក់កាត់វាខាតអស់ពីរៗប្រឡោះ ដូច្នេះបើថាកាត់ញឹក ដូចថាសាមប៉ុន្មាន ៣០នាក់ វាបានតែត្រឹមពីរដណ្តប់ បីដណ្តប់នាក់ទេ។ អ៊ីចឹងបានគេទុក គេរក្សាទុកហ្វីលនៅក្នុងនេះដើម្បីចាំដល់ច្រើនថតយកទាំងអស់ បានៗលាងម្តងទៅ។

**ស៖** អ៊ីចឹងឧទាហរណ៍ថា ខ្ញុំឃើញរូបថត -- ខ្ញុំឃើញលេខ៣២នៅលើអ្នកទោស <រូបថត ១៨២> នៅទំព័រ P01223720 អ៊ីចឹងបានន័យថាមិនៗមែនគាត់មកលេខ៣២ទេ គឺថាវាជា អាចថាមិនមែនគាត់ជាលេខរៀងត្រឹម៣២ទេ ប៉ុន្តែវាអាចជាអ្នកមកក្នុងចំណោមក្រុមមនុស្សច្រើនក្នុងមួយថ្ងៃ អ៊ីចឹងមែនទេ?

**ឆ៖** ព្រោះអានេះវា ដូចថាមកគ្នាក្នុងមួយថ្ងៃទៅមាន៣២អ៊ីចឹង អានេះ ខ្ញុំកំណត់រូបថតៗទេណ៎ា គេដាក់លេខសម្គាល់របស់អ្នកជាងថត បើខ្ញុំទៅមានគ្នា២០នាក់ ខ្ញុំដាក់លេខ១ លេខ២ រហូតដល់លេខ២០ ស្រណុកការពារភ្លាត់ខូចអីមួយប៉ុស្តិ៍អី ពីរប៉ុស្តិ៍អីហ្នឹងណ៎ា។

**ស៖** ឥឡូវនេះសូមលោកពិនិត្យទៅលើក្រឡាបរបស់លោកនៅផ្នែកទី២ គឺផ្នែកទី២នៃរូបថតនោះ។ មន្ត្រីតុលាការគឺនៅតារាងលេខ២ គឺទំព័រ P01223764។ ហើយខ្ញុំសូមបង្ហាញនៅលើអេក្រង់ផង

ដែរលោកប្រធាន។

[១១:១២:២៧]

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីសោតទស្សន៍បង្ហាញរូបថតនេះនៅលើអេក្រង់ទូរទស្សន៍!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ហើយសូមលោកឡើងទៅលើ -- ចុះទៅក្រោមបន្តិច គឺយើងមើលរូបថតហ្នឹងទាំងអស់។ គឺលោកសាក្សី លោកឃើញហើយ ដូចគេថាការដាក់ស្លាកនៅលើអ្នកទោសទាំងអស់ហ្នឹង គឺខុសពីអ្នកទោសដែលខ្ញុំបង្ហាញលោកមុននេះ។ ឥឡូវហ្នឹងគឺថាស្លាកទាំងអស់ហ្នឹងគឺថាយើងឃើញនៅមុខ ខ្លួនគេគឺមិនមែនត្រឹមតែមានលេខតែមួយមុខទេ គឺស្លាកហ្នឹងវាមានកាលបរិច្ឆេទ ប្រហែលជាថ្ងៃខែចូលមកដល់ហ្នឹងតែម្តង។ ហើយខ្ញុំឃើញថា គឺការដាក់ស្លាកហ្នឹង គេចាប់ផ្តើមនៅដើមឆ្នាំ៧៨។ ថាតើការដាក់ស្លាកហ្នឹងយ៉ាងម៉េចដែរ? ហេតុអីបានជាមានការផ្លាស់ប្តូរពីការដាក់ស្លាកតែលេខ មកការដាក់ស្លាកដូចដែលយើងឃើញទាំងអស់គ្នានេះ?

**លោក នឹម អ៊ីម៖**

**ឆ៖** អាហ្នឹងដាក់ស្លាក ហើយនិងថតចំមុខនិងចំហៀង ហើយអាហ្នឹងវាចុង នៅចូលឆ្នាំ៧៨ ចុង៧៨ហើយ ចូលដើម -- ជិតចុង១៧៨ណ៎ា ព្រោះអាហ្នឹងវាស្រណុក។ ព្រោះអាហ្នឹង តាឌុច គាត់បញ្ជាឱ្យធ្វើ ថតពីមុខផង ថតចំហៀងផង ហើយនិងដាក់ឈ្មោះ ថ្ងៃខែ ថ្ងៃចូលហ្នឹងណ៎ា។

**ស៖** ខ្ញុំនឹងសួរលោកអំពីចំណុចនេះនៅពេលក្រោយបន្តិច ប៉ុន្តែឥឡូវនេះ គឺខ្ញុំចង់សួរថាតើៗការដាក់លេខហ្នឹង វាផ្លាស់ប្តូរនៅដើម៧៨ ដោយគេមកប្រើប្រាស់ស្លាកដែលថា គេដាក់ស្លាកថ្ងៃខែ ហើយនិងឈ្មោះ។ តើអ៊ីចឹងមែនទេ គេផ្លាស់ប្តូរនៅដើម៧៨ ឬក៏ម៉េចដែរ?

**ឆ៖** វាផ្លាស់ប្តូរដើម្បីស្រណុកការបាត់ ដូចថាដូចការបាត់ឈ្មោះ -- បាត់ៗ ឬរលុបថតមិនជាប់ ថតទៅលាងទៅវាខូចអី ដើម្បីឱ្យដឹងថាឈ្មោះនេះ និង លេខទីប៉ុណ្ណេះ ថ្ងៃខែចូលប៉ុណ្ណេះ ស្រណុកនឹងស្រាវជ្រាវរកឈ្មោះដកយកមកថតវិញណ៎ា។

[១១:១៥:១៤]

**ស៖** តើលោកចាំទេថា ប្រព័ន្ធនៃការដាក់លេខនុ៎ងវាយ៉ាងម៉េចដែរ? គឺថាមិនត្រឹមតែមានការមិនមានថ្ងៃខែនិងឈ្មោះប៉ុណ្ណោះទេ នៅលើហ្នឹងមានទាំងលេខទៀត គឺមានលេខសម្រាប់អ្នកទោស

នីមួយៗទៀត។ ដូច្នេះ ខ្ញុំចង់ដឹងថាតើលេខហ្នឹងគឺគេដាក់តាមខែ ឬមួយក៏តាមត្រីមាស ឬក៏យ៉ាងម៉េចដែរ? តើគេរៀបចំលេខនៅលើខ្លួនអ្នកទោសហ្នឹងគេរៀបចំយ៉ាងម៉េចដែរ? លោកចាំទេ?

**ឆ៖** ចាំ ព្រោះលេខនេះដូចខ្ញុំប្រាប់តាំងពីដើមមកដូចថា លេខដើម្បីពួកខ្ញុំបីនាក់ដាក់ទេ ដាក់ដើម្បីសម្គាល់ណា។ ជួនណាខ្លះគេដាក់ទៅ គេដាក់របស់គេ គេតាមលេខរៀងគេ ចង់ដឹងមើល ជួនណាអត់នឹកឃើញ ភ្លេចអី។ គេដាក់តាមលេខដែលគេចំណាំតាមហ្វីលវិញ ព្រោះអាហ្នឹងការៗលេខហ្នឹងអត់មានកំណត់ថា ចំពោះអ្នកទោសមានប៉ុន្មានៗ អត់ទេ។ អាហ្នឹងតាមខ្ញុំអ្នកធ្លាប់ផ្តិតហ្នឹង។

**សៈ** ខ្ញុំយល់លោកសាក្សី។ ប៉ុន្តែប្រសិនបើយើងមើលទៅលើរូបថតទី១ គឺ P01223764 ខ្ញុំឃើញថាអ្នកទោសមានលេខ ៣១២, ៥៥៩, <៦៥៩>, ៦៦២ ថាតើលេខប៉ុន្មានរយទាំងអស់ហ្នឹង វាមានន័យយ៉ាងម៉េចដែរ? <តើ>លោកនិយាយថាលេខហ្នឹង គឺមនុស្សម្នាក់ៗដែលថតហ្នឹងជាអ្នកប្រើ<ឬ>? ប៉ុន្តែប្រសិន បើអ៊ីចឹងមែន តើលោកថាលោកអាចចាំយ៉ាងម៉េចដែរ ទាក់ទងរឿងលេខហ្នឹង ឬមួយក៏ថាសហការីលោកពីរនាក់ទៀតហ្នឹង គាត់ប្រើលេខហ្នឹងយ៉ាងម៉េចដែរ? វាមានន័យដូចម្តេចដែរ?

**ឆ៖** ការណ៍នេះខ្ញុំពិបាកចាំដែរ ព្រោះក្រែង និត, សុង គេដាក់លេខសម្គាល់តាមក្នុងគេថតបានណា។ ចំណែកខ្ញុំ កម្រនេះ ខ្ញុំច្រើនតែឲ្យ សុង ទៅថត ព្រោះខ្ញុំយូរៗទៅថតម្តងទេ។

[១១:១៧:៤៩]

**សៈ** អ៊ីចឹងទាក់ទងទៅនឹងរូបថតនេះ ខ្ញុំនៅសល់មួយសំណួរចុងក្រោយ។ អស់លោក លោកស្រីមន្ត្រីតុលាការ សូមលោកស្រីមើលទៅតារាងទី៣ គឺទំព័រ01 -- សុំទោសគឺ P01223835 ហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញនៅលើអេក្រង់ផងដែរ។ លោកសាក្សី នេះគឺជារូបថតដែលមើលទៅដូចជាកម្មាភិបាល ប៉ុន្តែអត់មានលេខ អត់មានអ្វីនោះទេ គឺអត់មានពាក់ស្លាកលេខនៅលើទ្រូងនោះទេ។ ដូច្នេះសូមលោកមើលទៅពីរបីទំព័រខាងមុខទៀតទៅ តើលោកចាំរូបថតនេះទេ? ថាតើលោកជាអ្នកថតរូបហ្នឹង ឬក៏សហការីពីរនាក់ទៀតរបស់លោកជាអ្នកថតរូបទាំងអស់នេះ?

**ឆ៖** អូ៎ ! រូបថត បើពាក់ម្លូកអាហ្នឹងសុទ្ធតែអ្នកធ្វើការហើយណា។ បើអត់ពាក់ម្លូក អាហ្នឹងខ្ញុំសន្និដ្ឋានថា ប្រហែលជាកាលវគ្គមុនគេមិនទាន់ដាក់លេខ អ្នកទោសណា គេថាអ្នកទោសនាំចូលមកណា។ បើអ្នកថតដាក់មានពាក់ម្លូក អាហ្នឹងពួកកម្មាភិបាល អ្នកធ្វើការនៅក្នុងហ្នឹងហើយ។ តែបើអត់ពាក់ម្លូក អាហ្នឹងសុទ្ធតែពួកខាងកាលម៉ាហ៊ុកបញ្ជូនតាមឡាន។ កាលម៉ាហ៊ុកមានទាន់ដាក់លេខទេ អាមុនដំបូងបំផុត។

**ស៖** ខ្ញុំមានសំណួរសួរលោកច្រើនណាស់ ប៉ុន្តែដោយសារតែពេលវេលា ខ្ញុំត្រូវសួរលោកបន្តទៀតទៅលើការផ្តិត ហើយនិងលាងហ្វីលវិញម្តង។ យើងនិយាយអំពី -- លោកបាននិយាយថា ពេលខ្លះពេលដែលលោកផ្តិតនោះវាខូចរូបថតនោះ។ ប្រសិនបើរូបថតខូច ក្នុងពេលដែលលោកផ្តិត តើលោកធ្វើយ៉ាងដូចម្តេចដែរ?

**ឆ៖** ចំពោះអារឿងផ្តិតរូបថតគឺអត់បញ្ហាអីទេ ព្រោះយើងផ្តិត បើថាកំហុសខូច យើងផ្តិតម្តងខូច វាអត់មានខូចដល់ហ្វីលទេ ខូចត្រឹមតែក្រដាសទេ វាអាចផ្លាស់ក្រដាសផ្តិតវិញបាន។ តែបើយើងលាងហ្វីល តែលាងជាប់ឲ្យប៉ះគ្នា គឺ ហើយនិងយើងដាក់ថ្នាំខុសគឺ ខូចៗទាំងអស់ហើយ។

[១១:២០:០៩]

**ស៖** តើលោកចាំថាវាមានហេតុការណ៍ដែលថា លាងហ្វីលខូចទៅ ហើយលោកត្រូវថតឡើងវិញដែរឬទេ? ថាតើវាធ្លាប់មានករណីដែលហ្វីលខូច ហើយលោកត្រូវថតអ្នកទោសឡើងវិញដែរឬទេ?

**ឆ៖** មានៗ មានថត ជួនណាក្នុងថតមួយដុំហ្នឹង យើងដាក់ហ្វីលទៅ វាឲ្យប៉ះគ្នាមួយប្រឡោះអីទៅវាត្រូវខូចអស់ពីរបីដុំ -- ពីរបីនាក់ហ្វីលជាប់គ្នាហ្នឹងណ៎ា យើងទៅសុំ ធី ឡើងថត -- សុំថតឈ្មោះហ្នឹងវិញមក។

**ស៖** ឥឡូវនេះ ខ្ញុំសូមអានឲ្យលោកស្តាប់នូវអ្វីដែលលោកឆ្លើយជាមួយអ្នកស៊ើបអង្កេត។ ក្នុងកំណត់ហេតុស្តាប់ចម្លើយ E3/7639 អង់គ្លេសមានលេខ <00162734> ខ្មែរមានលេខ <00162710>, បារាំងមានលេខ <00338076>។ នេះគឺជាអ្វីដែលលោកបានឆ្លើយ ហើយខ្ញុំនឹងសួរលោកបន្ថែមទៅលើអ្វីដែលលោកឆ្លើយនេះ។ ខ្ញុំសូមដកស្រង់សម្តីលោកសិន៖ "ថ្ងៃមួយ ក្នុងពេលដែលខ្ញុំកំពុងតែលាងហ្វីល រូបថត ហ្វីលរូបថតនោះវាខូច។ នៅពេលដែលខ្ញុំស្នើសុំថតឡើងវិញ ខ្ញុំរកឃើញតែមនុស្សតែពីរនាក់ប៉ុណ្ណោះ។ ហើយខ្ញុំសួរ ឌុច ថា បង អ្នកទោសយកមកម្សិលមិញទៅណាអស់ហើយ? គាត់ថា ទៅស្រែអស់ហើយ ទៅថតនៅស្រែទៅ។" សូមបញ្ចប់ការដកស្រង់។ លោកចាំទេ ថាលោកបានឆ្លើយ ចម្លើយបែបនេះប្រាប់អ្នកស៊ើបអង្កេត?

**ឆ៖** បាទ ខ្ញុំធ្លាប់បានប្រាប់ដែរ ព្រោះកាលនោះ ខ្ញុំ ពេលថតទៅ វាខូច ដល់ហើយ សុំ-- ទៅសុំតាឌុច ៗ ថា គេបញ្ជូនទៅស្រែ ក៏ខ្ញុំទៅតាមថតស្រែ ទៅកន្លែងធ្វើស្រែ ធ្វើស្រូវហ្នឹងណ៎ា។

[១១:២៣:៣៣]

**ស៖** ប៉ុន្តែរូបថតហ្នឹងគេថតកន្លែងណាដែរ? តើគេថតអ្នកទោសនៅក្នុងបរិវេណស-២១មែនទេ?

**ឆ៖** ស-២១ តែខូច ខូចហើយ ដល់ពេលខ្ញុំលាងហើយកាលនោះ គាត់បញ្ជូនអ្នកអត់រឿងអី គ្មានពាក់ព័ន្ធអី គាត់បញ្ជូនទៅធ្វើស្រែ។

**ស៖** អ៊ីចឹង ឌុច ប្រាប់ថាឲ្យទៅថតនៅស្រែទៅ គឺនៅព្រៃសនោះ? តើលោកទៅខ្លួនឯងនៅក្នុងហេតុការណ៍នេះមែនទេ? ហើយតើលោកចាំអ្នកដែលលោកបានថតកាលពីម្សិលមិញហ្នឹង គឺថាអ្នកដែលលោកថត ហើយខូចហ្នឹង លោកចាំដោយរបៀបណា?

**ឆ៖** ចាំលេខរៀង ផ្នែកបន្ទាប់ ចាំហ្វីលតាមលេខរៀង។ ដល់ទៅ ពេលថតផ្តិតអី វាបាត់ ខូច ឈ្មោះប៉ុន្មាន ទៅដល់ ធី។ ប្រាប់ហើយ។ ប្រាប់បានខ្ញុំយកអាហ្នឹងទៅសុំ តាឌុច ឡើងទៅថតស្រែវិញ។

**ស៖** តើនៅស្រែហ្នឹង គឺវាមានអគារ ដូចនៅស-២១ ដែរឬទេ? ថាតើនៅព្រៃសហ្នឹង លោកថតរូបអ្នកទោសដោយរបៀបណាដែរ?

**ឆ៖** *(មិនឮសំឡេង)*

**ប្រធានអង្គជំនុំ៖**

លោកសាក្សី ចាំឆ្លើយ មីក្រូហ្វូនដំណើរការសិន ចាំឆ្លើយ។

**លោក នឹម អ៊ឹម៖**

**ឆ៖** ដាក់យកប្រដាប់ថតបញ្ចាំងកុននៅតាមផ្ទះ យកទៅ ឲ្យទៅថត។ ហើយធ្វើរបាំងវាំងននក្រោយហ្នឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺអង់គ្លេសមាន -- គឺឯកសារ E3/7639, អង់គ្លេសមានលេខ 00162736, ខ្មែរមានលេខ 00162713, បារាំងមានលេខ 00338079។ លោកបាននិយាយដូចតទៅនេះ គឺគេសួរលោកថា៖ “ករណីទាំងអស់ដែលលោកត្រូវថតឡើងវិញនៅព្រៃស តើលោកត្រូវថតញឹកញាប់ដែរឬទេ?” លោកឆ្លើយថា៖ “នៅពេលដែលរូបថតខូច ខ្ញុំត្រូវត្រឡប់ទៅថតនៅព្រៃសវិញ ប្រហែលជាពីរបីដងក្នុងមួយឆ្នាំ។” តើវាត្រឹមត្រូវដែរឬទេ ដែលថាអ្វីដែលខ្ញុំរៀបរាប់ហ្នឹង វាជាហេតុការណ៍ត្រឹមត្រូវ?

[១១:២៦:៥០]

**ឆ៖** បាទ ពិតមែនហើយ។ ព្រោះតែខូច ខ្ញុំសុំគាត់ទៅថតវិញហើយ។

**ស៖** ឥឡូវនេះ ខ្ញុំសួរលោកអ៊ីចេះវិញ។ អ្នកទោសដែលត្រូវបានថតនៅទួលស្លែង ដែលក្រោយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពេលដែលថតហើយហ្នឹង ពួកគាត់ទៅណាដែរ លោកដឹងទេ?

**ឆ៖** ព្រោះខ្ញុំអត់បានដឹងសុទ្ធពីរឿងការងារអស់ហ្នឹង។ ដឹងថាពេលដែលថតហើយ គឺមកផ្តិតតែរៀបចំបញ្ជូនទៅឯណា អាហ្នឹងលើខាងផ្នែកគេផ្សេង។

**ស៖** ឥឡូវនេះ ខ្ញុំអាននូវអ្វីដែលលោកឆ្លើយជាមួយខាងសហចៅក្រមស៊ើបអង្កេតគឺ ERN ដដែលហ្នឹង គ្រាន់តែខ្ញុំ គឺគេសួរថា៖ “ក្រោយពេលដែលថតរូបហើយ តើអ្នកទោសទៅណាដែរ?” ហើយលោកបានឆ្លើយដូចតទៅនេះ៖ “អ្នកទោសដែលថតហើយ ភាគច្រើនគេបញ្ជូនទៅធ្វើស្រែ។ តែក្រៅពីហ្នឹងទៀត ខ្ញុំអត់បានដឹងទេ។ ហើយអ្នកទោសដែលបញ្ជូនទៅធ្វើស្រែ ច្រើនអ្នកតូចៗទេ។ ខ្ញុំទៅតាមថត ខ្ញុំឃើញទៅធ្វើស្រែវិញ។” លោកចាំទេ ថាលោកបានឆ្លើយបែបនេះ ប្រាប់អ្នកស៊ើបអង្កេតរបស់ខាងការិយាល័យសហចៅក្រមស៊ើបអង្កេត?

**ឆ៖** ព្រោះដែលខ្ញុំតាមថតនេះ ឃើញថាកន្លងមក ខ្ញុំថតនេះហើយខូចហ្នឹង គឺតែខូច ខ្ញុំតាមថតមកវិញ។ ដោយឃើញថា មនុស្សវាទៅនោះច្រើន ហើយរាប់ពាន់ដែរណ៎ា មានទាំងនារី មានទាំងប្រុសមានទាំងស្រី។ ព្រោះកន្លែងហ្នឹងកន្លែងធ្វើស្រែផង ធ្វើឡោតផង ចិញ្ចឹមគោ ចិញ្ចឹមជ្រូកអីហ្នឹង។

[១១:២៨:៣៦]

**ស៖** តើលោកចង់និយាយយ៉ាងម៉េច ចង់មានន័យថាម៉េច ដែលថាអ្នកទោសដែលបញ្ជូនទៅធ្វើស្រែ ច្រើនអ្នកតូចៗទេ។ តើអ្នកតូចៗហ្នឹង លោកចង់សំដៅមានន័យយ៉ាងម៉េចដែរ?

**ឆ៖** សំដៅថាអ្នកមិនមានតួនាទីធំដុំ។ អ្នកដែលតូច កូនចៅតូចតាចហ្នឹង។

**ស៖** ហើយលោកនិយាយថាមានមនុស្សរាប់ពាន់នាក់។ នៅក្នុងកំណត់ហេតុរបស់លោកគឺថាលោកថា<បានឃើញពួក>គេ<>ធ្វើស្រែ។ តើលោកដឹងទេក្នុងចំណោមអ្នកតូចៗដែលទៅធ្វើស្រែនៅព្រៃសហ្នឹង តើគេមានស្រង់ប្រវត្តិរូបរបស់ពួកគាត់ ហើយគេថតរូបនៅស-២១ ដែរឬទេ? តើគេធ្វើអីចឹងដែរទេចំពោះអ្នកតូចៗដែលត្រូវធ្វើស្រែនៅព្រៃសនោះ?

**ឆ៖** ជួនណាបានថតហើយគេបញ្ជូនទៅក៏មាន ជួនណាឃើញ គេយកពីណាមក ខ្ញុំអត់ដឹងទេ ប៉ុន្តែភាគច្រើនថតហើយយក ដែលខ្ញុំបានទៅតាមថតវិញ គឺគ្នាបានច្រើនដែរ ប៉ុន្តែទៅណោះវាឃើញមនុស្សវាច្រើនដែរនៅក្នុងតាមអង្គភាពគេហ្នឹង ប៉ុន្តែដឹងគេកកើតតាំងពីជំនាន់ឆ្នាំណាមក ខ្ញុំអត់ដឹង។

**ស៖** ខ្ញុំសូមអាននូវអ្វីដែល ហ៊ឹម ហ៊ុយ បានឆ្លើយ។ គឺគាត់ឆ្លើយប្រាប់អង្គជំនុំជម្រះទាក់ទងទៅនឹងអ្នកដែលគេបញ្ជូនទៅព្រៃស គឺសក្ខីកម្មរបស់គាត់នៅថ្ងៃ០៣ <ឧសភា> ២០១៦ នៅម៉ោងប្រហែល

<១៥:៣៩> “សំណួរ៖ តើគេធ្លាប់បញ្ជូនមនុស្សទៅពីស-២១ ទៅព្រៃសដែរទេ? ហើយហេតុអ្វី? ហើយ ហ៊ីម ហ៊ុយ ក៏បានឆ្លើយថា៖ គឺគេ<មកពីអង្គភាពផ្ទាល់របស់ពួកគេ ហើយបន្ទាប់មកបាន>មកដល់ ស-២១ ប៉ុន្តែពេលខ្លះគេអត់ដាក់ចូលទៅក្នុងបរិវេណគុកភ្លាមៗនោះទេ គឺគេឈប់នៅផ្លូវធំ ហើយបន្ទាប់ មកទៀត គេបញ្ជូនអ្នកទោសទាំងអស់នោះទៅព្រៃសដើម្បីធ្វើស្រែ។”

[១១:៣២:៣០]

ហើយក្រោមបន្តិចគាត់និយាយអំពីគេៗដឹកមនុស្សតាមឡាន ដឹកមនុស្សចេញពីបរិវេណស-២១ ទៅព្រៃស។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើហ្នឹងជាហេតុការណ៍ដែលលោកនិយាយមែនទេ គឺថានៅពេល ដែល ឌុច ខឹង ដែលថាលោកផ្ដិតរូបថតមិនផ្ដិតហ្វីលខុសអ៊ីចឹងទៅ ឌុច ប្រាប់ឲ្យលោកទៅថតរូបនៅព្រៃ សឡើងវិញ។ អ៊ីចឹងមានន័យថា អ្នកដែលគេបញ្ជូនទៅព្រៃសនោះក៏គេថតរូប<ដោយ>កងរបស់លោក <ដែលធ្វើការ>នៅក្នុងបរិវេណគុកទួលស្លែងដែរ អ៊ីចឹងមែនទេ?

**ឆ៖** អាហ្នឹង ដូចខ្ញុំប្រាប់ថាថតខូចហើយ ដល់ពេលខ្ញុំស្រាវទៅវាបានឈ្មោះហ្នឹង សួរគាត់ គាត់ ថាបញ្ជូនទៅព្រៃស ដូច្នេះខ្ញុំសុំគាត់ទៅតាមថត ក្រែងលោខ្លាចបាត់រូបហ្នឹង។

**ស៖** លោកនិយាយថា កើតប្រហែលពីរបីដងក្នុងមួយឆ្នាំ។ អ៊ីចឹងពេលពីរបីដងក្នុងមួយឆ្នាំដែល ខូចហ្នឹង គឺនៅពេលដែលខូចលោកប្រាប់ ឌុច ។ ប្រាប់ឲ្យទៅស្រែ ទៅថតនៅស្រែវិញ អ៊ីចឹងមែនទេ?

**ឆ៖** បាទ *(ឮមិនច្បាស់)* គាត់ឲ្យខ្ញុំទៅថតវិញ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមើលទៅឃើញថាដល់ម៉ោងហើយប្រហែលជាយើងអាចឈប់សម្រាក។ តើ លោកប្រធានសម្រេចយ៉ាងដូចម្ដេចដែរ?

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ឥឡូវនេះដល់សម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពី ពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

លោក នឹម អ៊ីម ឥឡូវនេះដល់សម្រាកថ្ងៃត្រង់ហើយ លោកអាចសម្រាកបានហើយ អង្គជំនុំ ជម្រះអញ្ជើញលោកមកកាន់កន្លែងផ្ដល់សក្ខីកម្មវិញឲ្យបានមុនម៉ោងមួយកន្លះរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួន ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការ នេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យម៉ោង

មួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:៣៥ នាទី ដល់ម៉ោង ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តសវនាការ។ សូមអញ្ជើញលោកមេធាវី នួន ជា បន្តសំណួរ។ តែអង្គជំនុំជម្រះសូមរំឭកដល់លោកមេធាវីថា លោកបានប្រើពេលវេលាអស់ ៩០នាទីហើយ។ នៅសល់ ៣០ នាទីទៀតសម្រាប់ពីក្រុមរបស់លោក។ សូមអញ្ជើញ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនទៀតដែលខ្ញុំត្រូវសួរលោកនៅពេលនេះ។ ខ្ញុំសូមចាប់ផ្ដើមនៅប្រធានបទថ្មីមួយទៀត។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក E3/7639, អង់គ្លេសមានលេខ 00162739, ខ្មែរមានលេខ 00162715, បារាំងមានលេខ 00338083។ លោកបាននិយាយអំពីការចាប់រំលោភដែលកើតឡើងទៅលើអ្នកទោស។ លោកបាននិយាយថា មានពេទ្យម្នាក់ចាប់រំលោភអ្នកទោស។ តើលោកមានចាំទេថាលោកបានឆ្លើយចម្លើយបែបនេះប្រាប់អ្នកស៊ើបអង្កេត?

**លោក នឹម អ៊ឹម៖**

**ឆ៖** ខ្ញុំបានប្រាប់ដែរ ប្រាប់ឆ្លើយប្រាប់អ្នកស៊ើបអង្កេតដែរ។ ព្រោះហ្នឹងអ្នក--

**ប្រធានអង្គជំនុំ៖**

លោកសាក្សីចាំមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងពណ៌ក្រហមសិន ចាំឆ្លើយ។ លោកសាក្សីអាចលើកមីក្រូហ្វូនឡើងលើបន្តិចមក ដើម្បីឲ្យ បាទៗៗ។

**លោក នឹម អ៊ឹម៖**

**ឆ៖** ព្រោះហ្នឹងបើ បាទ ខ្ញុំបានប្រាប់ម្ដងដែរ ព្រោះកាលហ្នឹងបើអ្នករំលោភហ្នឹងគឺពេទ្យ រំលោភអ្នកទោសហ្នឹង។

[១៣:៣៣:២៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** តើលោកចាំទេគាត់ឈ្មោះអី ហើយតើអ្នកទោសហ្នឹងឈ្មោះអ្វីដែរ? ហើយថាតើពេទ្យហ្នឹងគេត្រូវទៅ តើពេទ្យហ្នឹងត្រូវគេដាក់ទណ្ឌកម្មដែរឬទេ?

**ឆ៖** ឈ្មោះពេទ្យហ្នឹងខ្ញុំភ្លេចហើយ អ្នកដែលនារីដែលពេទ្យរំលោភនោះខ្ញុំអត់បានចាំដែរ។ ហើយប៉ុនក្រោយមក ពេទ្យហ្នឹងត្រូវចាប់ពេទ្យហ្នឹងដាក់គុកដែរ ដាក់គុកប្រហារជីវិតចោលសម្លាប់ចោលដែរ។

**ស៖** តើគេចាប់គាត់ដាក់ទោសហ្នឹង ដោយសារតែគាត់រំលោភអ្នកទោសហ្នឹងមែនទេ?

**ឆ៖** បាទ។

**ស៖** សូមអរគុណ។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកគឺ E3/7639, អង់គ្លេសមានលេខ 00162735, បារាំងមានលេខ 00338078, ខ្មែរមានលេខ 00162712។ លោកបាននិយាយអំពីការថតអ្នកសារព័ត៌មាន<ពីរនាក់>អាចជនជាតិគុយបា ឬក៏ជនជាតិរុស្ស៊ី។ តើលោកចាំទេថា លោកបានផ្ដល់សក្ខីកម្មប្រាប់អ្នកស៊ើបអង្កេតអំពីជនបរទេសនេះ?

**ឆ៖** បានថតអ្នកកាសែតពីរនាក់ដែរ ប៉ុនខ្ញុំភ្លេចមិនដឹងថា គុយបាមិនដឹង អីមិនដឹង ប៉ុនថាកាលហ្នឹងមានដោយមកមានម៉ាស៊ីនថតមួយគ្រឿង មិនដឹងកាលហ្នឹងដូចប៉ង់តាក់ ឬកាណុងទេកាលហ្នឹងមានតែពីរហ្នឹងទេ មានប៉ង់តាក់ និងកាណុង។

**ស៖** នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក លោកនិយាយអំពីម៉ាស៊ីនថតម៉ាកប៉ង់តាក់ជារបស់អាល្លឺម៉ង់។ ខ្ញុំចង់ដឹងថាហេតុអ្វីបានជាលោកត្រូវពិនិត្យមើលម៉ាស៊ីនថតហ្នឹង តើអ្នកណាជាអ្នកបញ្ជាឲ្យលោកពិនិត្យមើលម៉ាស៊ីនថតនោះ?

**ឆ៖** ព្រោះថាមកជាមួយ ដូចកាលនេះមកដោយមក គេហៅខ្ញុំថត ក៏ ឌុច ទៅសួរខ្ញុំតើម៉ាស៊ីនម៉ាកអីដែរ អាហ្នឹងរបស់អាល្លឺម៉ង់ហើយ ប៉ង់តាក់ហ្នឹង។

[១៣:៣៦:៣៤]

**ស៖** ខ្ញុំគិតថានៅរសៀលនេះ ព្រះរាជអាជ្ញានឹងសួរលោកអំពីការថតរូបកុមារហើយ។ នៅក្នុងទំព័រដដែលនៃកំណត់ហេតុស្ដាប់ចម្លើយរបស់លោកដែលខ្ញុំទើបតែអានមុននេះ គឺលោកបាននិយាយថាគឺលោកមិនដែលថតកុមារទេ។ តើវាត្រឹមត្រូវដែរឬទេ?

**ឆ៖** ព្រោះកុមារខ្ញុំអត់ដែលបានថតទេ ក្រែងលោកូនចៅខ្ញុំវាថតណ៎ា ព្រោះកាលហ្នឹងខ្ញុំតែស្អី

នេះល្អមៗ ខ្ញុំអត់ដែលចុះទៅទេ បើថាគ្នាច្រើនបានខ្ញុំចុះទៅហ្នឹង។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ។ លោកគឺជាមនុស្សដែលទទួលខុសត្រូវសំខាន់នៅក្នុងការលាងហ្វីលរូបថត ហើយខ្ញុំដឹងថាមានហ្វីលរាប់ពាន់ហ្វីលត្រូវបានគេយកមកលាង ប៉ុន្តែលោកចាំទេថាលោកធ្លាប់ឃើញហ្វីលរូបថតកុមារនៅពេលដែលលោកលាងហ្វីលនោះ?

**ឆ៖** វាច្រើនពេក ដូចថាការចងចាំហ្នឹងវាមានបញ្ហា។ វាមានដែរ ប៉ុនតិចតួច វាធ្លាប់ដែលឃើញណំា ប៉ុន្តែរឿងឲ្យបានទាំងកុមារច្រើនៗមិនដែលជួបទេ។

**ស៖** ដូចនេះនៅពេលដែលលោកលាងហ្វីល <>លោក<ចាំថា>ធ្លាប់បានឃើញរូបថតកុមារ <តែកម្រឃើញណាស់> តើលោកអាចគិតមើលថាវាមានប្រហែលជាប៉ុន្មានភាគរយដែរ? ប្រសិនបើធៀបជាមួយនឹងចំនួនសរុបហ្នឹង តើហ្វីលរូបថតកុមារដែលលោកលាងហ្នឹងមានប្រហែលជាប៉ុន្មានភាគរយដែរ?

**ឆ៖** ប្រហែលជាខ្ទង់ បើតាមខ្ញុំនេះ ប្រហែលជាខ្ទង១០ភាគរយទេតាមមើល។

**ស៖** តើអាចទេថាត្រឹមតែមួយភាគរយ ទៅពីរភាគរយនោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី -- លោកព្រះរាជអាជ្ញា។

[១៣:៣៩:៣៥]

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ គាត់សួរសំណួរ ហើយសាក្សីផ្តល់ចម្លើយ<ប៉ាន់ស្មានមួយ> ហើយមេធាវីគាត់មិនពេញចិត្ត ឥឡូវស្រាប់តែមកមេធាវីមកដាក់នៅតួលេខដែលគាត់ពេញចិត្តទៅវិញ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<បើ>មានមូលដ្ឋានដែលអាចកំណត់នូវភាគរយនេះបាន <សូមបង្ហាញមក>។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំអាចសួរបាននូវសំណួរទាំងអស់នេះ បន្ទាប់ពីខ្ញុំសួរបើក សំណួរបើក។ ដូច្នេះ តើវាអាចទេថាភាគរយនោះវា ពេលលោកដែលលោកនិយាយនោះ វាអាចច្រើនហួសហេតុ និងថាតើវាត្រឹមតែមួយ ឬក៏ពីរភាគរយទេ ឬក៏យ៉ាងម៉េចដែរ?

[១៣:៤០:២០]

**E1/474.1**

**លោក នឹម អ៊ឹម៖**

**ឆ៖** ព្រោះទៅ កុមារ ខ្ញុំឃើញកាលលាង ការផ្ដិតខ្ញុំមិនដែលបានទេ គ្រាន់តែលាងហើយនេះ ប៉ុនថាឃើញនោះ វាមកម៉ាហ៊ុក ឃើញម៉ែឪមកដោយជាមួយហ្នឹងមែន។ ប៉ុនថាឲ្យលើសលប់ ឲ្យរាប់រយរាប់ពាន់នាក់ -- រាប់រយ បួនដប់ម្ភៃសាមសិបនាក់ គ្មានទេណ៎ា។ តែបើត្រឹមក្នុងមួយនៅធ្វើការហ្នឹង ខ្ញុំដឹងថា ប្រហែលជាបួនប្រាំនាក់ អីដប់នាក់ប៉ុណ្ណឹងទេ។ កន្លែងខ្លះអត់បានថតផង កុមារហ្នឹង។

**ស៖** តើលោកចាំថា ធ្លាប់ឃើញកុមារនៅព្រៃសទេ នៅពេលដែលលោកទៅព្រៃសនោះ?

**ឆ៖** ព្រោះទៅនោះ វាមិនដែលឃើញទេ បើក្រែងខាងខេត្តផ្នែកអីនៅជាមួយនារីមិនដឹង បើថាខាងបុរស នេះទេ ព្រោះនៅព្រៃសមានអង្គភាពនារី អង្គភាពបុរស។ អត់នៅចូលជាមួយគ្នាទេ អង្គភាពដោយឡែកៗគ្នា។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅលើការសួរសំណួរពាក់ព័ន្ធទៅនឹងកម្មាភិបាលដទៃទៀតដែលធ្វើការនៅស-២១។ លោកបាននិយាយអំពី ឌុច។ លោកក៏បាននិយាយអំពីលេខរៀងទី២ នៅស-២១ គឺ ហ៊ី នៅក្នុងកំណត់ហេតុរបស់លោក។ តើលោកចាំអំពី ហ៊ី នេះទេ?

**ឆ៖** ចាំ។

[១៣:៤២:១៤]

**ស៖** តើលោកចាំអ្វីខ្លះទាក់ទងឈ្មោះហ៊ី នេះ?

**ឆ៖** ហ៊ី ខ្ញុំកាលនៅ អាហ្នឹងនៅក្នុងស-២១ ហ៊ី គេខាងអនុប្រធាន។ នៅនេះ ហើយ ហ៊ី ហ្នឹង គាត់ខូចភ្នែកម្ខាង។ ប៉ុន្តែពេលដល់ពេល ពេលយួនវ៉ៃចូលរត់ទៅភ្នំ ពីរនាក់ហ្នឹងអត់សូវត្រូវគ្នាទេ បើតាមខ្ញុំសង្កេតមើលណ៎ា។ គឺ ហ៊ី វាមិនសូវតាម ឌុច ប៉ុន្មានទេ។ តែដល់បែក វាចូល ដូចថាអត់មានការគ្រប់គ្រងពីលើមកទៀត។

**ស៖** តើលោកដឹងអំពីភារកិច្ចរបស់កងពល ទាក់ទងទៅនឹង ឌុច ហើយ ហ៊ី នោះទេ?

**ឆ៖** ព្រោះពេលហ្នឹង ខ្ញុំអត់ចាប់អារ-- ព្រោះអត់មានការដឹងឮដែរ។ ដឹងថា បទបញ្ជាមាន បើថានិយាយពីលើ មានខាងក្រសួងការពារសន្តិសុខ ខាងក្ដាប់សន្តិសុខទូទាំងប្រទេស។ មានតែថាពាក់ព័ន្ធពីហ្នឹងមកទេ ព្រោះខ្ញុំឮថា តាឌុច គាត់ហៅតាកុងៗ ដល់ស្រាវជ្រាវ តាកុង មានតែម្នាក់ហ្នឹង មានតែសុន សេន។

[១៣:៤៣:៥៥]

**ស៖** ឥឡូវនេះ ខ្ញុំសូមអាននូវសម្រង់មួយចំនួនដកស្រង់ចេញពីសក្ខីកម្មរបស់ ឌុច ទាក់ទងទៅនឹងការបែងចែកភារកិច្ចនិងការទទួលខុសត្រូវរវាង ឌុច ហើយនិង ហ៊ី។ ខ្ញុំនឹងអាននូវសម្រង់ប្រហែលជាបីទៅបួន គឺជាសម្រង់ដែលគាត់បញ្ជាក់ប្រហែលជាប៉ុន្មានខែមុននៅក្នុងតុលាការនេះ។ គឺថា ខ្ញុំនឹងពន្យល់អំពីសម្រង់នេះ។ បន្ទាប់មកទៀត ខ្ញុំនឹងបង្ហាញនូវឯកសារយោង ឌុច បាននិយាយអំពី ហ៊ី។ "ខ្ញុំទទួលខុសត្រូវតែទៅលើអ្នកទោសសំខាន់ៗ សម្រាប់អ្នកទោសផ្សេងៗទៀត គឺហ៊ី គឺជាអ្នកទទួលខុសត្រូវលម្អិត។ ហ៊ី ចាត់ចែងលើផ្នែក លើតំបន់ភ្នំពេញនិងវិស័យដទៃទៀត សូម្បីតែការអានឯកសារ ឬក៏អានចម្លើយជាដើម។ អ្វីៗទាំងអស់ដែលទាក់ទងនឹងផ្នែកភ្នំពេញ គឺត្រូវឆ្លងកាត់ ហ៊ី មុននឹងមកដល់ខ្ញុំ។ ហ៊ី ចាត់ចែងលើការងារប្រចាំថ្ងៃនៅស-២១ ហើយគាត់ក៏ជាអ្នកគ្រប់គ្រងផងដែរ វាជាការពិត។ ចំពោះយុទ្ធជនធម្មតា គឺគាត់ជាអ្នកគ្រប់គ្រងទាំងស្រុង <ហើយគាត់អាចបញ្ជាឲ្យ>ធ្វើទារុណកម្ម។" ខ្ញុំនឹងប្រាប់លោក ថាតើលោកអាននៅកន្លែងណានេះ។ ដូច្នេះ តើលោកយល់យ៉ាងម៉េចដែរ អំពីការបែងចែកភារកិច្ចរវាង ហ៊ី ហើយនិង ឌុច នេះ លោកសាក្សី?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកព្រះរាជអាជ្ញា!

[១៣:៤៦:០៩]

**លោក ខេល លីសាក់៖**

ខ្ញុំមិនយល់ ហេតុអ្វីបានជាត្រូវរង់ចាំដល់សាក្សីឆ្លើយហើយ ទើបផ្តល់លេខ ERN និងផ្តល់លេខឯកសារនោះ? ហេតុអីក៏មិនផ្តល់មុនពេលដែលសាក្សីឆ្លើយទៅ ដើម្បីឲ្យតុលាការអាចឆែកពិនិត្យមើល? <ខ្ញុំស្នើឲ្យលោកផ្តល់លេខយោងមុននឹងសាក្សីឆ្លើយនឹងសំណួរ។>

**លោក វ៉ិចទ័រ កូប៉េ៖**

ដោយសារតែវាមានលេខច្រើន ហើយត្រូវការពេលវេលា។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ផ្តល់មកតែម្តងទៅ។

**លោក វ៉ិចទ័រ កូប៉េ៖**

<E3/5748>, អង់គ្លេសមានលេខ <00153568>, បារាំងមានលេខ 0013445 *(ស៊ីក),* ខ្មែរមានលេខ <00153459>, ពីរ E3/1570, អង់គ្លេសមានលេខ 0015--

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**អ្នកបកប្រែ៖**

លោកប្រធាន ស្នើឱ្យមេធាវីអានលេខឱ្យបានយឺតៗ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមលោកអានលេខ ERN ឱ្យបានយឺតៗបន្តិច ដើម្បីសម្រួលដល់អ្នកបកប្រែ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <E3/1570> អង់គ្លេស <00154193>, <ភាសាខ្មែរ>មានលេខ 00154223, បារាំងមានលេខ 00154208។ E3/5792។ នៅម៉ោង <១១:៤៣> E3/5771, អង់គ្លេសមានលេខ 00185500, ខ្មែរមានលេខ 00185492, បារាំងមានលេខ 00185509។ គឺគាត់និយាយប្រហែលជាប៉ុន្មានខែមុននេះ នៅក្នុងតុលាការនេះថា ហើយមានពេលដែលមានការអានសម្រង់ ហើយ ឌុច គាត់អះអាង។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំគិតថាលោកប្រហែលជាចាំនូវអ្វីដែលខ្ញុំអាន គឺទាក់ទងទៅនឹង ឌុច ដែលនិយាយថា ហ៊ី គាត់ទទួលខុសត្រូវទៅលើអ្នកទោសដែលមិនសូវសំខាន់ ហើយគាត់ចាត់ចែងលើការងារប្រចាំថ្ងៃក្នុងផ្នែកតំបន់ភ្នំពេញ ហើយនិងយុទ្ធជនសាមញ្ញធម្មតាៗ <ហ៊ី គ្រប់គ្រងអ្វីៗទាំងអស់>។ តើវាត្រឹមត្រូវទេ ឬមួយក៏លោកយល់ ឬក៏លោកមានព័ត៌មានផ្សេងពីនេះ?

[១៣:៤៨:៤៧]

**លោក នឹម អ៊ឹម៖**

**ឆ៖** អុំ ! អាហ្នឹង ខ្ញុំក្ដាប់អត់ជុំដែរ ព្រោះខ្ញុំអត់បានដឹងឮពាក្យខាងគាត់ អនុប្រធានហ្នឹង។ គ្រាន់តែកន្លងមក ឃើញថា ខាងនេះ គាត់ តាឌុច គាត់ឧស្សាហ៍ទាក់ទងជាមួយ តាហ៊ី ហ្នឹង មិនដឹងគាត់រៀបចំរបៀបម៉េច ព្រោះខ្ញុំដឹងតែមុខជំនាញខ្ញុំ ដឹងតែថតនិងផ្ដិត។

**ស៖** មិនអីទេលោកសាក្សី។ ឥឡូវនេះ ខ្ញុំបន្តទៅប្រធានបទថ្មីមួយទៀត។ លោកបាននិយាយអំពីកម្មាភិបាលម្នាក់ទៀត ដែលធ្វើការនៅស-២១ ឈ្មោះ ស្រ៊ី។ តើលោកចាំឈ្មោះ ស្រ៊ី? ខ្ញុំមិនច្បាស់ថា ស្រី ឬក៏ ស្រ៊ី ទេ។

**ឆ៖** ព្រោះឈ្មោះ ស្រ៊ី នេះជាបក្ខជន ខាងមើលការខុសត្រូវអ្នកធំៗ យាមកាមអ្នកធំៗ។ ដល់ហើយ តាំងពី -- កាលនោះគាត់ចាប់ផ្ដើម -- តាឌុច ឱ្យមកសុំម៉ាស៊ីនថត ហើយនិងម៉ាស៊ីនផ្ដិត ក្រដាសអីហ្នឹង ខ្ញុំក៏ឱ្យទៅ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** អ៊ីចឹងគាត់ត្រូវការម៉ាស៊ីនថតសម្រាប់ភារកិច្ចរបស់គាត់ ទាក់ទងទៅអ្នកទោសសំខាន់ៗដែរ

ឬទេ?

[១៣:៥០:៤៥]

**ឆ៖** ព្រោះកន្លងមកខ្ញុំអ្នកថតផ្តិត ដល់សាក្រោយហ្នឹងមិនដឹងម៉េច ខ្ញុំមិនមែនអ្នកនេះ យក ឲ្យតាស្រ៊ី ហ្នឹងមកសុំប្រដាប់ថត ប្រដាប់ផ្តិតអីហ្នឹង ហ្វីលក្រដាស ខ្ញុំបញ្ជូនឲ្យ យកឲ្យទៅៗ។ ព្រោះមិនដឹងថា គេច្រើននេះ ព្រោះសុទ្ធអ្នកធំៗមកបាននេះ ព្រោះខ្ញុំកន្លងមកមិនដែលជួបថតអ្នកធំៗសុទ្ធ ព្រោះខ្ញុំអង្កាល់ហ្នឹងមិនទាន់ចូលស្អីទេ នៅយុវជននៅឡើយហ្នឹង។

**ស៖** អ៊ីចឹងលោកគិតថា គាត់ជាអ្នកថតរូបអ្នកទោសសំខាន់ៗដែលចូលមកមែនទេ? អ៊ីចឹងបានន័យថា នៅពេលដែលថតអ្នកទោសសំខាន់ៗ គឺគាត់ជាអ្នកថតមែនទេ?

**ឆ៖** បាទ ព្រោះអ្នកធំៗខ្ញុំមិនដែលបានថតទេ កូនចៅខ្ញុំក៏វាអត់ដែលបានថតដែរ។

**ស៖** តើលោកនិងសមាជិកពីរនាក់ទៀត សុង ហើយនិង និត ដែលធ្លាប់ថតរូបអ្នកទោសដែលស្លាប់ទេ?

**ឆ៖** មានៗ ពេលខ្លះបានគេវ៉ៃងាប់ហើយ ឡើង -- គេហៅឲ្យទៅថតទៅ។ មានគេវ៉ៃងាប់ ស្លួរចម្លើយងាប់ ទៅដល់ៗដាក់ដល់កន្លែងគុកឃុំឃាំង។

[១៣:៥២:៣៧]

**ស៖** ខ្ញុំមានសំណួរច្រើន ប៉ុន្តែខ្ញុំត្រូវរំលងចោលដោយសារពេលវេលា។ លោកសាក្សី តើលោកធ្លាប់ថតរូបវៀតណាម គឺថតរូបទាហានវៀតណាមទេ?

**ឆ៖** បាទ ធ្លាប់ថត។

**ស៖** តើលោកចាំថាថតអ្វីខ្លះ ថាតើអ្នកដែលលោកថតហ្នឹងជាទាហានវៀតណាម ឬក៏កម្មាភិបាលវៀតណាម? តើលោកចាំអីខ្លះពីការថតរូបវៀតណាមនោះ?

**ឆ៖** ឃើញគេបញ្ជូនមកពាក់ខោអាវវៀតណាម ហើយគាត់គេឲ្យថត។ អត់មានអី មានថតជាកំណាត់ខ្លួនដូចអ្នកទោសធម្មតាអ៊ីចឹង ដែលគេថាអ្នកទោសធម្មតាហ្នឹង។

**ស៖** តើមានករណីណាខ្លះ ដូចជាថា អ្នកខ្លះមិនមែនជាទាហានវៀតណាមទេ ប៉ុន្តែពួកគាត់ត្រូវគេបង្ខំឲ្យពាក់ខោអាវជាទាហានវៀតណាម។ តើធ្លាប់មានករណីអ៊ីចឹងទេ?

**ឆ៖** ខ្ញុំអត់ដែលដឹងដែរអាហ្នឹង។

[១៣:៥៤:១៦]

**ស៖** ឥឡូវនេះ ខ្ញុំសូមរំលងប្រធានបទខ្លះ ហើយខ្ញុំសួរសំណួរចុងក្រោយ<>។ ព្រឹកមិញលោកបាននិយាយអំពីផ្ទះដែលលោក សុង ហើយនិង និត រស់នៅទីនោះ។ ហើយជាកន្លែងដែលលោកប្រើប្រាស់បន្ទប់ងងឹតដើម្បីលាងហ្វីល ហើយលោកបាននិយាយថា ផ្ទះហ្នឹងនៅជិតផ្ទះ ឌុច ប្រហែលជា៥០ ទៅ ៧០ម៉ែត្រ គឺនៅផ្លូវ៣១៨ -- ៣៤៨ តើលោកចាំទេថា តើលោកស្គាល់ពីផ្ទះវីឡាមួយ ដែលឥឡូវហ្នឹងជាស្ថានីយវិទ្យុសំបុកឃ្មុំនៅតាមផ្លូវ៣៦០ទេ? គឺជាកន្លែងដែលអ្នកទោសគេយកមកប្រមូលផ្តុំ។ តើលោកចាំអំពីអគារនោះទេ?

**ឆ៖** អ៊ូ! ខ្ញុំទៅមើលប៉ុន្មាន នៅខែ៨ហ្នឹងទៅ រកកន្លែងផ្ទះហ្នឹងវាភ្លេចអស់ហើយ វាក៏ដឹងថាផ្លូវថាលូទឹកស្អុយឆ្លងលូទឹកស្អុយមែន តែឥឡូវវាផ្ទះគេប្រែថ្មីអស់ហើយ។

**ស៖** លោកនិយាយពីអំពីសីហា សីហាឆ្នាំហ្នឹង គឺខែមុនហ្នឹងមែនទេ?

**ឆ៖** ខ្ញុំមកលេងហ្នឹងខ្ញុំទៅមើលទៅរក វាប្លែកអស់ ផ្ទះវាណែនប៉េះអស់ហើយ។

**ស៖** ប៉ុន្តែខ្ញុំចង់សួរថាលោកទៅស្ថានីយវិទ្យុសំបុកឃ្មុំនៅតាមផ្លូវ៣៦០ហ្នឹងនៅពេលណា? ថាតើលោកទៅនៅក្នុងខែសីហា ឆ្នាំ២០១៦ ហ្នឹង គឺខែមុនហ្នឹងមែនទេ?

**ឆ៖** ២០១៦ ហ្នឹងប៉ុនទៅមួយអង្គការ ខាងអ្នកចងប្រវត្តិសាស្ត្រ។ គាត់ទៅឲ្យជូនខ្ញុំឲ្យ ទៅសួរមើលកន្លែងនេះ ធ្លាប់ផ្ទះ មានផ្ទះអីចឹងអត់។ ខ្ញុំថាអត់ទេ ផ្ទះពីដើមមកអត់សូវមានផ្ទះកកកុញអីចឹងទេ។

**ស៖** វាគួរឲ្យអារម្មណ៍មែនលោកសាក្សី។ <តើ>នៅក្នុងខែសីហា លោកមានបានទៅមើលផ្ទះដែលលោកស្គាល់ដែលលោកថាលោកស្គាល់ព្រឹកមិញនេះទេ? គឺផ្ទះនៅផ្លូវ៣៤៨ ដែលលោកហើយសុង ហើយនិង និត ស្នាក់ហ្នឹងទេ តើផ្ទះហ្នឹងវានៅស្ថានភាពដដែល ឬមួយក៏ប្រែប្រួលហើយ?

**ឆ៖** ប្រែប្រួលអស់ហើយ។

[១៣:៥៧:៣១]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំសោកស្តាយយ៉ាងខ្លាំងដែលខ្ញុំបញ្ចប់ពេលវេលាខ្ញុំរួចហើយ។ ដូច្នេះ ខ្ញុំសូមបញ្ចប់ការសួរសំណួរ ហើយសូមអរគុណផងដែរលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

ជាបន្ត មុននឹងផ្តល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញា ដើម្បីតាំងសំណួរទៅកាន់សាក្សីរូបនេះ

អង្គជំនុំជម្រះត្រូវការស្តាប់ការកត់សម្គាល់របស់ភាគីនានា ពាក់ព័ន្ធនឹងការកោះហៅសាក្សីដែលមានរហស្សនាម 2-TCW-1065 ដែលបានផ្តល់ចម្លើយនៅក្នុងឯកសារ E319/43.3.9-11។ កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីតាមរយៈអ៊ីម៉ែលថា អង្គជំនុំជម្រះកំពុងពិចារណាក្នុងការកោះហៅសាក្សីបន្ថែមម្នាក់ទៀត ដែលមានរហស្សនាម 2-TCW-1065 ពាក់ព័ន្ធនឹងអង្គហេតុ ស្ថានភាពនៃជម្លោះប្រដាប់អាវុធ ហើយអញ្ជើញឲ្យភាគីធ្វើការកត់សម្គាល់ទៅលើបញ្ហានេះ។ នៅពេលនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាក្នុងការធ្វើការកត់សម្គាល់មុនភាគីដទៃទៀត។ សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[១៣:៥៨:៥៨]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំបានមើលកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីរូបនេះ ហើយទស្សនៈរបស់យើងខ្ញុំយល់ឃើញថា វាសាក្សីមួយដ៏សំខាន់ដែលតាមការយល់ឃើញរបស់យើង គឺថា គាត់អាចនិយាយរឿងរ៉ាវច្រើនមិនមែនមានតែជម្លោះប្រដាប់អាវុធទេ។ គាត់អាចឆ្លើយអំពីការបោសសម្អាតនៅភូមិភាគបូព៌ា ហើយមានអ្វីកើតឡើងនៅភូមិភាគនោះ។ ដូច្នេះ តាមការយល់ឃើញរបស់យើងខ្ញុំគាត់គឺជាសាក្សីមួយដ៏សំខាន់ ដែលអង្គជំនុំជម្រះគួរតែកោះហៅ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី សូមធ្វើការកត់សម្គាល់។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងគោរពតាមការវិនិច្ឆ័យរបស់អង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី នួន ជា!

[១៤:០០:១២]

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំយល់ឃើញថា ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន គឺថាគាត់មានចំណាប់អារម្មណ៍ខ្លាំងចំពោះសាក្សីរូបនេះ។ អ៊ីចឹង សូមឲ្យក្រុមមេធាវីរូបនេះឡើងនិយាយមុន ខ្ញុំតាមពីក្រោយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អញ្ជើញលោកមេធាវីការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន ដែលផ្ដល់វេទិកាមកខ្ញុំ។ ខ្ញុំសូមនិយាយថា យើងចូលដល់ដំណាក់កាលមួយ ដែលយើងត្រូវធ្វើការកត់សម្គាល់ទាក់ទងទៅនឹងការសម្រេចកោះហៅសាក្សី <2-TCW-1065> នេះ របស់អង្គជំនុំជម្រះ។ ឥឡូវនេះ យើងខាងមេធាវី ខៀវ សំផន ហ្នឹង យើងកំពុងតែវិល វីវក់អារម្មណ៍អស់ហើយ។ ខ្ញុំសូមពន្យល់។ ខ្ញុំខំព្យាយាមរកពាក្យឲ្យត្រឹមត្រូវដើម្បីនិយាយអំពីអារម្មណ៍របស់យើង។ កាលប្បវត្តិវាចោទជាបញ្ហាចំពោះសាក្សីរូបនេះ ថ្ងៃទី២២ មីនា ឆ្នាំ២០១៦ គឺប្រហែលជា៦ខែកន្លងទៅនេះ មានកំណត់ហេតុស្ដាប់ចម្លើយបីបានផ្ដល់ជូនដោយព្រះរាជអាជ្ញា នៅក្នុងក្របខ័ណ្ឌនៃកាតព្វកិច្ចដែលត្រូវផ្ដល់ភស្តុតាងដោះបន្ទុក ហើយនេះវាចេញពីសេចក្ដីសម្រេចដែលអង្គជំនុំជម្រះបានចេញ <ក្នុងអំឡុងពេល>ដែលកំណត់ឲ្យកម្រិត<ការពិភាក្សា។> ហើយថ្ងៃទី៤ ខែ៨ ឆ្នាំ២០១៦នោះ គឺមានពិភាក្សាអំពីឋានៈនៃឯកសារដែលបញ្ជូនមកនេះ ហើយក្រុម ខៀវ សំផន បានពន្យល់ថា យើងត្រូវតែមានលទ្ធភាពឆ្លើយតបទៅនឹងការដាក់បង្ហាញឯកសារទាំងអស់នេះ <ឬក៏យ៉ាងហោចណាស់ដើម្បីដឹងថា តើការដាក់បង្ហាញឯកសារនេះ>សមស្របទៅតាមលក្ខណៈវិនិច្ឆ័យដែលអង្គជំនុំជម្រះបង្គាប់ឲ្យគោរពដែរ ឬក៏អត់។ តាមរយៈចៅក្រម ឡាវែន៍ អង្កាល់នោះ បើអង្គជំនុំជម្រះបានឆ្លើយថា មិនមានព្យសនកម្មអីនោះទេ ពីព្រោះមាននៅក្នុង *ស៊ែជ្រាយ* ហើយៗ ហើយ<មិនទាន់>បានបញ្ចូលទៅក្នុងសំណុំរឿង<ទេ>។ អង្កាល់នោះ ខ្ញុំបានព្យាយាមរកឈ្មោះនោះ ហើយអង្គជំនុំជម្រះគាត់បានបន្តទទួលទៀត <ហើយនៅក្នុងការពិភាក្សាផងដែរ គឺថាមានការបង្ហាញ>ឯកសារដែលមកពី<សំណុំរឿង> <00៣>, <00៤> នុំង<ដោយសហព្រះរាជអាជ្ញា។> ហើយកាលនោះ អង្គជំនុំជម្រះបានកំណត់សម្រេចហៅឈ្មោះ មុយ <វ៉ាន់នី។ ដូច្នេះពេលនេះយើងស្ថិតក្នុងស្ថានភាពដូចគ្នា>។ <មានរយៈពេល> ៦ខែ<ចន្លោះរវាង>ឯកសារដោះបន្ទុក <ដែលត្រូវបានបង្ហាញដោយសហព្រះរាជអាជ្ញា ប៉ុន្តែថ្ងៃនេះ> ខាងព្រះរាជអាជ្ញាគាត់ផ្លាស់ប្តូរ ហើយ<ទាំងខាងសហព្រះរាជអាជ្ញា ទាំងខាង>មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនុំង ទាំងពីរនាក់ហ្នឹង <ជឿថា ឯកសារទាំងនេះគឺ>--

[១៤:០៣:១៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមលោកស្រីយឺតបន្តិច ពីព្រោះបកប្រែទៅភាសាអង់គ្លេស គឺថាពិបាកតាមលោកស្រី។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំព្យាយាមនិយាយឲ្យយឺតជាងនេះបន្តិច។

ដូចនឹងករណី មុយ វ៉ាន់នី ដែរនេះ គឺថាយើង ឥឡូវហ្នឹងយើងមានសាក្សីមួយទៀត ដែលត្រូវបានកំណត់អត្តសញ្ញាណថាជាសាក្សីដោះបន្ទុក ព្រះរាជអាជ្ញាគាត់ថាអ៊ីចឹង។ ហើយគាត់បានផ្តល់កំណត់ហេតុស្តាប់ចម្លើយរបស់គាត់នុ៎ងមក ថាគាត់ហ្នឹងមិនចាំបាច់គោរពតាមវិធាន៨៧(៤)ទេ ដើម្បីបញ្ចូលឯកសារនេះជាភស្តុតាង ឬរឿងសាក្សីនោះ។ តែសព្វថ្ងៃនេះ ឃើញថាដូចមានព្រះរាជអាជ្ញាហ្នឹងផ្លាស់ប្តូរគោលជំហរ។ យើង ហ្នឹងដែលយើងគិតថា ភស្តុតាងហ្នឹងជាភស្តុតាងដោះបន្ទុក។ អ៊ីចឹងយើងថា មិនចាំបាច់កោះហៅទេ ហើយអង្គាល់នោះៗ អង្គជំនុំជម្រះទំនងដូចជា ចង់កោះហៅសាក្សីរូបហ្នឹងមក។ ប៉ុន្តែឥឡូវនេះ យើងចូលមកដល់ដំណាក់កាលមួយពិសេសនៃនីតិវិធីហើយ តាមសេចក្តីសម្រេចមួយចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ អង្គជំនុំជម្រះអង្កាល់នោះនុះ បានទទួលកំណត់ហេតុស្តាប់ចម្លើយបីតាំងពីខែ មីនា ២០១៦ មកម្ល៉េះ ហើយអង្គជំនុំជម្រះមិនបានដាក់ចូលក្នុងបញ្ជីនៅក្នុងវគ្គពិភាក្សាគ្នាអំពីជម្លោះប្រដាប់អាវុធទេ។ ក៏ប៉ុន្តែដល់<ថ្ងៃទី១៣>ខែកញ្ញា គឺពីរថ្ងៃមុននេះ យើងបានទទួលអ៊ីម៉ែលមួយដែលបញ្ជាក់ប្រាប់ថា អង្គជំនុំជម្រះចង់កោះហៅសាក្សីរូបនេះ ដោយផ្អែកទៅលើឯកសារ E319/43.3.9 - 11 នេះគឺជាឯកសារដែលបញ្ជូនមក។ កាលនោះ អង្គជំនុំជម្រះបាននិយាយនៅពេលប្រជុំរៀបចំសវនាការថា មិនបានបញ្ចូលនៅក្នុងឯកសារទេ ហើយអង្គជំនុំជម្រះក៏បានខំព្យាយាមយកភស្តុតាងដែលមកពីសំណុំ<០០៣>, <០០៤> នោះមក ហើយភាគីអត់មានអ្នកណាស្នើសុំទេ។ ឥឡូវនេះយើងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ហើយ គឺសល់តែប៉ុន្មានសប្តាហ៍ចប់ហើយ សំណុំរឿងយើងនេះ។ អ៊ីចឹង<>ការកត់សម្គាល់<ដំបូងដោយសារគេបានស្នើសុំឲ្យយើងឆ្លើយតប>ទៅលើការសម្រេច <ដែលអង្គជំនុំជម្រះចង់មានផែនការកោះហៅ បើសិនជាការសម្រេចនោះនៅមិនទាន់បានអនុវត្តទេ -- ដូច្នេះ>ការកត់សម្គាល់ទី១ របស់ខ្ញុំនោះគឺយើងចង់និយាយថា យើងជួបប្រទះនឹងបញ្ហាយុត្តិធម៌ផ្លូវច្បាប់ ពីព្រោះថាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ គឺថាយើងឃើញថា កិច្ចស៊ើបអង្កេតហ្នឹងវាបីឆ្នាំជាងមកហើយ <ដែលយើងបានចេញ>ដីកាដំណោះស្រាយតាំងពីឆ្នាំ២០១០ ហើយ<នៅឆ្នាំ២០១៦ គេបានប្រកាសថា យើងនឹងស្តាប់សក្ខីកម្មរបស់>សាក្សី<ម្នាក់ ដែល>មិនមានអ្នកណាស្នើសុំទេប៉ុន្មានឆ្នាំមកហើយហ្នឹង។ អ៊ីចឹងយើងត្រូវយល់ទាំងអស់គ្នាថា វិធាននៃអង្គជំនុំជម្រះយើងនេះគឺយើងអាចអនុញ្ញាតឲ្យចូលដាក់ភស្តុតាងថ្មីចូលបានបើសិនជាមានសារៈសំខាន់ ហើយមានប្រយោជន៍។ នេះគឺជា វាគោរពទៅតាមវិធាន៨៧(៤)

ហើយទៅបញ្ចូលភស្តុតាងថ្មី។ ក៏ប៉ុន្តែយើងត្រូវចាំថា <យើងនៅក្នុងយុត្តាធិការមួយ ដែល>មានកិច្ចស៊ើបអង្កេតបានធ្វើមកហើយ ហើយភស្តុតាងថ្មីនេះ<គឺបានមកតាមរយៈការបង្ហាញឯកសារ ដែល> មិនមែនជា<ផ្នែកនៃឯកសារ>នៅក្នុងសំណុំរឿងយើងទេ គឺមកសំណុំរឿងផ្សេង <ព្រោះថាចំណុចនេះគឺបាននិយាយនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ> ហើយយើងកុំភ្លេចខ្លួនថាឥឡូវនេះថ្ងៃទី១៥ កញ្ញា ឆ្នាំ ២០១៦ហើយ។ អ៊ីចឹងអង្គជំនុំជម្រះអាចបញ្ចូលភស្តុតាងថ្មីបាន ក៏ប៉ុន្តែរបៀបបញ្ចូលនេះបញ្ចូលយ៉ាងម៉េច ប៉ុន្មានខែចុងក្រោយនេះៗ គឺយើងបញ្ចូលមកហ្នឹងគឺមានបញ្ហាតែម្តង។ យើងៗមើលភាគរយនៃសាក្សី ហើយនិងឯកសារដែលបញ្ចូលនៅក្នុងសំណុំរឿង<០០២/០២>នេះ ហើយនិងយើងមើលភាគរយនៃឯកសារដែលមកពីសំណុំរឿងផ្សេងទៀតនោះ យើងមើលទៅឃើញវាខុសគ្នាណាស់ ច្រើនឆ្ងាយណាស់។ <>យើងយល់ហើយថាយើងអាចទទួលភស្តុតាងថ្មីបាន ក៏ប៉ុន្តែ<>ខ្ញុំ<ត្រូវពិនិត្យ>មើល<នៅក្នុងកុំព្យូទ័ររបស់ខ្ញុំ ព្រោះខ្ញុំមិនមានពេលដើម្បី>ព្រីនមើល<ទេ។> ចង់ដឹងមើល នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះមួយដែលអង្គជំនុំជម្រះបានកំណត់ថានៅថ្ងៃទី០១ កញ្ញា ហ្នឹងគឺត្រូវព្រះរាជអាជ្ញាហ្នឹងត្រូវ -- <នៅក្នុងបរិបទនៃការជំនុំជម្រះ លោកនិយាយ ហើយនេះជាសេចក្តីសម្រេចនោះ> គឺសេចក្តីសម្រេច <E319/47/3> នៅកថាខណ្ឌ២៣ មានតែភាសាអង់គ្លេសទេ ខ្ញុំដកស្រង់ជាភាសាអង់គ្លេស។

[១៤:០៨:១៦]

"ក្នុងករណីណាក៏ដោយ ដោយសារថាអង្គជំនុំជម្រះជិតនឹង<បញ្ចប់>ការពិភាក្សាដេញដោលអំពីភស្តុតាងលើសំណុំរឿង០០២/០២ <គួរតែចូលដល់ចំណុចមួយ> នៅពេលដែលភាគី<អាចពឹងផ្អែកទៅលើភស្តុតាង>កំណត់ហេតុជាលាយលក្ខណ៍អក្សរ <ដែលត្រូវបានបង្កើតឡើងតាមរយៈ>ការស៊ើបអង្កេត <និងការជំនុំជម្រះ>នៅក្នុងសំណុំរឿងនេះ។ តម្លៃនៃភស្តុតាងគឺថា អាចនឹងបង្ហាញនូវការពិតជាក់លាក់ណាមួយ ហើយនិងមានទម្ងន់ពាក់ព័ន្ធទៅនឹងភាពជាក់លាក់ណាមួយដែលពាក់ព័ន្ធទៅនឹងភស្តុតាងថ្មីៗដែលបង្ហាញនៅជិតនឹងបញ្ចប់កិច្ចដំណើរការវិធី ដែលភាគីមិនមានឱកាសគ្រប់គ្រាន់ដើម្បីវាយតម្លៃ និងឆ្លើយតបទៅនឹងភស្តុតាងថ្មីៗទាំងនេះ។" បញ្ចប់ការដកស្រង់។ នេះជាអ្វីដែលអង្គជំនុំជម្រះបានលើកឡើង ក៏ប៉ុន្តែឥឡូវនេះ <អ្វីដែលខ្ញុំកំពុងតែមើលឃើញនោះគឺថា អ្វីដែលលោកបាននិយាយ>កាល<ពី>ខែមិថុនា ឆ្នាំ២០១៦នោះ គឺបានលើកឡើង<ថា "យើងពិតជាចាំបាច់ត្រូវពិនិត្យមើលភស្តុតាងដែលយើងកំពុងតែយកមក">។ <ហើយនៅពេល>យើង<>អាចសេចក្តីសម្រេចហ្នឹងហើយ យើង<គិត>ថា <"អ្វីដែល>យើងបានជំទាស់ យើងចោទលោទសតាំងពីយូរមកហើយ ថាការដាក់ផ្តល់ឯកសារភស្តុ-

តាងមកពីសំណុំរឿងផ្សេង<មិនមែនសំណុំរឿង០០២/០២ នោះទេ ដែលមកពីការស៊ើបអង្កេតបន្ថែម ហើយដែលមិនស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះក្តីនេះទេ"។> យើងគិតថា <"នៅទីបំផុត>អង្គជំនុំជម្រះយល់<នូវបទពិសោធន៍របស់យើង>។ ហើយឥឡូវនេះ <ខ្ញុំយល់ថា មិនត្រឹមតែអង្គជំនុំជម្រះមិនយល់ទេ គឺបានថែមទាំងបង្កើតឲ្យមានបញ្ហាច្បាប់បន្ថែមទៀត។ ព្រោះថា ទើបតែប៉ុន្មាន>សប្តាហ៍មុនពេលចប់សំណុំរឿងយើងនេះ <ពួកគេជាថ្មីម្តងទៀតបានស្នើសុំឲ្យយើងស្តាប់សក្ខីកម្មរបស់>សាក្សីមួយមកទៀត ដែលគ្មានភាគីណាសុំស្នើមកផង <តាំងពី>ខែ៣ ឆ្នាំ២០១៦ <ព្រោះថា>អង្គជំនុំជម្រះ<ជាអ្នកដែល>បានពិគ្រោះកំណត់ហេតុស្តាប់ចម្លើយ<ទាំងអស់នេះ ហើយអង្គជំនុំជម្រះបានដឹងរឿងនេះ។> សហព្រះរាជអាជ្ញា<ដែលបានបង្ហាញភស្តុតាង>ហ្នឹងគាត់ដឹងដែរ គាត់បានពិគ្រោះឯកសារដែរ គឺគាត់អត់បានស្នើដាក់បញ្ចូលដែរ។ ហើយភាគីខាងជនជាប់ចោទនេះ តាមធម្មតាគេប្រាប់ថា សុទ្ធតែជាភស្តុតាងដោះបន្ទុក ក៏ប៉ុន្តែយើងមើលទៅវាមិនមែន<ជាភស្តុតាងដោះបន្ទុក>ទេ <ហើយក៏មិនបានស្នើសុំកោះហៅសាក្សីនេះ ឬក៏ស្នើសុំឲ្យដាក់ចម្លើយរបស់គាត់ទៅក្នុងភស្តុតាងនោះដែរ។>

<ដូច្នេះនេះជា>បរិបទ<ដែលខ្ញុំនិយាយនៅថ្ងៃនេះ ហើយនេះជាមូលហេតុដែលខ្ញុំនិយាយថា បើលោកចៅក្រមស្នើឲ្យខ្ញុំធ្វើការសង្កេត ក្នុងនាមយើងជាមេធាវីការពារក្តីលោក ខៀវ សំផន នៅក្នុងវគ្គនេះ គឺយើងគ្មានចំណូលចិត្តចង់>កោះហៅសាក្សីណាមួយមកទេ ព្រោះអីមានសាក្សីជាច្រើនទាក់ទងនឹងជម្លោះប្រដាប់អាវុធ<នៅក្នុងសំណុំរឿង០០២/០២>ហ្នឹង <នៅពេលដែលមេធាវីការពារក្តីបានស្នើសុំឧទាហរណ៍ដូចជា> សាក្សី TCE-87 នេះជាដើម <ខ្ញុំជឿថា>ថ្មីៗនេះ យើងបានសុំឲ្យកោះមក អត់មានឃើញ។ តែភស្តុតាងនៅក្នុងសំណុំរឿង<០០២/០២>នោះ <ដែលភាគីកំពុងស្នើសុំឲ្យកោះហៅសាក្សីមួយរូប នៅមិនទាន់ត្រូវបាន>ធ្វើសេចក្តីសម្រេចអីទេ <ប៉ុន្តែយើងនឹងពិនិត្យមើលនរណាម្នាក់ដែលមក>ពីសំណុំរឿងផ្សេង <ហើយដែលគ្មានភាគីណាមួយបានស្នើសុំពីមុន>មក<>។ អ៊ីចឹងខ្ញុំគិតថា <យើងអាចនិយាយបានថា> ធ្វើឲ្យយើងច្របូកច្របល់ក្នុងអារម្មណ៍សម្បើមណាស់ កិច្ចដំណើរការជំនុំជម្រះនេះ ដំណើរការទៅនោះវាប៉ះពាល់ដល់ខាងការពារក្តី ព្រោះថា យើងមិនដឹងថាត្រូវឆ្លើយតបទៅនឹងភស្តុតាងមួយណា តើការដាក់បន្ទុកមួយណា? <ព្រោះថា>នៅក្នុងដីកាដំណោះស្រាយហ្នឹងតាំងពី២០១០មកម៉្លេះ ឥឡូវនៅតែយើងអត់ដឹងថាត្រូវឆ្លើយតបនូវអ្វីផងទេ។ មេធាវី ខៀវ សំផន យល់ឃើញយ៉ាងដូច្នេះឯង។

[១៤:១១:៤៣]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<ដូច្នេះ>យើង<កំពុងតែមានការដេញដោលគ្នាពីខាងមេធាវីការពារក្ដីលោក ខៀវ សំផន។ យើង>ស្ថិតនៅក្នុងស្ថានភាពហ្នឹង ហើយ<ខ្ញុំមិនអាចនិយាយបានទេថា> យើង<មានការ>យល់ច្រឡំអំពី<អ្វីដែល>អង្គជំនុំជម្រះ<នឹងសម្រេចនោះ>។ អ៊ីចឹងបើសិនជាអង្គជំនុំជម្រះ<ស្នើសុំឱ្យមានការសង្កេត ព្រោះថាជាទូទៅ>សេចក្ដីសម្រេច<នេះត្រូវបានអនុវត្តរួចហើយ។ ដូច្នេះបើសិនជាក្នុងករណីនេះ អ៊ីចឹង>យើងគ្រាន់តែសូមជម្រាបជូនថា <មានបញ្ហាមួយគឺភាពមិនប្រាកដប្រជា>តាមផ្លូវច្បាប់<ដែលយើងជឿថា ការបង្ហាញឯកសារមកពីសំណុំរឿងផ្សេងក្រៅវិសាលភាពនៃសំណុំរឿង០០២/០២ នោះគឺមានភាពយឺតយ៉ាវខ្លាំងណាស់>។ ដូច្នេះ យើងសូមសួរថា តើអង្គជំនុំជម្រះត្រូវកោះហៅសាក្សីហ្នឹងមក ឬក៏អត់? ហើយបើកាលណាអ៊ីចឹង <យើងស្នើសុំឱ្យមាន>ពេលវេលាឱ្យយើងត្រៀមលក្ខណៈ <សម្រាប់សាក្សីរូបនេះ>។

[១៤:១២:៣៣]

<នៅពេលខ្ញុំនិយាយពីពេលវេលា ដោយសារខ្ញុំ>នៅក្នុងសវនាការសាធារណៈ យើងត្រូវយល់ដឹងពីលក្ខខណ្ឌនៃការងាររបស់យើងប្រចាំថ្ងៃ។ យើងត្រូវដឹងថា សម្របសម្រួលខ្លួនយ៉ាងម៉េច រៀបចំខ្លួនយ៉ាងម៉េច ពីព្រោះថា ផែនការមកហ្នឹងវាប្រែប្រួលរហូត <ព្រោះថា>យើងឱ្យអ្នកពិគ្រោះយើងធ្វើការនោះ យើងពិបាកគ្រោងការងារណាស់ ព្រោះអីបើបញ្ចូលសាក្សីថ្មីមកអ៊ីចឹង ការរៀបចំការងាររបស់យើងហ្នឹងវាផ្លាស់ប្ដូរអស់រលីង។ អ៊ីចឹង<វាមានន័យថាពេលវេលាដែល>យើង<អាចធ្វើការលើសេចក្ដីសន្និដ្ឋានបញ្ចប់នោះ> ឧទាហរណ៍ <វាមានន័យថា>យើងត្រូវ<ប្រើប្រាស់ពេលវេលានេះជំនួសវិញដើម្បីកែតម្រូវការងារប្រចាំថ្ងៃតាមភស្ដុតាងថ្មី>។ <អ៊ីចឹងវាមិនធម្មតាទេ។ ហើយវាកាន់តែមិនធម្មតាទៅទៀត ក្នុងករណីដែលការជំនុំជម្រះមួយ ដែលមានការស៊ើបអង្កេត ហើយវារឹតតែមិនធម្មតា ព្រោះថ្ងៃនេះ ថ្ងៃទី១៥> ខែកញ្ញា ឆ្នាំ២០១៦ ទៅហើយ។

ខ្ញុំគិតថា អង្គជំនុំជម្រះប្រហែលជាចេញសេចក្ដីសម្រេចជាស្ថាពរហើយ។ <ប៉ុន្តែយើងសូមពេលវេលាបន្ថែម ដើម្បីរៀបចំ ហើយក៏សូមយោងទៅសំណើ>ដែលយើងបានដាក់ <ដោយនិយាយថាយើងចង់បាន>ឯកសារខ្សែអាត់ ដែល<ត្រូវគ្នានឹងកំណត់ហេតុស្ដាប់ចម្លើយសាក្សី ព្រោះថានោះក៏ជាមធ្យោបាយមួយក្នុងការតាមដានពី>ភាព<>អាចទុកចិត្តបានរបស់សាក្សីហ្នឹង។ ហើយដោយហេតុថាយើងឥឡូវនេះ យើងផ្លាស់ប្ដូររហូត ផ្លាស់ប្ដូរភស្ដុតាងនៅក្នុងសំណុំរឿងរហូតនោះ យើងសូមថា សូមឱ្យដឹងឱ្យច្បាស់មើល ថាតើ<នេះជា>សាក្សីចុងក្រោយ<ដែលនឹងត្រូវបានបង្ហាញឱ្យភ្ញាក់ផ្អើលនៅនាទី

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ចុងក្រោយ ពី>ក្នុងបញ្ជីសាក្សី <ដែលយើងនឹងមាននៅក្នុងសំណុំរឿង០០២/០២ ឬយ៉ាងណា?>

[១៤:១៤:០៨]

ខ្ញុំសូមបញ្ជប់ថា ខ្ញុំសូមរំឭកចំណុចមួយ ព្រោះថាយើងបានចោលទោសសម្បើមណាស់ រឿងការផ្ទេរឯកសារពីសំណុំរឿងពី<០០៣>, <០០៤> មកយ៉ាងច្រើននេះ ព្រោះថាយើងកំពុងកាត់ក្តីផង យើងត្រៀមលក្ខណៈការពារក្តីផង។ <ដូច្នេះការរៀបចំការស៊ើបអង្កេត> <០០៣>, <០០៤> <ដែលជាមូលដ្ឋានសម្រាប់រៀបចំសវនាការនេះ គឺប្រព្រឹត្តទៅក្នុងពេលជាមួយគ្នានឹងពេលដែលយើងដំណើរការលើសំណុំរឿង០០២/០២ ប៉ុន្តែយើងមិនមែនជាភាគីក្នុងការ>ស៊ើបអង្កេត<នោះទេ។ ខ្ញុំមានបញ្ហាច្រើនចង់និយាយលើប្រធានបទនេះ ប៉ុន្តែដោយសារតែពេលវេលាខ្ញុំមានកំណត់> ខ្ញុំសូម<>បញ្ជាក់ថា បើសិនជាអង្គជំនុំជម្រះចង់កោះហៅសាក្សីរូបហ្នឹងមក សហព្រះរាជអាជ្ញាស្គាល់សាក្សីតាំងពី២០១២មកនេះ។ បើសិនជាអង្គជំនុំជម្រះចង់កោះហៅមក ឱ្យពេលវេលាមកយើងត្រៀមលក្ខណៈឱ្យត្រឹមត្រូវ ឱ្យមានខ្សែអាត់ឱ្យត្រឹមត្រូវ <ហើយអង្គជំនុំជម្រះត្រូវពិចារណាចំពោះការបង្ហាញភស្តុតាងថ្មីដ៏ច្រើននេះ ព្រោះ>យើង<ត្រូវការមានលទ្ធភាពក្នុងការ>ពិគ្រោះ<លើលក្ខខណ្ឌដែលយើងនឹងសរសេរសេចក្តីសន្និដ្ឋានស្តាពរ>។

[១៤:១៥:១៧]

អ្វីដែលខ្ញុំនិយាយនេះ គឺថា<សំខាន់ផង និង>ជាលក្ខណៈនិមិត្តរូប<ផង> ដោយសាតែសេចក្តីសម្រេចចុងក្រោយមួយចំនួនរបស់អង្គជំនុំជម្រះនេះ គឺ<ការបង្ហាញសាក្សីដ៏ច្រើនពីក្នុងការស៊ើបអង្កេតនៃ>សំណុំរឿង<០០៣, ០០៤> បង្កឱ្យមានបញ្ហាផ្លូវច្បាប់តែម្តង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី នួន ជា!

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជឿជាក់ថាវាមានសំខាន់ណាស់ ទាក់ទងទៅនឹងថាតើសាក្សីរូបនេះជាអ្នកណា ហើយយើងកំពុងតែនិយាយពីអ្នកណា។ ខ្ញុំគិតទៅ គឺថាជាសមាជិកគ្រួសារមួយ សាច់ឈាមឆ្ងាយនៃ -- អ្នកដែលមានសាច់ឈាមឆ្ងាយពីមេភូមិភាគបូព៌ា សោ ភឹម ហើយគាត់ធ្វើការនៅមន្ទីរពេទ្យនៅ<ភូមិភាគបូព៌ា> មន្ទីរពេទ្យកងពលលេខ៤ ដែលជាកងពលមួយដ៏សំខាន់របស់ភូមិភាគបូព៌ា ដែលដឹកនាំដោយបុគ្គលម្នាក់ ស្គាល់គ្រប់គ្នាហើយ នៅក្នុងបន្ទប់សវនាការ គឺលោក ហេង សំរិន។

ដូចដែលអង្គជំនុំជម្រះបានជ្រាបហើយ គឺថាយើង<មានជំហរខុសគ្នាក្នុងការ>ស្នើសុំ <>កោះហៅសាក្សីពីសំណុំរឿង០៣ និង០៤។ មិនមានអ្វីជាឧបសគ្គទេ ត្រូវតែកោះហៅបុគ្គលនេះឱ្យចូលខ្លួន។ <តើគាត់សំខាន់>ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង<ទេ? យើងខ្ញុំមិនជឿដូច្នោះទេ។> យើងខ្ញុំបានអានកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ហើយគាត់មិនមានតួនាទីអ្វីដែលអាចផ្តល់ចម្លើយសំខាន់ៗអំពីព្រឹត្តិការណ៍សំខាន់ៗនៅក្នុងភូមិភាគបូព៌ា នៅខែឧសភា ១៩៧៨ និងមុនៗនោះទេ។ ហើយសព្វថ្ងៃនេះតាមការយល់ឃើញរបស់អង្គជំនុំជម្រះ <គាត់>អ្នកដែលត្រូវមកផ្តល់សក្ខីកម្មអំពីជម្លោះប្រដាប់អាវុធ។ <ខ្ញុំ>មិនដឹងថាតើគាត់នឹងផ្តល់សក្ខីកម្មអំពីប្រធានបទស្តីអំពីការបោសសម្អាតនេះដែរឬក៏អត់ទេ គឺការបោសសម្អាតនៅភូមិភាគបូព៌ា។ ខ្ញុំមន្ទិលសង្ស័យថា គាត់<>អាចផ្តល់សក្ខីកម្មពីការបោសសម្អាតនេះបាន<>មើលទៅ។ ហើយបញ្ហាដែលធំនោះ គាត់គឺជាមនុស្សតូចតាចទេ មិនមែនជាមនុស្សដែលសំខាន់ហើយដែលគួរតែមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះយើងនេះទេ។

[១៤:១៨:២៤]

លោកប្រធាន បើមិនយល់ទាស់ទេ ខ្ញុំសូមសំអាងជូនអង្គជំនុំជម្រះអំពីកថាខណ្ឌសំខាន់មួយនៃពីគំនិតយោបល់តិចតួចទេ។ គឺជាសម្តីរបស់ចៅក្រមម្នាក់ដែលធ្វើការនៅវិស័យព្រហ្មទណ្ឌ គឺក្នុងករណីរបស់រឿងក្តី កាតាំងហ្កា។ គាត់និយាយពីចំណុចមួយចំនួន អំពីបញ្ហានៃការបាត់បង់ភស្តុតាង។ ការបាត់បង់ភស្តុតាង គឺថាដូចដែលយើងដឹងហើយ គឺវាសំខាន់ណាស់។ <គាត់និយាយ>នៅក្នុងកថាខណ្ឌ ១៤៨ នៃមតិយោបល់ភាគតិច។ ខ្ញុំសូមដកស្រង់៖ “អវត្តមានភស្តុតាងទាំងស្រុងពីអ្នកដែលស្ថិតនៅចំណុចសំខាន់នាពេលនេះ វានាំឱ្យមានបញ្ហាដែលថា ព័ត៌មានដែលសំខាន់ៗវាអាចបាត់ចេញពីប្រតិចារឹករួមមាន ការមិនបានបង្ហាញ ភស្តុតាងឱ្យបានពេញលេញ ដែលវានាំឱ្យមានអន្តរាយ និងភាពអន្តរាយ។ ហើយវានាំបង្កឱ្យមានវិមតិសង្ស័យផងដែរ។” ហើយមានឱកាសច្រើនណាស់ យើងបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងរបស់យើង ឱ្យកោះហៅសាក្សីសំខាន់ៗមួយចំនួនក្នុងសំណុំរឿងនេះ។ គឺសាក្សីសំខាន់ៗពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅភូមិភាគបូព៌ា ក៏ដូចជាពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ។ យើងខ្ញុំបានស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅលោក ហេង សំរិន, ឱ្យកោះហៅលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន, លោក អ៊ុក ប៊ុនឈឿន, <លោក ប៉ុល សារឿន,> ឱ្យកោះហៅលោក ប៉ែន សុវណ្ណ។ ពួកគាត់ទាំងអស់នេះគឺថាជាមនុស្សដែលសំខាន់ណាស់នៅពេលផ្តល់ ដែលត្រូវផ្តល់សក្ខីកម្មអំពីព្រឹត្តិការណ៍ដែលយើងបាននិយាយគ្នាតាំងពីម្សិលមិញ ថ្ងៃនេះ ហើយក៏យើងៗក៏បានស្នើសុំឱ្យកោះហៅតាំងពីប្រាំបួនឆ្នាំមុនម្ល៉េះ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ដូច្នេះ ក្ដួយរបស់ សោ ភឹម រូបនេះ ខ្ញុំសប្បាយចិត្តណាស់បើគាត់អាចមកបាន បើគាត់មិនមកបានក៏មិនបញ្ហាអ្វីដែរ។ ក៏ប៉ុន្តែអ្វីដែលសំខាន់ គឺយើងខ្ញុំបានលើកឡើងឈ្មោះអម្បាញ់មិញហើយទើបជាសាក្សីដ៏សំខាន់ដែលៗត្រូវផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

សូមជូនវេទិកាទៅលោកចៅក្រម ហ្សង់ម៉ាក។

[១៤:២១:២៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ លោកស្រីមេធាវី អង់តា ហ្គីសសេ ខ្ញុំចោទសំណួរទៅលោកស្រី ហើយយើងបានស្ដាប់<> ការជំទាស់របស់លោកស្រីហើយ។ ហើយលោកស្រីថា បើ<ចាំបាច់> លោកស្រីត្រូវការពេលវេលាច្រើនជាងហ្នឹង។ អ៊ីចឹងលោកស្រីអាចជម្រាបជូនពីពេលវេលាដែលលោកស្រីត្រូវការដើម្បីត្រៀមសួរចម្លើយទៅសាក្សីរូបហ្នឹងទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

អាស្រ័យទៅនឹង<ពេលដែលយើងបានទទួល>ខ្សែអាត់<ពាក់ព័ន្ធទៅនឹងកំណត់ហេតុស្ដាប់ចម្លើយសាក្សី ព្រោះថា>ដូចដែលខ្ញុំបានជម្រាបជូនហើយគឺថា លេខសំណើដែលយើងបានដាក់ជូននោះខ្ញុំភ្លេចទៅហើយ ក៏ប៉ុន្តែយើងក៏បានដឹងថាមានខ្សែអាត់របស់គាត់ ខ្សែអាត់នៃចម្លើយរបស់គាត់។ អ៊ីចឹងនៅពេលយើងបានទទួលខ្សែអាត់ហ្នឹងហើយ យើងនឹងដឹងថា ត្រូវចំណាយពេលវេលាប៉ុន្មាន ដើម្បីត្រៀមខ្លួន។ អ៊ីចឹង ខ្ញុំអត់ទាន់ដឹងទេឥឡូវនេះទាល់បានខ្សែអាត់សិន។

[១៤:២២:២៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងលើកឡើងសង្ខេបទេដោយសារតែខ្ញុំមានការភ្ញាក់ផ្អើលណាស់អ្វីដែលខ្ញុំបានស្ដាប់ឮពីមេធាវីការពារក្ដី។ ខ្ញុំសូមឆ្លើយតបទៅនឹងចំណុចមួយចំនួនដែលយើងទើបស្ដាប់ឮអម្បាញ់មិញ។ ទី១ ដែលថាបុគ្គលរូបនេះ សាក្សីរូបនេះមិនសំខាន់។ <យើងទើបតែបានឮសេចក្ដីថ្លែង-ការណ៍ខុសមួយអំពីតួនាទីរបស់បុគ្គលម្នាក់នេះ។> គឺថា <គាត់>មិន<មែន>ជាពេទ្យម្នាក់នៅក្នុងមន្ទីរ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ពេទ្យ<ទេ គឺគាត់>ជាប្រធានពេទ្យ ប្រធានមន្ទីរពេទ្យកងវរសេនាធំ។ ហើយ<នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨> នៅពេលដែលមានការបោសសម្អាតកម្មាភិបាលនៅភូមិភាគបូព៌ា គាត់<ត្រូវ>បានដំឡើងទៅជាមេបញ្ជាការកងវរសេនាធំ។ អ៊ីចឹងសម្រាប់ខ្ញុំនេះ ដែលស្ដាប់ឮអ្នកដទៃនិយាយថា បុគ្គលរូបនេះមិនសំខាន់នោះ គឺមិនយល់។ ហ្នឹងការធ្វើបែបនេះហាក់បីដូចជាខ្វះកែវភ្នែកអង្គជំនុំជម្រះចោលហើយ។

ហើយពាក់ព័ន្ធទៅនឹងការបង្ហាញភស្តុតាងនេះ គឺគាត់<វាមានការពាក់ព័ន្ធ ហើយ>អាចនិយាយអំពីមនុស្សផ្សេងៗនៅក្នុងភូមិភាគបូព៌ាដែលមេធាវីការពារក្ដីបានលើកឡើងហើយថា ជាចំណុចដ៏សំខាន់នៅក្នុងសំណុំរឿងយើងនេះ។ អ៊ីចឹងឯងបានជា<យើងបង្ហាញភស្តុតាងនេះ។> អ៊ីចឹងខ្ញុំមិនចង់បង្កបញ្ហាច្រើនទេ ក៏ប៉ុន្តែពេលបុគ្គលរូបនេះមកអាចបង្ហាញរឿងរ៉ាវថ្មីៗ គឺថាវាមានប្រយោជន៍ដល់ក្រុមមេធាវីការពារក្ដី នួន ជា។ <ពួកគេប្រើប្រាស់ឱកាសនេះ ដើម្បីលើកឡើងនូវបញ្ហាមួយផ្សេងទៀត ប៉ុន្តែខ្ញុំមិនចង់អូសបន្លាយពេលវេលាវែងឆ្ងាយទេ ព្រោះវាមិនមែនជាបញ្ហាឡើយ គឺអង្គជំនុំជម្រះជាអ្នកសម្រេច។> ហើយសំខាន់បំផុតនោះ គឺ<សារណារបស់ក្រុមលោក ខៀវ សំផន ដែល>ស្ដីបន្ទោសអង្គជំនុំជម្រះ ដូចកូនក្មេងនោះ គឺ<ដោយសារតែខ្លួនមានបំណងក្នុងការស្នើសុំស្ដាប់សាក្សីម្នាក់ ដែល>គួរ<ឲ្យ>កត់សម្គាល់ណាស់<សម្រាប់ខ្ញុំ។> គឺនេះគឺជា អង្គជំនុំជម្រះសាលាដំបូងដែលកំពុងតែស្វែងរកការពិត។ បើសិនជាអង្គជំនុំជម្រះយល់ឃើញថា សាក្សីរូបនេះនឹងជួយឲ្យអង្គជំនុំជម្រះស្វែងរកនូវការពិត អ៊ីចឹងគួរតែកោះហៅសាក្សីរូបនេះ។ ការជំទាស់ណាមួយដែលមិនច្បាស់លាស់ មានភាព កំសោយនោះគឺមិនត្រឹមត្រូវទេ។ វាគឺថាជាការពិតមានពេលវេលាគ្រប់គ្រាន់ហើយសាក្សីតែមួយរូបតើ។ ដូច្នេះ ភាគីនីមួយៗអាចមានពេលវេលាត្រៀមគ្រប់គ្រាន់ហើយ។ ដូច្នេះ វាមិនមែនជាវេទិកាមួយដែលថាយើងត្រូវហៅសាក្សីរូបនេះមកស្អែកភ្លាមនោះទេ។ អាហ្នឹងបានវាអាចហ្នឹងបង្កបញ្ហាណាមួយ ឬក៏ថាបង្កព្យសនកម្មណាមួយដល់ភាគីណាមួយ។

ដូច្នេះ លោក លោកស្រីចៅក្រម នៅទីនេះមានភារកិច្ចមួយ<មិនបង្កបញ្ហាដល់ខ្លួនឯងក្នុង>ការស៊ើបអង្កេត<ដែលត្រូវបានធ្វើឡើង>ប៉ុន្មានឆ្នាំ<កន្លងមក ប៉ុន្តែឆ្លៀតឱកាសនេះបង្ហាញសាក្សីថ្មីដែលសំខាន់>។ បើអង្គជំនុំជម្រះយល់ឃើញថា បុគ្គលរូបនេះអាចនឹងជួយបង្ហាញការពិតដល់អង្គជំនុំជម្រះ នោះអង្គជំនុំជម្រះគួរតែកោះហៅសាក្សីរូបនេះ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ អង្គជំនុំជម្រះសូមអរគុណដល់ភាគីដែលបានធ្វើការកត់--

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអញ្ជើញលោក សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន អញ្ជើញឲ្យបានខ្លីបានហើយ។

[១៤:២៦:១៨]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់ធ្វើការកត់សម្គាល់ពីរ ដើម្បីឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។ <ទី១> បើសិនជាគាត់គិតថាសាក្សីហ្នឹងសំខាន់មែនទែននោះ ម៉េចក៏មិនស្នើសុំតាមវិធាន ៨៧(៤) ហ្នឹង <ដើម្បីកោះហៅសាក្សីនេះ។ សហព្រះរាជអាជ្ញាមិនបានធ្វើដូច្នោះទេ ដូច្នេះយើងជឿថា ចំពោះសហ>ព្រះរាជអាជ្ញា<គឺវាមិនសំខាន់ទេ។> អ្វីដែល<យើងបានឮនៅថ្ងៃនេះ ហើយនិងអ្វីដែលយើងបាននិយាយមួយរយៈមុននេះ គឺមិនមែនជាអ្វីថ្មីទេ ប៉ុន្តែដែល>ថ្មីគឺថាយើងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១៦ ទៅហើយ វាមិនតាំងពីដំបូងឯណា។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

អង្គជំនុំជម្រះសូមអរគុណដល់ភាគីដែលធ្វើការកត់សម្គាល់លើបញ្ហានេះ។ អង្គជំនុំជម្រះនឹងយកមតិយោបល់របស់ភាគីទៅពិនិត្យពិចារណា ដើម្បីចេញសេចក្តីសម្រេចលើពីបញ្ហានេះ។

ជាបន្តទៀត សូមអញ្ជើញសហព្រះរាជអាជ្ញាតាំងសំណួរទៅសាក្សីរូបនេះ។ ពេលវេលាសម្រាប់សហព្រះរាជអាជ្ញានិងដើមបណ្តឹងរដ្ឋប្បវេណីវាមានរយៈពេលពីរវគ្គ។សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

[១៤:២៧:២៧]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំសូមចាប់ផ្តើមសួរអំពីប្រវត្តិសាវតាររបស់លោក មុននឹងលោកត្រូវបានគេចាត់តាំងឲ្យទៅធ្វើការនៅស-២១។ លោកបានឆ្លើយថា ពីដំបូងឡើយលោកត្រូវបានគេចាត់តាំងឲ្យធ្វើជាអ្នកថតរូបនៅពេលដែលលោកនៅក្នុងកងពល៧០៣។ អ្វីដែលខ្ញុំមិនយល់នោះគឺ តើគេមានគោលបំណងអ្វីដែលត្រូវឲ្យមានអ្នកថតរូបចំណុះឲ្យកងពល ដូចជាកងពល៧០៣ជាដើម។ តើនៅពេល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែលលោកជាកងទ័ពចំណុះឲ្យកងពល៧០៣នោះ ហេតុអ្វីបានជាគេចាត់តាំងឲ្យលោកធ្វើជាអ្នកថតរូប?

**លោក នឹម អ៊ីម៖**

**ឆ៖** ឥឡូវខ្ញុំសូមនិយាយលម្អិតបន្តិចរឿងបញ្ហាហ្នឹង កាលមុនដំបូងគឺខ្ញុំជាជនអ្នកពិការទេ ត្រូវរបួស ហើយដេកពេទ្យ។ ពេលដែលចេញពេទ្យខឹង កាលហ្នឹងខឹងពេទ្យរឿងបែងចែកវណ្ណៈហ្នឹង បែងចែកបក្សពួកហ្នឹង ខ្ញុំក៏ប្រឆាំងគេ ក៏ខ្ញុំចេញប្រឆាំងដល់ផ្តើល ស្រី មឿន ហៅ ធារិទ្ធ ហ្នឹងព្រោះគេបែងចែកវណ្ណកងហា កងរយ កងវីរៈ គេធ្វើបាយសម្លសុទ្ធម្ហូបឆ្ងាញ់ៗ សម្រាប់អ្នកយុវជនគេឲ្យស៊ីសម្លតែម្ហូរដើមចេក ហើយសាបទៀត។ ដល់ហើយក៏ខ្ញុំធ្វើការខ្ញុំដើររួច ខ្ញុំដើរចូលទៅហូបបាយកន្លែងរួមៗគ្នាហ្នឹង ក៏ពេលនោះក៏អ្នកដែលៗរបួសក៏ថាសម្លសាប សុំអំបិល។ សុំអំបិល ពេទ្យគេថា គេអត់ខ្ចីមាត់ក ម្នាក់ថាទេ ពីរនាក់ថាទេ ខ្ញុំក៏ជ្រុលមាត់បណ្តោយ។ ខ្ញុំថាឥឡូវមិត្តទាំងអស់ពួកវ៉ៃដណ្តើមស្រី បានៗមកត្រូវរបួសហ្នឹង បានពេទ្យពិបាកហ្នឹងណា។ នែ! បងៗខាងពីរតុម្ហូលនេះ អាហ្នឹងបានវ៉ៃរំដោះប្រទេសជាតិ បានគេផ្គត់ផ្គង់ មានត្រីចំហុយ មានមាត់ស្ងោរអីហ្នឹង។ គ្រាន់ពេលហ្នឹងផ្តើលពេលហូបមួយមន្ទីរពេទ្យហ្នឹងទៅ។ ដល់បានប្រហែលជាចំនួនប្រហែលជាមួយម៉ោងក្រោយមកបានឃើញ ស្រី មឿន ថា ស្រី មឿន នេះហៅ ធារិទ្ធ ហ្នឹងគាត់មកដល់។ ស្រាប់មកដល់គេឲ្យនីរសារគាត់ហៅខ្ញុំ ទៅផ្ទះកន្លែងប្រជាជនអត់នៅ។ គាត់ប្រាប់ថា នែ! មិត្តឯងប្រយ័ត្នងាប់ តែមិនស្រួលគេចាប់ថ្នាំសម្លាប់ចោល។ ខ្ញុំក៏ពេលដែលគាត់ប្រាប់ហើយ ក៏ខ្ញុំដឹងខ្លួន។ ក៏ពេលល្ងាចពេទ្យមកចាក់ថ្នាំ ថាអត់ទេ អត់ចាក់ទេ គ្រាន់តែសុំថ្នាំលេបបានហើយ។ ដល់ពេលព្រឹកឡើង -- ល្ងាចឡើង ខ្ញុំប្រាប់ពេទ្យ ខ្ញុំចេញហើយស្អែកនោះ ហើយខ្ញុំត្រូវរបួសមិនទាន់ជាផង ទើបសើរើរបួសខ្លួននោះ ក៏ខ្ញុំត្រឡប់ ចេញថ្ងៃហ្នឹង បែកភ្នំពេញថ្ងៃបណ្តោយ។ បាន ខ្ញុំមកទៅជួបនឹងគាត់នៅសាលាខេត្ត នៅខេត្តកណ្តាលនេះ ក៏ឲ្យខ្ញុំហៅ ឲ្យនីរសារហៅខ្ញុំចូលទៅ គាត់ថា កុំអាលទៅជួយធ្វើនេះផង ជួយចាប់ម៉ូតូ ចាប់ឡាន ដែលគេសប្បាយនឹងជ័យជម្នះ ប្រជាជនសប្បាយនឹងជ័យជម្នះហ្នឹង ខ្លាចក្រែងគ្រោះថ្នាក់លន់ នល់ -- ទ័ពលន់ នល់ បោកគ្រាប់បែក វាបាញ់ងាប់។ ដល់ពេលចប់ការងារបានគាត់យកខ្ញុំទៅកន្លែងតាណាត បានតាណាត ឲ្យទៅចូលកន្លែងធ្វើជាងថតស-២១ទៅ -- អ៎! ជាងថត ៧០៣ទៅ។ ចប់ត្រឹមហ្នឹង។

[១៤:៣១:១៨]

**ស៖** ត្រឹមត្រូវហើយលោក។ ខ្ញុំយល់ហើយ លោកត្រូវរបួស ហើយលោកទៅសម្រាកពេទ្យហ្នឹង។ អ្វីដែលខ្ញុំមិនយល់នោះ អ៊ីចេះ! ថាតើហេតុអ្វីបានជាកងពល៧០៣ ត្រូវការអ្នកថតរូប? សំណួរខ្ញុំ

អ៊ីចេះទេ។ អ៊ីចឹងថាហេតុអីបានជាគេ<ឲ្យ>លោកធ្វើជាអ្នកថតរូបប្រចាំកងពល៧០៣?

**ឆ៖** នេះខ្ញុំអត់បានដឹងដែរ ប៉ុន្តែថាធម្មតា*(ឮមិនច្បាស់)* ខ្ញុំឃើញមានម៉ាស៊ីនថតច្រើន ប្រដាប់ថតច្រើន ប្រហែលត្រូវការថតកាតអ្នកនេះ ក្រែងលោមានទៅសមរភូមិណា អីណា ក្រែងវាបានថតក្នុងឯកសារទុក។

**ស៖** តើលោកធ្លាប់ចេះថតរូបអីដែរទេ មុននឹងគេចាត់តាំងលោកឲ្យមកធ្វើជាអ្នកថតរូបនៅស-២១?

**ឆ៖** ពេលនោះ ខ្ញុំអត់ទាន់ចេះទាំងអស់ ប៉ុន្តែដល់ហើយ ដល់គេបង្កើតបាន មានប្រាំមួយនាក់ដូចខ្ញុំប្រាប់អ៊ីចឹង ដល់ហើយគេរើស ជ្រើសរើសបីនាក់ទៅរៀនចិន។ ចំណែកខ្ញុំនៅបីនាក់ ក៏ខ្ញុំយកដើរមើលតាមផ្ទះ តាមផ្ទះអ្នកថត មើលតាមឯកសារ ខ្ញុំអត់ចេះភាសា ខ្ញុំចុះមកតាមមូលដ្ឋានស្វែងរកអ្នកចេះភាសាហ្នឹង បកប្រែជាភាសាខ្មែរមកវិញ។ អ៊ីចឹងត្រូវលាយថ្នាំយ៉ាងម៉េច ត្រូវធ្វើម៉េចៗ ខ្ញុំយកអាហ្នឹងមកបកប្រែជាភាសាខ្មែរ ដើម្បីរៀនជាក់ស្តែង ហើយកាលនុ៎ងអាងតែសប្បុរក្រដាស សម្បូរហ្វីលនោះចង់ខូចប៉ុន្មានក៏អត់ភ័យដែរនោះ ឲ្យតែឆាប់ចេះ។

[១៤:៣៣:១០]

**ស៖** ឥឡូវខ្ញុំចូលសួរអំពីការបណ្តុះបណ្តាលរបស់លោកឲ្យក្លាយទៅជាអ្នកថតរូប។ កិច្ចសម្ភាសន៍របស់លោកនៅក្នុងឯកសារ E3/7639, ERN ជាភាសាខ្មែរ 00162708, អង់គ្លេស 00162732, បារាំង 00338074។ នេះគឺជាកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត សូមដកស្រង់៖ “ខ្ញុំមិនដែលទៅរៀននៅប្រទេសចិនទេ។ ខ្ញុំរៀនសូត្រពីសមមិត្តរបស់ខ្ញុំ រៀនពីការងារតែម្តង។” តើលោកថា សហការី ឬសមមិត្តរបស់លោកមួយណាដែលបង្ហាត់បង្ហាញរៀនលោក ឲ្យលោកចេះថតរូបនេះ?

**ឆ៖** អង្កាល់ហ្នឹងការថតវាងាយទេ។ ការថត តែសំខាន់គឺផ្តិតនិងលាងរូបថតទេ។ តែខ្ញុំយកឯកសារដែលពីប៉ុស្តិ៍ -- ពីផ្ទះដែលជាងថត ដែលពេលគេរត់ទៅ បែកហើយរត់ទៅ គេកៀរទៅជនបទហ្នឹង ខ្ញុំយកឯកសារហ្នឹងតាមស្វែងរកអ្នកចេះដឹងខាងបច្ចេកទេសហ្នឹង ឲ្យវាបកប្រែជាភាសាខ្មែរមកវិញ ដើម្បីយកមករៀនជាក់ស្តែង រៀនបណ្តើរអនុវត្តបណ្តើរ។

**ស៖** ចុះលោកជួបអ្នកទាំងនោះដោយរបៀបណា?

[១៤:៣៤:៥២]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ជួប អង្គាល់ហ្នឹងជួបតាមរយៈដែលខ្ញុំសុំខ្មោច តាណាត។ តាណាត គាត់ប្រធានកងពលហ្នឹង ទៅទំនាក់ទំនង គាត់សុំចុះយក -- ឱ្យគាត់មើលប្រដាប់ខាង ប្រដាប់ខាងបច្ចេកទេសថតហ្នឹងឱ្យយកទៅសុំគាត់ទៅ ឱ្យចុះទៅបកប្រែ រកអ្នកបកប្រែ។

**ស៖** អ៊ីចឹង តើពេលនោះឬដែលលោករៀន បានរៀនសូត្រពីសៀវភៅហ្នឹងដោយយកសៀវភៅហ្នឹងទៅបកប្រែជាភាសាខ្មែរហើយ ទើបលោករៀនសូត្រ រៀនផ្តិតរូបរៀនអីហ្នឹង គឺជាប្រភពចំណេះដឹងរបស់លោកហើយមែនទេ?

**ឆ៖** ពេលហ្នឹង ខ្ញុំចាប់ផ្តើមរៀនបណ្តើរ អនុវត្តបណ្តើរ ដល់ពេលហើយបានរៀនតាមទ្រឹស្តី អនុវត្តទៅតាមទ្រឹស្តី បច្ចេកទេសគេបកប្រែឱ្យខ្ញុំ គឺបានអនុវត្តជាក់ស្តែងបានពិតប្រាកដមែន។ បើលាយការលាយហ្វីល ការលាងហ្វីល ការលាយថ្នាំលាងហ្វីលអី លាយថ្នាំផ្តិតរូបហ្នឹង គឺតាមការជាក់ស្តែងគឺពិតប្រាកដបានល្អមែន។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំបម្រុងនឹងចូលទៅប្រធានបទថ្មីមួយទៀតហើយ ប៉ុនមើលទៅឃើញដល់ម៉ោងសម្រាកហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ។

*(សវនាការសម្រាកពីម៉ោង ១៤:៣៦ នាទី ដល់ម៉ោង ១៤:៥៥ នាទី)*

[១៤:៥៥:៤៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឥឡូវនេះ លោកសាក្សី ខ្ញុំនឹងសួរអំពីហេតុការណ៍ដែលកើតឡើង នៅពេលដែលគេចាត់

01382324



តាំងឲ្យលោកទៅថតរូបអ្នកទោស។ តើលោកអាចប្រាប់បានទេ ថាតើគេប្រាប់លោកយ៉ាងដូចម្ដេច ថា នៅពេលអ្នកទោសមកដល់ស-២១ហ្នឹង តើគេប្រាប់លោកថាយ៉ាងម៉េចដែរ ដើម្បីឲ្យលោកដឹងទៅថតរូប នោះ?

**លោក នឹម អ៊ីម៖**

**ឆ៖** ពេលដែលអ្នកទោសមកដល់ស-២១ គឺបាន ធី គេអ្នកតេហៅខ្ញុំ តាមខ្សែទូរស័ព្ទខ្សែ។

**ស៖** លោកបាននិយាយអំពីកន្លែងដែលលោកទៅថតរូប។ ដូច្នេះ ខ្ញុំចង់បញ្ជាក់បន្តិច តើលោក ថតរូបតែមួយកន្លែងទេឬនៅពេលដែលលោកនៅស-២១ ឬមួយក៏ថាវាមានកន្លែងផ្សេងៗគ្នាជាច្រើន ក្នុង រយៈពេលដែលលោកនៅស-២១ហ្នឹង ដែលគេថតរូបអ្នកទោសហ្នឹង តើគេថតអ្នកទោសនៅតែមួយ កន្លែងទេ ឬក៏គេថតនៅកន្លែងផ្សេងៗគ្នាច្រើននៅស-២១នោះ?

**ឆ៖** ព្រោះថតកន្លែងស-២១ហ្នឹង កាលពីមុនមានតែកន្លែង ធី ហ្នឹងទេ ដែលគេអ្នកកត់បញ្ជី ចេញចូល តែក្រោយមក បានពេលដែលឈ្មោះ ស្រ៊ី ហ្នឹង គាត់មកយកម៉ាស៊ីនថត យកក្រដាស -- យក ហ្វីលអី គឺទៅថតកន្លែងអ្នកធំៗ កន្លែងថា អ្នកដែលសំខាន់ៗ អាហ្នឹងគេអត់ឲ្យខ្ញុំចូលទេ។ ព្រោះអាហ្នឹង គេទុកខាងក្រុមបក្ខជនគេអ្នកគ្រប់គ្រង។

[១៤:៥៨:២៤]

**ស៖** នៅពេលដែលលោកធ្វើការងារហ្នឹង តើលោកចំណាយពេលប្រហែលប៉ុន្មានដែរ ក្នុងការ ថតរូបអ្នកទោសម្ដងៗ?

**ឆ៖** បើគ្នាតិច តែត្រឹមបីបួននាទីវាហើយៗ បើវាតិច។ បើគ្នាច្រើន អាហ្នឹងចូលមួយម៉ោង ជាង មួយម៉ោងឯណោះ។

**ស៖** នៅពេលដែលលោកបញ្ចប់ការថតរូបអ្នកទោសហើយ តើលោកឃើញទេថា គេយកអ្នក ទោសនោះទៅណាដែរ?

**ឆ៖** គេឡើងតាមកន្លែងឃុំឃាំង សាលានេះ កន្លែងស-២១ហ្នឹង។

**ស៖** ក្រោយពីលោកបញ្ចប់ការថតរូប តើលោកទៅណាបន្តទៀត? តើលោកធ្វើអ្វីបន្តទៀត?

**ឆ៖** ពេលដែលចប់ការថតហើយ ខ្ញុំវិលទៅកន្លែងខ្ញុំវិញ។ បើហ្វីលហ្នឹងវាអស់ វាគ្រប់ចំនួន ម៉ា អស់ បានខ្ញុំលាង លាងវា លាងហ្វីលផ្ដិត។ បើថានៅ ខ្ញុំទុកសិន។

**ស៖** លោកនិយាយថា ក្រោយពេលដែលគេផ្ដិតរូបថតហើយ គឺលោកបញ្ជូនទៅ ស្ងួស ធី។ តើ

អ្នកណាជាអ្នកបញ្ជូនរូបថតហ្នឹងទៅឲ្យ ធី ហ្នឹង?

**ឆ៖** គឺរូបខ្ញុំផ្ទាល់តែម្តង។

**ស៖** ចុះហ្វីលៗលោករក្សាទុក ឬមួយក៏លោកបញ្ជូនហ្វីលហ្នឹងទៅឲ្យ ធី ដែរ?

**ឆ៖** គឺហ្វីលនៅទុកក្នុងបន្ទប់ កន្លែងខ្ញុំផ្តិត ទៅយកតែរូបថតទៅទេ។

**ស៖** តើលោកអាចប្រាប់បានទេ តើលោករក្សាហ្វីលហ្នឹងទុកដោយរបៀបណា? តើលោកមាន -- តើលោករក្សាទុកតាមថ្ងៃខែ ឬក៏មាន លោកមានលេខសម្គាល់អីដើម្បីរក្សាហ្វីលទុកដែរទេ?

**ឆ៖** ទុក ហ្វីលទុកទាំងអស់តែម្តង ទុករុំចោល រុំវាតាមលំដាប់លំដោយដែលដាក់ក្នុងនេះ ដាក់ក្នុងម៉ាស៊ីន ដែលបន្ទប់ម៉ាស៊ីនត្រជាក់ទៅ។

[១៥:០២:០៥]

**ស៖** ខ្ញុំចង់សួរលោកអំពីអ្វីដែលមេធាវីការពារក្តីបានសួរលោករួចមកហើយ ដោយសារខ្ញុំមិនច្បាស់អ្វីដែលលោកឆ្លើយ។ លោកបាននិយាយថា ពេលខ្លះលោករង់ចាំបួនប្រាំថ្ងៃរហូតដល់ពេលមានអ្នកទោសគ្រប់គ្រាន់ដើម្បីឲ្យលោកថតរូបនោះ។ ខ្ញុំចង់សួរថា ក្នុងរយៈពេលបួនប្រាំថ្ងៃ ដែលអ្នកទោសរង់ចាំហ្នឹងគាត់រង់ចាំនៅកន្លែងណាដែរ? ក្នុងរយៈពេលបួនប្រាំថ្ងៃហ្នឹង តើគេ<ធ្វើអ្វី>អ្នកទោស<>ដែរ?

**ឆ៖** អានេះមិនមែនគេទុកអ្នកទោសទេ គឺថាហ្វីលខ្ញុំមិនទាន់អស់ តែកាត់ទៅវាខ្លាចខូច ត្រូវពន្លឺទៅវាខូចនេះ សុខចិត្តអស់ ចំនួនថាក្នុងការ ក្នុង៣៦ប៉ុស្តិ៍ ឧទាហរណ៍ ទាល់តែអស់គ្រប់៣៦ប៉ុស្តិ៍ បានខ្ញុំលាងហ្វីលហ្នឹងដើម្បីយកប្រើការ។ ហើយបើយើងកាត់វាទៅ ខ្លាចខូចអាហ្វីលរូបថតមុននោះ អាហ្វីលថតមុន តែចូលពន្លឺខូចហើយ។

**ស៖** ខ្ញុំយល់ ប៉ុន្តែ<ប្រហែល>ជាខ្ញុំស្តាប់មិនច្បាស់។ លោកថា លោករង់ចាំបួនប្រាំថ្ងៃមុនពេលផ្តិត មុនពេលលាងហ្វីល ឬមួយក៏លោករង់ចាំបួនប្រាំថ្ងៃមុនពេលដែលលោកទៅថតអ្នកទោស។ តើអាបួនប្រាំថ្ងៃហ្នឹងរង់ចាំដើម្បីលាងហ្វីល ឬក៏រង់ចាំដើម្បីថតរូបអ្នកទោស?

**ឆ៖** រង់ចាំហ្នឹងគឺថា ដូចថាខ្ញុំថតបានក្នុងបី មកហ្នឹងបានបីនាក់ឧទាហរណ៍ តែទើបអស់ឧទាហរណ៍ ៣៦ប៉ុស្តិ៍ វាទើបអស់តែបីប៉ុស្តិ៍ វានៅសល់៣៣ទៀត។ ដល់អីចឹងទាល់អស់ ព្រោះបានអស់ហ្វីលហ្នឹងថតបានគ្រប់ចំនួនប៉ុស្តិ៍ហ្នឹងហើយបានខ្ញុំបញ្ចូល ចូលលាងបាន ធ្វើការបាន ព្រោះកាត់ទៅ ដូចខ្ញុំប្រាប់អំមិញថា កាត់ទៅវាខ្លាចខូច ខូច។ តែកាត់មួយកាត់ បើបង្ខំ បានខ្ញុំតស៊ូកាត់។ ចូលក្នុងបន្ទប់ងងឹត ខ្ញុំកាត់អាហ្នឹងយកមកដាក់ក្នុងកំប៉ុងលាងហ្វីលទៅ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:០៤:៣៥]

**ស៖** ខ្ញុំយល់ខ្លះហើយ។ ឥឡូវនេះ ខ្ញុំបញ្ជាក់ឲ្យច្បាស់បន្តិច អ៊ីចឹងបានន័យថាលោកថតរូបបីរូបមួយថ្ងៃ ហើយមួយថ្ងៃទៀតលោកថត១០នាក់ ហើយបន្ទាប់មកទៀត ប្រាំ។ អ៊ីចឹងបានន័យថារហូតដល់ពេលដែលលោកថតអស់ ៣៦ហ្វីលហ្នឹង ទើបលោកយកហ្វីលហ្នឹងទៅលាង។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពីព្រោះអាហ្នឹង ដល់អស់បានប៉ាន់លាង។

**ស៖** មេធាវី នួន ជា បានបង្ហាញលោក ហើយក៏បានសួរលោកអំពីទម្រង់រូបថតនៅស-២១ ដែលយើងឃើញជាទូទៅ ហើយលោកបាននិយាយអំពីរយៈពេលមួយ គឺរយៈពេលដែលថា ថតរូបអត់មានដាក់លេខអីទាំងអស់ ហើយលោកនិយាយអំពីការថតរូបអ្នកទោសឲ្យឈរជាប់ជញ្ជាំង។ ដូច្នេះ ខ្ញុំសូមបង្ហាញនូវរូបថតមួយចំនួន ដើម្បីឲ្យលោកពិនិត្យមើល ថាតើរូបថតហ្នឹងឬ ជាអ្វីដែលលោកនិយាយ ហើយខ្ញុំចង់ឲ្យលោកបញ្ជាក់ថាតើលោកស្គាល់ទីតាំងថតរូបដែរឬទេ?

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញរូបថត មួយចំនួនជូនទៅសាក្សី ហើយក្នុងពេលដែលខ្ញុំផ្តល់ហ្នឹង ខ្ញុំនឹងអានអំពីកំណត់ត្រា។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកឯកសារនេះ យកទៅបង្ហាញសាក្សី។

[១៥:០៦:២៤]

**លោក ឌេល លីសាក់៖**

រូបថត ដែលខ្ញុំផ្តល់ជូនសាក្សីហ្នឹង គឺប្រភពរូបថត ដែលមានរូបថតជាង៥.០០០រូបថត ហើយរូបថតទាំងអស់នោះ គឺលើឯកសារ E3/8639. គឺរូបថតមានចាប់ពីលេខ១ រហូតទៅដល់រូបថតលេខ <ជាង> <៥១០០> ហើយរូបថតនីមួយៗនេះ ដែលខ្ញុំនឹងប្រើប្រាស់នៅថ្ងៃនេះ គឺឯកសារ E3/8639. ខ្ញុំភ្លេចលេខកន្ទុយហ្នឹងហើយ ហើយរូបថតដែលបង្ហាញជូនសាក្សីហ្នឹង គឺ E3/8639.4427, .5089, .4926, .4724 និង .5184។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញនូវរូបថតមួយចំនួនផងដែរ នៅលើអេក្រង់។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីសោតទស្សន៍ ដាក់បង្ហាញរូបថតហ្នឹង លើអេក្រង់ទូរទស្សន៍។

[១៥:០៧:៥៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ដូច្នេះ នៅក្នុងរូបថតបីបួនដំបូងដែលខ្ញុំប្រគល់ជូនលោក គឺលោករូបអ្នកទោសដែលឈរនៅខាងក្រៅ ដូចជាឈរនៅក្បែរជញ្ជាំង។ រូបថតដែលបង្ហាញនៅលើអេក្រង់នេះ គឺ<៤៩២៦> ដែលមានអគារ មានបន្ទប់។ តើលោកចាំទីតាំងនេះទេលោកសាក្សី?

**លោក នឹម អ៊ឹម៖**

**ឆ៖** កន្លែងទីតាំងនេះ អាហ្នឹងកន្លែង ធី អ្នកគ្រប់គ្រង កត់អ្នកទោសចេញចូល អាកន្លែងនេះមួយហ្នឹង។ អគារពីមុខ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដើម្បីជាកំណត់ត្រាប្រតិចារឹក គឺ4931 ប៉ុន្តែខ្ញុំឮនិយាយថា <3926>។

**លោក វ៉ិចទ័រ កូប៉េ៖**

<អត់ទេ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<អាមួយដែលដាក់បញ្ចាំងលើអេក្រង់នេះឬ?>

**លោក វ៉ិចទ័រ កូប៉េ៖**

<អត់ទេ នោះជាលេខមកពីខាងឃែល>។ លេខ<២៦>ដែលគាត់អាននេះ គឺលេខ ERN។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មិនអីទេ។

**លោក ឌេល លីសាក់៖**

លេខដែលខ្ញុំអាននេះ គឺលេខចុងកន្ទុយនៃឯកសារ E3 តែប៉ុណ្ណោះ លោកស្រីចៅក្រម។

[១៥:០៩:១៦]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកសាក្សី។ រូបថតចុងក្រោយ -- រូបថតពីរទៀត ដែលខ្ញុំផ្តល់ជូនលោកផងដែរនោះ គឺ4724 និង 5184 ហើយរូបថតទាំងពីរនេះ គឺហាក់ដូចជាគេថតនៅក្នុងអគារមួយ ដូចជាអគារជាន់ណាមួយអ៊ីចឹង។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបង្ហាញនូវអេក្រង់ផងដែរ ថាតើលោកចាំទីតាំងនេះទេ?

**លោក នឹម អ៊ឹម៖**

**ឆ៖** ព្រោះរូបថតនេះ គឺពេលដែលអ្នកដែលគេយកមកយប់ ដល់ហើយគេដាក់កន្លែងបន្ទប់រួមហ្នឹង ខ្ញុំឡើងទៅថតអាកន្លែងបន្ទប់រួមខាងផ្នែកនារីហ្នឹង ជាអគារនៅខាងជើង។

**ស៖** នៅពេលដែលលោកនិយាយថា អគារនៅខាងជើងហ្នឹង តើអគារហ្នឹងនៅក្នុងបរិវេណ ឬក៏នៅក្នុងអគារដែល ដែល ស្ងួស ធី ធ្វើការហ្នឹង ឬក៏នៅខាងក្រៅបរិវេណនោះទេ?

**ឆ៖** វាមិនមែនអគារ ធី ធ្វើការ ជាកន្លែងដាក់អ្នកទោស ប៉ុនកន្លែងខ្លះមានកន្លែងរួម ដាក់មនុស្សច្រើន ដែលវាមកពេលយប់ បញ្ចូលហ្នឹងទៅ។

**ស៖** មុននេះលោកបាននិយាយថា នៅពេលដែលដំបូងៗនៃស-២១ ការថតរូបគឺថាគេ<ថតក្នុងទ្រង់បែបនេះ គឺធ្វើឡើង>មុនពេលដែលលោកមកប្រើប្រាស់ប្រព័ន្ធលេខនោះ។ ដូច្នេះ តើលោក<ចាំ>ទេថា ប៉ុន្មានខែ<>ដែល<លោក>ថត<រូបក្នុងទម្រង់បែបនេះ មុនពេលដែលលោកចាប់ផ្ដើមប្រើប្រាស់លេខរៀងនោះ>? ថាតើលោកចាំទេ ប៉ុន្មានខែ មុនដែលលោក<ប្រើលេខរៀងនោះ>?

**ឆ៖** ព្រោះពេលហ្នឹងអត់ទាន់មានអ្នកថតទេ។ ពេលដែលខ្ញុំមកដល់ ខ្ញុំតាមដានមើល។ ដល់ពេលខ្ញុំចាប់ធ្វើ ក៏អត់ដាក់លេខដែរ។ ទើបដាក់លេខក្រោយនេះទេ អាលេខហ្នឹង។ កាលខ្ញុំមកដល់ ក៏អត់មានទាន់ដាក់លេខដែរ។

[១៥:១២:១៧]

**ស៖** អរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំនឹងសួរលោកអំពីរូបថតមួយចំនួនទៀត ហើយដូចៗដែលមេធាវីការពារក្ដីបានសួរដែរ គឺជារូបថតរបស់អ្នកទោសដែលគេថតទាំងមុខ និងថតពីចំហៀងដែលយើងឃើញនៅឆ្នាំ៧៨។ ដូច្នេះខ្ញុំសូមអនុញ្ញាតផ្ដល់រូបថតមួយចំនួនជូនទៅសាក្សី គឺរូបថតដែលថតពីចំហៀងផងដែរ លោកប្រធាន។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតផ្ដល់នូវរូបថតនេះជូនដល់សាក្សី។ ហើយខ្ញុំនឹងបង្ហាញអំពី<រូបថតទាំងនោះ ពេលដែលសាក្សីបានទទួលហើយ>។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ យករូបថតនេះជូនសាក្សី។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**លោក ខេល លីសាក់៖**

រូបថតបន្តដែលខ្ញុំផ្ដល់ជូននេះគឺឯកសារ <E3/8639.193>, .196, .4149, .<4192>

ហើយនិងមានរូបថតនៅខាងក្រោយដែលមានលេខឯកសារ E3 ខុស<គ្នា> គឺ E3/8063.74<>។ សូមអនុញ្ញាតបង្ហាញផងដែរនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីសោតទស្សន៍បង្ហាញឯកសារនេះលើអេក្រង់ទូរស្សន៍។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ដូច្នេះរូបថតនេះ គេថតពីចំហៀង ដែលយើងឃើញនៅលើអេក្រង់នេះ គឺ .193។ យើងឃើញថារូបថតហ្នឹង គេដាក់<អ្នកទោសឱ្យអង្គុយនៅលើកៅអីមួយប្រភេទ> ហើយឃើញឧបករណ៍មួយទៀតនៅ<ក្រោយ>ក្បាលរបស់អ្នកទោសនេះ។ តើលោកអាចប្រាប់តុលាការបានទេថា តើអ្នកទោសអង្គុយ<លើអ្វី>ដែរ? ហើយឧបករណ៍ដែលយើងឃើញនៅពីក្រោយក្បាលរបស់អ្នកទោសហ្នឹង តើជាឧបករណ៍អ្វីដែរ?

[១៥:១៥:០០]

**លោក នឹម អ៊ីម៖**

**ឆ៖** បញ្ហាថតចំហៀងនេះ ហើយថតចំមុខ ហើយថតចំហៀងឱ្យអង្គុយអាកន្លែងប្រដាប់ហ្នឹង គឺសម្រាប់ តាឌុច គាត់បញ្ជាឱ្យចុងក្រោយហើយទេ គាត់បានពីណាមកយកមកឱ្យខ្ញុំណា ដល់ហើយគាត់ចាប់ផ្តើមថតចំមុខផង ថតចំហៀងផង ផ្សេងពេលខ្លះវាស់កម្ពស់ទៀត ហើយវាស់កម្ពស់អត់ដែលបានថត ក៏វាស់កម្ពស់កត់ទៅ កម្ពស់ប៉ុន្មានអីប៉ុន្មានទេ។

**ស៖** នៅពេលដែលលោកវាស់កម្ពស់អ្នកទោស ថាតើលោក<កត់ត្រាទុកនៅកន្លែង>ណាដែរ ហើយតើ<ព័ត៌មាននេះគេយកទៅធ្វើអី>ដែរ?

**ឆ៖** បង្រៀនបាន ប៉ុនមិនដឹងបានប៉ុន្មានថ្ងៃ ខ្ញុំធ្វើបានតែប៉ុណ្ណឹងទេ ក្រោយមកខ្ញុំថតតែប៉ុណ្ណឹង ឈប់ថតទៅ ខ្ញុំធ្វើធម្មតាវិញ។ មើលទៅវាញឹកៗ វាពិបាកពេក។

**ស៖** ឥឡូវនេះ យើងសូមមើលទៅលើរូបថតចុងក្រោយគឺ E3/8063.74 គឺជារូបថតដែលមានកៅអី ដែលរូបថត គឺថតអង្គុយលើកៅអី។ ប្រសិនបើលោកមើលទៅលើរូបថតហ្នឹង គឺលោកឃើញកៅអី ហើយយើងយកចេញពីសារមន្ទីរទួលស្លែង ថាតើក្នុងឆ្នាំ៧៨ លោកបានថតអ្នកទោសដែលអង្គុយកៅអី អ៊ីចឹងដែរទេ?

**ឆ៖** ថតបានតិចណាស់អាអង្គុយនៅកៅអី ហើយចំហៀង ហើយដាក់ចំហៀងបានតិចទេ បាន

តិចគ្នាទេ អត់ព្រោះពេលនោះវាថតអាចំហៀងហ្នឹង វាចាក់ចុះហ្វីលពេក ម្នាក់ពីរប៉ុស្តិ៍ៗ វាចុះហ្វីល។ បានខ្ញុំប្រាប់ តាឌុច គាត់ថាបងចុះហ្វីលណ៎ា ក្រដាសក៏ចុះ អាកៅអីហ្នឹងក៏ទើបនឹងចាប់នេះ កាលមុនបាន កៅអីមកនេះ បានគេឱ្យអង្គុយថតទៅ ជួនណាថតឈរទៅ ថតកាត់ ដល់ពេលថតតែមួយកំណាត់ទៅ ឱ្យគេឈរទៅ។ អាហ្នឹងទើបនឹងរៀបចុងក្រោយហើយទេ រៀប២០០០ -- និយាយពី--

[១៥:១៧:៤៩]

**ស៖** ប៉ុន្តែខ្ញុំចង់សួរលោកអ៊ីចេះវិញ <គឺឱ្យលោក>និយាយពីកៅអី<ថែមបន្តិច>ទៀត <តើនេះជាកៅអីដូចគ្នា> គឺដូចកៅអី<ដែលយើងឃើញ>អ្នកទោស<ក្នុងរូបថតមុន>នោះ<ទេ?> តើវាកៅអីតែមួយ ឬក៏កៅអីផ្សេងគ្នា?

**ឆ៖** មានឃើញតែមួយទេអាហ្នឹង មានតែមួយទេ មាននេះ ពួកអាប្រភេទនេះមានតែមួយទេ។

**ស៖** ហើយកៅអីហ្នឹង គឺគេទុកនៅរហូតនៅក្នុងបន្ទប់ថតរូបហ្នឹងទេនៅក្នុងឆ្នាំ៧៨នោះ?

**ឆ៖** នៅកន្លែង ធី គេនេះនោះ។

**ស៖** លោកសាក្សី តើធ្លាប់មានពេលណាមួយដែលគេថតរូបអ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងរបស់ពួកគាត់ទេ?

**ឆ៖** មាន។ ពេលដូចថា វាទៅយកមកយប់អ៊ីចឹង ដល់ព្រឹកឡើង គេអត់មានអ្នកណាគេយកចុះឱ្យ ធី ឱ្យគេអ្នកអង្គរក្សយាម ហ្នឹងហៅខ្ញុំឡើងទៅថតរូបហ្នុងទៅ។

**ស៖** តើលោកទៅថតរូបនៅក្នុងបន្ទប់ឃុំឃាំងហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ពេលខ្ញុំទៅបានប្រហែលពីរដងទេ។

[១៥:២០:១០]

**ស៖** ក្នុងពេលដែលគេឱ្យលោកទៅថតអ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងតែម្តងនោះ តើលោកអាចប្រាប់បានទេ ថាលោកឃើញយ៉ាងម៉េចដែរ ឃើញអ្វីដែរ ទាក់ទងទៅនឹងស្ថានភាពរបស់អ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងនោះ?

**ឆ៖** ឃើញទៅ បើទៅចូលអាកន្លែងបន្ទប់រួម អាហ្នឹងមនុស្សអត់ច្រវាក់ទេ អត់ដាក់ខ្នោះទេ។ បើថាបន្ទប់មួយៗ អាហ្នឹង ខ្នោះ ដាក់ខ្នោះជើង។ ខ្នោះជើងទាំងពីរ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញរូបថតមួយចំនួនទៀត ដែលជារូបថតអ្នកទោសនៅក្នុង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បន្ទប់ឃុំឃាំងរបស់ពួកគេ។ ហើយខ្ញុំសូមអនុញ្ញាតផងដែរ បង្ហាញ ប្រគល់រូបថតនេះជូនទៅ<សាក្សី> ហើយ ក្នុងពេលជាមួយនេះ ខ្ញុំនឹងផ្ដល់នូវលេខឯកសារយោង។

[១៥:២១:១៥]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ យកឯកសារនេះ ជូនទៅសាក្សី។

**លោក ឌេល លីសាក់៖**

ដើម្បីកំណត់ត្រាប្រតិចារឹក រូបថតដែលខ្ញុំផ្ដល់ជូនដល់សាក្សីនេះគឺ <E3/8639.3299>, .3303, .3795, .3859 និង .2585។ ហើយខ្ញុំសូមអនុញ្ញាតនៅលើអេក្រង់ផងដែរ ដោយសូមអនុញ្ញាតបង្ហាញ ទី១ គឺ E3/8639.3299។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ដាក់បញ្ចាំងឯកសារនេះ លើទូរទស្សន៍។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅពេលដែលលោកផ្ដល់សក្ខីកម្មអំពីអ្នកទោសដែលគេថតនៅក្នុងបន្ទប់ឃុំឃាំង ថាតើគឺដូចនឹងរូបថតដែលខ្ញុំបង្ហាញរបស់លោក គឺថារូបថតដែលខ្ញុំប្រគល់ជូនលោកនោះ គឺជារូបថតដែលគេថតអ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងហ្នឹង តើមែនទេ?

**លោក នឹម អ៊ឹម៖**

**ឆ៖** ហ្នឹងពិតមែនហើយ ព្រោះពេលនោះ គឺគេអត់យកចុះមក គេដាក់ខ្នោះនៅហ្នឹង គេអត់បណ្ដើរចុះមកទេ។ គេហៅខ្ញុំទៅថត បានខ្ញុំយក ខ្ញុំប្រើកាំម៉ារ៉ា -- ដាក់ទៅថត យកប្រដាប់ផ្លាស់សម្រាប់បើកចុចដាក់យកភ្លើងជំនួយហ្នឹង។ ព្រោះថា នេះហ្នឹង គេអត់យកទុកឲ្យ ឲ្យអ្នកនេះ យកអត់ចុះទេ។ ព្រោះគ្នាវាច្រើន ថ្ងៃហ្នឹង។

[១៥:២៣:៤៦]

**ស៖** នៅពេលដែលលោកថតរូបអ្នកទោស គឺថាមិនមែនថតនៅក្នុងបន្ទប់ឃុំឃាំងទេ ប៉ុន្តែនៅក្នុងបន្ទប់ធម្មតា។ តើពេលខ្លះអ្នកទោសគេដាក់ខ្នោះដែរឬទេ? នៅពេលដែលគេថតពួកគាត់នៅក្នុងបន្ទប់ធម្មតាហ្នឹង តើអ្នកទោសមានគេដាក់ខ្នោះដៃ ឬក៏ខ្នោះជើងដែរឬទេ?

**ឆ៖** ព្រោះអ្នកទោសនេះ គឺគេដាក់ខ្នោះជើងហើយៗ ព្រោះនៅបន្ទប់តូច ម្នាក់ បន្ទប់មួយម្នាក់

ហ្នឹងណ៎ា គឺខ្នោះជើងហើយស្រេចហើយ។

**លោក ឌេល លីសាក់៖**

ខ្ញុំសូម<ការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញ>រូបថត<បី>ផ្សេងមួយទៀត <ហើយខ្ញុំនឹងកំណត់អត្តសញ្ញាណរូបថតទាំងនោះនៅក្នុងប្រតិចារឹក>។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ យករូបថតនេះបង្ហាញសាក្សី។

[១៥:២៥:០១]

**លោក ឌេល លីសាក់៖**

ដើម្បីជាកំណត់ត្រាប្រតិចារឹករូបថតដែលខ្ញុំប្រគល់គឺ <E3/8639.3319>, .3321 និង .3813។ ហើយខ្ញុំសូមអនុញ្ញាតលោកប្រធានផងដែរបង្ហាញនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីសោតទស្សន៍បង្ហាញរូបថតនេះលើអេក្រង់ទូរទស្សន៍។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមចាប់ផ្តើមរូបថតទី១ គឺ .3319 យើងឃើញអ្នកទោសនៅទីនេះគឺ គាត់ជាប់ខ្នោះដៃ។ តើលោករូបថតហ្នឹងគេថតនៅក្នុងបន្ទប់ឃុំឃាំង ឬក៏នៅក្នុងបន្ទប់ធម្មតា គឺបន្ទប់ថតរូបអ្នកទោសនោះ?

**លោក នឹម អ៊ីម៖**

**ឆ៖** ព្រោះរូបថតនេះ គឺអ្នកទោសទើបមកដល់ បានខ្ញុំថតជញ្ជាំងក្រោយជាប់ជញ្ជាំង ធី នៅហ្នឹង។ អ្នកមិនទាន់ថត ឲ្យឈរទៅ អ្នកថតឲ្យអង្គុយលើកៅអី។

**ស៖** តើមានអ្នកទោសដែលគេយកមកបន្ទប់<>ហ្នឹងក្រៅពីគេដាក់ខ្នោះហ្នឹង តើគេមានចងមុខដែរឬទេ?

[១៥:២៦:០៦]

**ឆ៖** ពេលដែលនាំចូលមកពីក្រៅ ចូលមកនៅក្នុងហ្នឹង ភាគច្រើនគេចងមុខ បានដល់ពេលខ្ញុំថតបានគេស្រាយមុខចេញ។ ឲ្យអ្នកការពារគេស្រាយមុខចេញ។

**លោក ឌេល លីសាក់៖**

ដូច្នេះខ្ញុំសូមអនុញ្ញាតបង្ហាញនូវរូបថតមួយទៀតគឺ 3321។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំគ្រាន់តែស្នើសុំអនុញ្ញាតបញ្ចាំងនៅលើអេក្រង់ប៉ុណ្ណោះ ឥឡូវគឺគេបញ្ចាំងហើយ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** <តើ>នេះគឺជាឧទាហរណ៍មួយទៀតដែលលោកទើបតែរៀបរាប់<នោះឬ? តើនេះគឺជា> រូបថតដែលយើងឃើញអ្នកទោស ដែលអ្នកទោសដែលមិនទាន់<ដល់វេនគេ>ថតរូបហ្នឹងឃើញគេចង មុខគាត់<ហ្នឹងមែនទេ?>

**លោក នឹម អ៊ឹម៖**

**ឆ៖** ហ្នឹងអាពេលនាំចូលមក ដូចខ្ញុំប្រាប់អ៊ីចឹងថា ពេលចូលមក គេចងមុខមកពីក្រោមក។ ចុះពីឡានមកគេចងមុខហើយ ហើយគេចងមុខតាំងពីចាប់ណោះ បើតាមខ្ញុំសន្និដ្ឋាន យកមកតាមផ្លូវគឺចងមុខហើយស្រេចហើយ មកដល់ក៏គេចងមុខ មកដល់ជាងថត ស្រាយម្នាក់ថតម្នាក់។ ស្រាយហើយបានគេយក ថតអស់ហើយបានគេយកឡើងទៅកន្លែងអគារលើទៅ។

[១៥:២៨:០៤]

**ស៖** ហើយខ្ញុំសូមអនុញ្ញាតបង្ហាញរូបថតបន្ទាប់ គឺរូបថត .3813។ លោកសាក្សីសូមលោកមើលទៅលើរូបថតចុងក្រោយនៅក្នុងរូបថតដែលខ្ញុំផ្តល់ជូនលោកនោះ។ នៅក្នុងរូបថត 3813 នេះយើងឃើញអ្នកទោសអង្គុយនៅលើឥដ្ឋ ហើយដៃរបស់គាត់ហ្នឹងគឺ គេចងស្ពាបសេក ហើយមើលទៅដូចជាចងទៅនឹងខ្សែពួរ ឬក៏ច្រវាក់អ្វីអ៊ីចឹងដែរ។ ដូច្នេះខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់។

លោកប្រធានសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ផង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** <តើលោកចាំថាអ្នកទោសដែលបានបញ្ជូនចូលក្នុងបន្ទប់ហ្នឹង គឺត្រូវបានគេចងដៃទៅក្រោយដោយភ្ជាប់ទៅនឹងច្រវាក់ បើតាមមើលរូបនេះទៅ មែនទេ?>

**លោក នឹម អ៊ឹម៖**

**ឆ៖** រូបនេះ គឺបែបចងយកមកហើយ ចងអត់ខ្មោះតាមមើល ហើយបន្ទាប់មកអង្គុយអែបជញ្ជាំងដែល ទ្រី នៅហ្នឹង ហើយថត។

**ស៖** បើខ្ញុំយល់មិនច្រឡំទេអ្នកទោសហ្នឹងគឺគេចងដៃភ្ជាប់ <>ទៅនឹងពួរមែនទេ?

**ឆ៖** តាមខ្ញុំមើល ខ្សែៗពួរហើយ។

**ស៖** យើងបាននិយាយគ្នាអំពីហ្វីលដែលលោកបានប្រើប្រាស់ ហើយយើងក៏បានពិភាក្សាគ្នារួចមកហើយដែរ លោកប្រធាន។ ខ្ញុំមានរូបថតមួយចំនួនដែលចង់ឲ្យសាក្សីពិនិត្យមើល និងសួរគាត់អំពីការអនុវត្តជាក់ស្តែងរបស់គាត់ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ហ្វីលទាំងនេះ។

[១៥:៣១:៤៦]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកឯកសារនេះជូនសាក្សី។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** រូបថតមួយចំនួនបន្ទាប់នេះ គឺឯកសារ <E3/8639.1064>, .4, .48, .386 និង .703 ។ ហេតុផលដែលខ្ញុំផ្តល់រូបមួយចំនួននេះ គឺយើងឃើញថារូបថតនីមួយៗនេះ គឺមានឈ្មោះដែលគេសរសេរ ឈ្មោះនៅលើហ្វីលនេះផងដែរ ហើយហ្វីលមួយចំនួននោះ គឺយើងឃើញមានពណ៌ខ្មៅ ហើយរូបថតខ្លះទៀតហ្នឹងក៏អ៊ីចឹងដែរ គឺមានសរសេរឈ្មោះជាពណ៌ប្រផេះៗ។ សំណួររបស់ខ្ញុំ សួរថា តើមានពេលណាដែលឈ្មោះរបស់អ្នកទោសនេះត្រូវបានគេសរសេរនៅលើហ្វីលអីដែលលោកបានរក្សាទុកនោះដែរឬទេ? មានគេសរសេរឈ្មោះអ្នកទោសនៅលើហ្វីលដែលលោកបានរក្សាទុកដែរឬទេ?

[១៥:៣៣:២៦]

**លោក នឹម អ៊ឹម៖**

**ឆ៖** បើបានថតមានដាក់ឈ្មោះហើយ គឺហ្វីលទាំងអស់ (ឮមិនច្បាស់) នៅក្នុងបន្ទប់ទាំងអស់នៅក្នុងបន្ទប់ដែលខ្ញុំរក្សាទុកហ្នឹងទាំងហ្វីល ទាំងរូបថត អ៊ំ! ទាំងហ្វីល ទាំងក្រដាសអីនៅហ្នឹងទាំងអស់ អាហ្វីលចាស់ ហ្វីលថ្មីហ្នឹងណា។

**ស៖** តើមានពេលណាមួយ ឬឱកាសណាមួយ ដែលឈ្មោះរបស់អ្នកទោសហ្នឹង ត្រូវបានគេកត់ត្រា ឬក៏សរសេរនៅលើហ្វីលដែរឬទេ?

**ឆ៖** អត់មានសរសេរទេ។ គឺសរសេរៗជាប់អាកន្លែងនេះតែម្តង កន្លែងដាក់ក្តារ ដាក់ក្រដាសអី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្នឹងឲ្យកាន់នោះមាន ប៉ុន្តែមិនបានទូទៅទាំងអស់ទេ។

**ស៖** ដូច្នេះ គេមានរបាមួយ អ៊ីចឹងនៅលើរបាឈើហ្នឹង គេសរសេរថាដូចម្ដេចដែរ?

**ឆ៖** គឺជួនណាគេដាក់ថ្ងៃៗ លេខ ហើយនិងឈ្មោះដែលនេះទៅ ព្រោះធ្វើកន្លងមកវាអត់មានអី បានទូទៅ ម្ដងធ្វើអ៊ីចេះម្ដងអ៊ីចុះរហូត ផ្លាស់ៗកម្មវិធីរហូត។

**ស៖** ហើយអក្សរដែលសរសេរដោយដៃ គឺសរសេរឈ្មោះអ្នកទោសនេះ តើជាអ្នកសរសេររបស់លោក ឬក៏ជាអក្សររបស់អ្នកផ្សេង?

**ឆ៖** មិត្តនិត ហើយ និត, សុង គ្នាអត់សូវចេះអក្សរ បានជាគ្នាឲ្យគេសរសេរឲ្យទៅ។ ចំណែកខ្ញុំៗសរសេរខ្លួនឯង។

**ស៖** សូមអរគុណលោកដែលបានបញ្ជាក់អំពីចំណុចនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអធ្យាស្រ័យដែលខ្ញុំកាត់ផ្ដាច់។ យើងខ្ញុំក៏ចង់ឃើញហ្វីលបញ្ចាំងនៅលើអេក្រង់នេះផងដែរ។ ខ្ញុំរីករាយ បើសិនណាជាអ្នកបង្ហាញហ្វីលនេះនៅលើអេក្រង់ផងដែរ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** អ៊ីចឹងសុំបង្ហាញហ្វីលទី១ គឺ<8639.1064>។ បើខ្ញុំយល់មិនច្រឡំទេ លោកសាក្សីនេះគឺជាអក្សររបស់លោក។ ហើយនេះគេសរសេរនៅលើរបាឈើមួយភ្ជាប់ទៅនឹងហ្វីល អ៊ីចឹងមែនទេ?

[១៥:៣៧:០៤]

**ប្រធានអង្គជំនុំ៖**

លោកសាក្សីៗកុំអាលទាន់ឆ្លើយ។ ឆ្លើយចាំពេលមីក្រូហ្វូនលោកសាក្សីប្រតិបត្តិការចេញភ្លើងក្រហមសិន ចាំឆ្លើយ។

**លោក នឹម អ៊ឹម៖**

**ឆ៖** ព្រោះការសរសេរនេះគឺអក្សរខ្ញុំហើយ នៅឈ្មោះហ្នឹង។ ប៉ុន្តែអាលេខក្រោមគឺលេខ ជាលេខ មានលេខធ្វើសម្រាប់បញ្ចេញបញ្ចូលបាន ដូចពីសូន្យ រហូតទៅដល់លេខប្រាំបួន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ដើម្បីឲ្យច្បាស់លាស់សម្រាប់ប្រតិចារឹក នៅលើរូបថតនោះ គឺគេមានស្លាកលេខមួយដែរ ដែលភ្ជាប់ទៅនឹងអ្នកទោស ហើយក៏មានសរសេរលេខ។ លេខនេះគឺថាជាលេខប្រើប្រាស់ដោយខាង

ផ្នែកសារមន្ទីរទួលស្លែងក្រោយមកទេ។ លោកសាក្សី លោកបាននិយាយខ្លះៗមកហើយនូវអ្វីដែលមេធាវីការពារក្ដីបានលើកឡើងនោះ។ លោកបានឆ្លើយថា ជាពិសេស <>ពេលវេលា<ចុងក្រោយ>នៅស-២១ លោកថា លោកកម្រនឹងថតរូបណាស់ គឺលោកប្រើប្រាស់ សុង ឲ្យទៅថត។ នៅពេលដែលលោកថាមានតែឱកាសម្ដងម្កាលនោះទេដែលលោកបានទៅថត។ អ៊ីចឹង តើលោកខ្លួនឯងផ្ទាល់រៀងរាល់ខែហ្នឹង តើលោកថតញឹកញាប់ប៉ុន្មានដែរក្នុងមួយខែៗហ្នឹង បានទៅថតញឹកញាប់ប៉ុនណាដែរ?

[១៥:៣៨:៥៧]

**ឆ៖** នេះវាតាមកាលកាលៈទេសៈដែលអ្នកទោសចូល គេនិយាយថាបញ្ជូនមកពីតាមមូលដ្ឋានច្រើន។ ជួនណាថ្ងៃណានេះទៅ មកបួនដប់ម្ភៃសាមសិបនាក់អី ខ្ញុំជួយទៅថតទៅ។ បើថាម្នាក់ពីរនាក់ ខ្ញុំឲ្យតែ និត, សុង គេទៅថតទៅ។ ហើយបើថា បើតាមនេះកាលៈទេស វាទៅជួនណាមកញឹកញាប់ ដូចខ្ញុំថាក្នុងមួយខែមក ទៅបានបួនដប់ដងដែរ បើសិនជាច្រើនញឹកញាប់ពេកណ៎ា។ ខ្ញុំឲ្យ និត, សុង វាទៅថតទៅ។

**ស៖** បាទ ខ្ញុំសូមសួរពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយជាមួយសហចៅក្រមស៊ើបអង្កេតគឺ E3/7639, ERN ភាសាខ្មែរ 00162714, អង់គ្លេស 00162738, បារាំង 00338081។ លោកបានឆ្លើយថា៖ "ខ្ញុំគិតថាប្រហែលអ្នកទោស២០០ ទៅ៣០០នាក់ដែលខ្ញុំបានថតរូប" បញ្ចប់ការដកស្រង់។ ខ្ញុំសូមបញ្ជាក់ត្រង់ចំណុចនេះបន្តិចលោកសាក្សី តើលោកនិយាយថាខ្លួនលោកផ្ទាល់នេះ គឺថាបានថតរូបអ្នកទោសតែចំនួន២០០ ឬក៏ទៅ៣០០តែប៉ុណ្ណោះទេឬ? ហើយក្រៅពីនោះ គឺថាបុគ្គលិករបស់លោក កូនចៅរបស់លោកជាអ្នកថត ឬក៏ខ្ញុំស្ដាប់ច្រឡំទេ នៅពេលដែលលោកលើកតួលេខ រូបថត២០០ ទៅ៣០០រូបថត ដែលថាលោកបានថតតែប៉ុណ្ណោះនេះ?

[១៥:៤១:០៦]

**ឆ៖** ព្រោះពេល ដូចខ្ញុំអ៊ីចឹងថា គឺពេលនោះខ្ញុំថតវាមួយចំនួន មិនបានដូចប្រហែលជាកូនចៅខ្ញុំទេ ព្រោះខ្ញុំខស្បាហ៍នៅរៀនបច្ចេកទេសអារឿងលាងហ្វីល លាងអីទុក ខ្ញុំអត់ប៉ានបណ្ដោយណ៎ា។ ខ្ញុំឲ្យសុខចិត្តឲ្យកូនចៅទៅថត ពេលណាច្រើនបានខ្ញុំចុះទៅ តាឌុច ឲ្យខ្ញុំទៅផ្ទាល់។ ឲ្យតែមានការហៅទៅបាននេះ បាទ ព្រោះកន្លងមកគឺខ្ញុំខ្លាចតែខូច ក្មេងៗ ពេលខ្លះខូចហ្វីលអស់ក៏មានដែរណ៎ា។

**ស៖** នៅទំព័របន្ទាប់គឺលេខ ERN ដែលខ្ញុំទើបតែផ្ដល់នេះ លោកបានបន្តឆ្លើយ។ សូមដកស្រង់៖ "ភាគច្រើនខ្ញុំប្រើកូនចៅរបស់ខ្ញុំឲ្យទៅថតរូប ហើយខ្ញុំហ្នឹងជាអ្នកផ្ដិតរូបថត ដោយសារថារូបថតជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ច្រើនខូចនៅពេលដែល<កូនចៅ>ខ្ញុំលាងហ្វីលនោះទៅ”។ តើការអនុវត្តជាក់ស្តែងរបស់លោកនោះ តើលោកប្រើប្រាស់កូនចៅរបស់លោកឲ្យទៅថតរូបអ៊ីចឹងមែនទេ។ ឯលោកវិញ គឺជាអ្នកនៅផ្តិតរូបថត អ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំ វាមិនប្រើទាំងអស់ពេកទេ បើថាពេលខ្លះគេបុកខ្លាំងមែនទែន ខ្ញុំខ្លាចអាពេលយកទៅហ្នឹង ថតទៅ មកដល់បណ្តោយឲ្យលាងៗបញ្ចូលហ្វីលទៅ ខ្លាចប៉ះគ្នា តែប៉ះ គឺប៉ះគ្នា គឺផ្តិតទៅ លាងហ្វីលទៅ ដិតដាមទាំងអស់ ខូចទាំងអស់ បានខ្ញុំមិនទុកចិត្ត។ ហើយណាទី១ ផ្នែកបច្ចេកទេសលាយថ្នាំទៀត តែលាយមិនគ្រប់ចំនួនវាៗឡើងប្រផេះ គឺវាទៅខ្មៅពេក ខ្មៅទៅវិញ។

[១៥:៤៣:១៩]

**សៈ** ខ្ញុំយល់ពីចំណុចនេះហើយលោក ប៉ុន្តែសំណួរខ្ញុំ តើតាមការអនុវត្តជាធម្មតានោះគឺកូនចៅរបស់លោកទេឬដែលជាអ្នកទៅថតរូប ហើយលោកជាអ្នកនៅផ្តិតរូបថត <តើហ្នឹង>គឺជាការធ្វើការប្រចាំថ្ងៃជាក់ស្តែងនៅស-២១ លោកធ្វើអ៊ីចឹងឬ?

**ឆ៖** វាមានពេលខ្ញុំទៅដែរ មិនថាអត់ទេណ៎ា ព្រោះកន្លែងខ្លះ បើថាពេលបុកមកច្រើនខ្ញុំទៅ។ ជួយទៅជួយថត ហើយជួយមើល។ បើតែថា មួយ ពីរ បីនាក់អី ខ្ញុំឲ្យទៅ សុង ហើយ បងនិត ទៅទេ។

**សៈ** ខ្ញុំសួរភ្ជាប់ពីចំណុចនេះ។ នៅពេលដែលមានអ្នកទោសច្រើនដែលត្រូវបានគេនាំចូលមក តើតែខ្លួនលោកម្នាក់ទេឬ ដែលទៅថតនៅពេលអ្នកទោសចូលមកច្រើន ឬក៏លោកទៅទាំងក្រុមរបស់លោកតែម្តង?

**ឆ៖** គឺខ្ញុំឲ្យខ្ញុំទៅ មានភាគច្រើនទៅតែពីរនាក់ទេ ទុកម្នាក់នៅចាំកន្លែងកាន់ ពួក (ឮមិនច្បាស់) តក់, អេន ព្រោះអីគេអត់ទាន់មកណ៎ា ព្រោះខ្ញុំខ្លាចចោលផ្ទះវាអត់ ទៅពីរនាក់ ទុកម្នាក់នៅចាំផ្ទះ។

**សៈ** ខ្ញុំសូមសួរបន្តពីអ្វីដែលលោកបានឆ្លើយទៅមេធាវីការពារក្តីពីមុននេះ។ មេធាវីការពារក្តីបានសួរលោកថា តើលោកដែលថតរូបអ្នកទោសដែលបានស្លាប់ទៅហើយនោះទេ? លោកបានឆ្លើយថា បាទ មានពេលខ្លះ ក្រោយពេលអ្នកទោសគេវាយដំរហូតដល់ស្លាប់ទៅ គេបានឲ្យយើងទៅថតរូបអ្នកទោសដែលស្លាប់នោះ។ នៅពេលដែលអ្នកទោសត្រូវបានគេវាយដំរហូតដល់ស្លាប់ តើខ្លួនលោកផ្ទាល់ជាអ្នកទៅថតអ្នកទោសដែលស្លាប់នោះ ឬក៏កូនចៅលោកទេ ដែលជាអ្នកទៅថត?

**ឆ៖** ហ្នឹង គឺខ្ញុំឡើងទៅថតផ្ទាល់ហើយ នៅអគារខាងត្បូង។

[១៥:៤៥:៥៦]

**ស៖** ចុះអ្នកណាដែលជាអ្នកមកប្រាប់លោក ថាមានអ្នកទោសស្លាប់ ហើយលោកត្រូវតែទៅថតរូប។ អ្នកណាជាអ្នកស្នើ ឬក៏បញ្ជាឲ្យលោកទៅថត?

**ឆ៖** គឺ ធី។ ធី គេប្រាប់តាឌុច, តាឌុច គេប្រាប់ខ្ញុំ។

**ស៖** រួចចុះអ្នកណាដែលប្រាប់ថា អ្នកទោសហ្នឹង ត្រូវបានគេវាយដំរហូតដល់ស្លាប់។ តើ ធី ឬក៏ជាអ្នកណាដែលប្រាប់ថា អ្នកទោសនេះគេវាយដំដល់ស្លាប់នោះ?

**ឆ៖** វារឿងនេះ តាឌុច គាត់ -- គេតេមកតាឌុច, តាឌុច គេប្រាប់ខ្ញុំទៅថតអ្នកទោស។ ដល់ទៅ ធី គេប្រាប់ហើយ។

**ស៖** តើលោកទៅថតអ្នកទោសដែលស្លាប់ហ្នឹង ទៅថតនៅឯណា?

**ឆ៖** នៅលើអគារ១ខាងត្បូង ជួរខាងត្បូង។

**ស៖** លោកនិយាយអំពីអគារខាងត្បូងនេះ គឺអគារដែលស្ថិតក្នុងបរិវេណស-២១ហ្នឹងមែនទេ?

**ឆ៖** បាទ មានអគារក្នុងជួរស-២១ហ្នឹង អគារប៉ុន្មានខ្នងឯណោះ អគារប៉ុន្មាន -- ហ្នឹងហើយដែលខាងត្បូង ខាងលិច ខាងជើង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតផ្តល់ឧទាហរណ៍មួយចំនួន គឺរូបថតអ្នកទោសដែលបានស្លាប់ ហើយខ្ញុំក៏សូមឲ្យសាក្សីបញ្ជាក់ ដើម្បីប្រតិចារឹកផងដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ តុលាការយកឯកសារនេះយកទៅឲ្យសាក្សី។

[១៥:៤៨:២៨]

**លោក ឌេល លីសាក់៖**

អ្វីដែលបានផ្តល់ទៅឲ្យសាក្សីពិនិត្យមើលនេះ គឺមានឯកសារបី។ ទី១ គឺជារូបថតដែលមាននៅក្នុងសៀវភៅរបស់ ដេវីដ ឆេនដ៍ល័រ គឺ “សំឡេងពីស-២១”។ នេះគឺ E3/1684, ERN 00192764។ ឯកសារទី -- រូបថតទី២គឺ E3/8063.49 – គឺ E3/8063.49។ <ឯកសារ>ទី៣នេះ គឺជាបញ្ជីអ្នកទោស ស-២១ ដែលបានស្លាប់ដោយសារជំងឺ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៧។ នេះគឺឯកសារ E3/3181, ERN ភាសាខ្មែរ 00088691, អង់គ្លេស 00784614, បារាំង 00728981។

លោកប្រធាន យើងខ្ញុំសូមការអនុញ្ញាតបញ្ចាំងរូបថតដែលមាននៅក្នុងសៀវភៅរបស់ ដេវីដ

ឆេនដ៍ល័រ គឺ00192764 មុន។ បាទ សូមបញ្ចាំងនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីសោតទស្សន៍ បញ្ចាំងរូបថតនេះនៅលើអេក្រង់ទូរទស្សន៍។

**សួរដោយលោក ឌេល លីសាក់៖**

បាទ សូមអរគុណ។ រូបថតទាំងពីរនេះគឺថាមាននៅក្នុងសៀវភៅរបស់លោក ដេវីដ ឆេនដ៍ល័រ យើងឃើញមានរូបថតអ្នកទោសចូល គឺឈ្មោះ <ឌឿ ភាជ ហើយនិង>រូបថតដែលគាត់ស្លាប់ហើយ ឬក៏ត្រូវបានគេសម្លាប់ហ្នឹងមានឈ្មោះរបស់គាត់ ហើយក៏មានថ្ងៃខែឆ្នាំផងដែរ។ លោកសាក្សីសំណួរដំបូងរបស់ខ្ញុំ តើអង្គភាពរបស់លោកឬ ដែលថតរូបថតអ្នកទោសដែលស្លាប់ដោយសារជំងឺនៅក្នុងបរិវេណ ស-២១ នោះ?

**លោក នឹម អ៊ីម៖**

**ឆ៖** ព្រោះអានេះគឺអ្នកថតហ្នឹងគឺ*(ឮមិនច្បាស់)* បើនិយាយក្នុងបរិវេណអគារក្នុងនេះហ្នឹងគឺមានគ្នាខ្ញុំតែបីនាក់ទេ តែបើរឿងក្រៅ ផុតពីអ្នកគេធំហ្នឹងវាមាន ដូចខ្ញុំប្រាប់អ៊ីចឹង មានអាស្រ៊ី មួយ ដែលវាអ្នកថត។ គេបក្ខជន ដូចខ្ញុំប្រាប់អ៊ីចឹង ព្រោះការងាររបស់ អាការងារអ្នកធំៗ គេអត់ឲ្យខ្ញុំទៅជិតទេ។

[១៥:៥១:៤៧]

**ស៖** តើលោកអាចបញ្ជាក់ពីរូបថតទី១បានទេ អំពីអ្នកទោសដែលស្លាប់នេះជារូប -- តើរូបថតនេះរូបថតៗនៅខាងក្នុង ស-២១ ទេ លោកអាចមើលឃើញស្គាល់ឥដ្ឋការ៉ូ លោកអាចមើលឃើញស្គាល់សញ្ញាណាមួយថាវានៅក្នុងស-២១ ហ្នឹងឬអត់ទេ?

**ឆ៖** ព្រោះរូប -- អាហ្នឹងជួនណាងាប់នៅកន្លែងសួរចម្លើយក៏មាន ជួនណាងាប់យកមកដល់កន្លែងលើអគារក៏មាន។

**លោក ឌេល លីសាក់៖**

លោកប្រធាន ក៏សុំបញ្ចាំងឯកសារ <E3/8063.49> នៅលើអេក្រង់ផងដែរ។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីសោតទស្សន៍ដាក់បញ្ចាំងឯកសារនេះនៅលើអេក្រង់ទូរទស្សន៍។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** អ្វីដែលខ្ញុំចង់សួរទៅលោកគឺវា នោះមានសញ្ញាមួយដាក់នៅលើខ្លួនអ្នកទោសដែលស្លាប់។

តើលោកចាំទេថា អង្គភាពរបស់លោក<គេ>មានឲ្យប្រើសញ្ញាមួយ គឺក្នុងនោះគឺមានឈ្មោះអ្នកទោស និងកាលបរិច្ឆេទដែលលោកថតអ្នកទោសដែលស្លាប់នៅក្នុងបរិវេណហ្នឹង។ លោកចាំទេ?

**លោក នឹម អ៊ឹម៖**

**ឆ៖** ព្រោះអានេះបើតាមខ្ញុំដឹងណ៎ា គឺងាប់ក្នុងអគារ ប៉ុន្តែគេសែងយកមកចេញក្រៅហើយ បានថតៗទៅតែម្តង ហើយដាក់លេខថ្ងៃខែ ដែលៗឈ្មោះហ្នឹង។

**ស៖** តើរូបថតអ្នកទោសដែលគេបានយកចេញមកក្រៅ<បរិវេណ> តើអង្គភាពរបស់លោកជាអ្នកថតរូប ឬក៏ផ្នែកខាងណាជាអ្នកថតរូបអ្នកទោសដែលគេសែងចេញមកក្រៅអគារក្រោយស្លាប់ហើយនោះ?

[១៥:៥៤:១៧]

**ឆ៖** គឺខាងអង្គភាពខ្ញុំអ្នកថតទេ។

**ស៖** បាទ សម្រាប់ប្រតិចារឹកលោកប្រធាន អ្នកទោសដែលបានបង្ហាញនៅក្នុងរូបថតទាំងពីរនេះ គឺ <ឌៀ ភាជ> និង <ម៉ាន ពៅ> គឺរូបថតទាំងពីរនេះអាចរកឃើញនៅក្នុងបញ្ជីអ្នកទោសនៅស-២១ ដែលស្លាប់ដោយជំងឺនៅថ្ងៃទី១២ តុលា ៧៧ ដូចដែលខ្ញុំបានផ្តល់លេខឯកសារយោងមកហើយ <ឌៀ ភាជ> នេះគេហៅថា ណុប ហៅក្រៅថា ណុប។ បញ្ជីអ្នកទោសពីសហថៅក្រមស៊ើបអង្កេត គឺលេខរៀង១៣៩៤ ហើយដែលមានអាយុ<៤៩>ឆ្នាំមកពី<តំបន់១> ភូមិភាគពាយ័ព្យ ចូលមកនៅថ្ងៃ ១២ កញ្ញា ៧៧ ។ អ្នកទោសដែលស្លាប់ទី២ <ឈ្មោះ ម៉ាន ពៅ> គឺមានលេខរៀង៥៣៨៩ និងនៅលើបញ្ជីរបស់សហថៅក្រមស៊ើបអង្កេតថាជា -- មានអាយុ៣៣ឆ្នាំ ជាប្រជាជនថ្មីមកពីតំបន់១ ភូមិភាគពាយ័ព្យ។ អ្នកទាំងពីរនេះ គឺថាមានលេខទី១ និងលេខរៀងទី២ នៅលើបញ្ជីអ្នកទោសដែលស្លាប់ដោយសារជំងឺនៅស-២១ <គឺឯកសារ E3/3181>។ លោកសាក្សី លោកត្រូវការទឹកពិសាខ្លះឬទេ?

យើងនៅសល់ពេលតែពីរបីនាទីទៀត ខ្ញុំចូលប្រធានបទថ្មី។ ខ្ញុំសូមសួរលោកអំពី ញ៉ែម អេន និងពេលវេលាដែលគាត់ចូលមកធ្វើការនៅស-២១ ជាលើកដំបូង។ មេធាវីការពារក្តីក៏បានសួរលោកពីមុនរួចមកហើយ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកឯកសារ E3/7639 ជាមួយសហថៅក្រមស៊ើបអង្កេត, ERN ជាខ្មែរ 00162711, អង់គ្លេស 00162734, បារាំង 00338077។ លោកបានឆ្លើយដូចតទៅ សូមដកស្រង់៖ “ក្រោយមក នៅពេលគេចាប់តាណាត គេបានបញ្ជូនក្មេងៗដូចជា អេន តូចនេះឲ្យមករៀនថតរូបពីខ្ញុំ។” ហើយនៅទំព័រខាងក្រោម សូមដកស្រង់៖ “នៅពេលដែលគេចាប់ខ្លួន

ហើយនាំ តាណាត ចូលមក មួយខែក្រោយក្រោយពេលចាប់ខ្លួនហ្នឹង មិត្តភក្តិខ្ញុំម្នាក់នៅកន្លែងសួរចម្លើយ បានប្រាប់ខ្ញុំថា តាណាត ត្រូវបានគេចាប់ខ្លួន ហើយនាំចូលមកខាងក្នុងនេះហើយ។ ពីរខែក្រោយមក គេបានយកក្មេងៗឲ្យមករៀនថតរូបពីខ្ញុំ។ សួរថា៖ តើពួកគេឈ្មោះអ្វីខ្លះ? ខ្ញុំនៅនឹកឃើញឈ្មោះ អេន ម្នាក់។” នៅពេលដែលលោកនិយាយអំពីការចាប់ខ្លួន តាណាត តើលោកសំដៅទៅលើ តាណាត អតីតមេបញ្ជាការកងពល៧០៣ នោះមែនទេ?

**ឆ៖** បាទ។

[១៥:៥៨:២៧]

**ស៖** មូលហេតុដែលខ្ញុំសួរលោកពីចំណុចនេះ លោកសាក្សី ដោយសារនៅក្នុងកិច្ចសម្ភាសន៍របស់លោក លោកថាពីរខែក្រោយមក ក្រោយពីការចាប់ខ្លួន គឺថាចាប់ខ្លួន ណាត ហ្នឹងគឺឈ្មោះ អេន ហ្នឹងបានមករៀនថតពីលោក។ ប៉ុន្តែកំណត់ត្រានៅស-២១ គឺលេខរៀង <១៤៨៦៦> បញ្ជីរបស់សហថៅក្រុមស៊ើបអង្កេតស-២១ បានបង្ហាញថា ណាត មិនបានចាប់ខ្លួន -- ចាប់ខ្លួនរហូតដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៨ ឯណោះ គឺតែពីរសប្តាហ៍មុនពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំទៅ។” តើអាចទេដែលថាលោកអាចនឹងច្រឡំថ្ងៃខែឆ្នាំ ដែល ញ៉ែម អេន ចូលទៅស-២១ ជាលើកដំបូង? ពីព្រោះថា មើលទៅវាអាចថា លោកថាពីរខែក្រោយពីការចាប់ខ្លួន តាណាត អ៊ីចឹងលោកអាចច្រឡំពេលវេលាទេមើលទៅ?

**ឆ៖** ព្រោះពេលហ្នឹង ខ្ញុំលំបាកដែរបាទ អត់ដែលចាំដែរ ប៉ុន្តែគ្រាន់ថា ដឹងថាពួកម៉ាកខ្ញុំវាអ្នកខាងក្នុង គេប្រាប់ថា តាណាត គេចាប់ហើយ។ គ្រាន់តែបានតែប៉ុណ្ណឹង ខ្ញុំបានប៉ុន្មានក្រោយមកបានឃើញ ញ៉ែម អេន ចូលទៅ ខ្ញុំភ្ញាក់ខ្លួនព្រឺត យកក្មេងៗចូលទៅរៀននឹងខ្ញុំ។ រួចព្រោះខ្ញុំកន្លងមក ខ្ញុំមិនដែលជួបពួក ញ៉ែម អេន ផង។ ហើយយកមកអាស្ងរធំៗ យកតូចៗ ខ្ញុំថាធ្លាប់ថាកន្លងមក ខ្ញុំធ្លាប់ឃើញថា បើគេបណ្តុះអាថ្មីបានហើយ អាចាស់ត្រូវគេយកចេញហើយ។ បានខ្ញុំតាំងចិត្តថា ប្រាប់គ្នាខ្ញុំកុំឲ្យរៀនបង្អាត់ចេះពេកហ្នឹងណា។

[១៦:០០:៣៣]

**ស៖** លោកប្រធាន ខ្ញុំសូមសួរមួយសំណួរទៀតមុនពេលឈប់សម្រាក។ លោកសាក្សី ព្រឹកមិញនេះក៏លោកបានឆ្លើយដូចគ្នាដែរថា លោកបានបង្រៀនក្មេងៗ។ បើលោកបង្រៀនក្មេងៗទាំងនេះឲ្យចេះអស់តែម្តងគឺថា លោកនឹងត្រូវគេសម្លាប់ចោលហើយ។ ហេតុអីបានជាលោកនិយាយថាអ៊ីចឹង ថាបើ

សិនណាជាលោកបង្រៀនក្មេងៗនេះឲ្យចេះថតរូបចប់សព្វគ្រប់នោះគឺថា គេនឹងសម្លាប់លោកចោលហើយក្រោយមក?

**ឆ៖** មូលហេតុ មើលមូលហេតុទី១ តាណាត អ្នកនាំខ្ញុំចូលទៅស-២១ ហ្នឹងមូលហេតុទី១។ បាទ ដូច្នេះឃើញ តាណាត ហើយ តាណាត ជាអ្នកធ្លាប់ជាមេខាងទាហានកងពលដែលខ្ញុំនៅរស់នៅជាមួយកងពលរបស់គាត់ហ្នឹងណ៎ា។ អ៊ីចឹងបាន គ្រាន់ព្រោះខ្ញុំធ្លាប់ឃើញកន្លងមក បើឃើញមានតែមានខ្សែរបស់ដូចថា មានន័យថាខ្ញុំជានីរសារកងពល តែគេចាប់កងពលបាន មានន័យថាក៏ទៅដែរ។ ហើយអ្នកចូលធ្វើប្រវត្តិរូប អ្នកណានាំចូល តែប៉ានតែមេអ្នកនាំចូលក្បត់ អ្នកដែលចូលទៅជាមួយក៏ទៅដែរ។ អាហ្នឹងខ្ញុំធ្លាប់សង្កេតឃើញអ៊ីចឹងណេ។

[១៦:០១:៥៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។

ឥឡូវដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ ហើយសវនាការនឹងលើកបន្តធ្វើនៅថ្ងៃសុក្រ ទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ដែលចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកអង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី នឹម អ៊ឹម បញ្ចប់ ហើយនិងចាប់ផ្ដើមសក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-283 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់។

អង្គជំនុំជម្រះអរគុណ នឹម អ៊ឹម ដំណើរការស្ដាប់សក្ខីកម្មរបស់លោកនៅពេលនេះ មិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃស្អែកទៀត ដែលចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សីអ្នកជំនាញក្នុងការជូនលោក នឹម អ៊ឹម វិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ និងសូមអញ្ជើញគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះនៅថ្ងៃសុក្រ ទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃុំឃាំងនៃ អ.វ.ត.ក វិញ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួម

សវនាការនៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

អញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*